# គោលលទ្ធិនៃពួកជំនុំបាទីស្ទឆ្នាំ១៦៨៩

# The Baptist Confession of Faith of 1689

# គោលលទ្ធិនៃពួកជំនុំ
# បាទីស្ទឆ្នាំ១៦៨៩

# The Baptist Confession of Faith of 1689

Translated and Published by:

**Church of Mercy Books**
Street 21 Prek Talay
Prek Ambel, Saang
Kandal, Cambodia

0

CHURCH OF MERCY BOOKS

កម្មសិទ្ធរបស់:

**ព្រះវិហារមេត្តាករុណាព្រែកអំបិល**

បកប្រែដោយ:

**លោក មាស ម៉ាដែស**

**លោក អ៊ុច អភិរិន**

**លោក ហេល ប៉ៀល**

ផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធខ្មែរដោយ:

**លោកគ្រូគង្វាល ឆ្លួន ឆេង**

**លោកគ្រូ ឯម វណ្ណាថន**

This translation of the 1689 Baptist Confession of Faith into Khmer is an answer to prayer for Biblical literature for the Cambodian people. Pastor Chheng Nuon of the Church of Mercy Prek Ambel is commissioned by the First Baptist Church of Parker, Texas, USA. He has served in Cambodia since 1999, planting churches. He has seen the need for teaching his flock the foundational doctrines of the Christian faith. It is our prayer that this confession of Faith will be a blessing to other Christians in Cambodia.

Special thanks to Shalom Church Singapore for their support, encouragement, and commitment to translating good books into the Khmer language.

**Contact Information:**

www.thechurchofmercy.org
info@thechurchofmercy.org

The Church of Mercy
Street 21 Prek Talay
Prek Ambel, Saang
Kandal, Cambodia

Pastor Chheng Nuon
mmcchheng@yahoo.com
(011) 672-757

រក្សាសិទ្ធិគ្រប់យ៉ាង

Copyright 2010

# មាតិកា

**ទំព័រ**


| | | | |
|---|---|---|---|
| **បុព្វកថា** | ៖ | ........................................ | xi |
| **ជំពូក ១** | ៖ | ព្រះគម្ពីរបរិសុទ្ធ .................................. | 1 |
| **ជំពូក ២** | ៖ | ព្រះជាម្ចាស់ និង ព្រះត្រៃឯកបរិសុទ្ធ ............................. | 8 |
| **ជំពូក ៣** | ៖ | រាជឱង្ការរបស់ព្រះ ............................ | 11 |
| **ជំពូក ៤** | ៖ | ការបង្កើតរបស់ព្រះ ............................ | 16 |
| **ជំពូក ៥** | ៖ | ការទំនុកបំរុងរបស់ព្រះជាម្ចាស់ ........... | 18 |
| **ជំពូក ៦** | ៖ | ការធ្លាក់ចុះរបស់មនុស្ស អំពើបាប និង ទណ្ឌកម្ម ...................... | 22 |
| **ជំពូក ៧** | ៖ | សេចក្តីសញ្ញារបស់ព្រះជាម្ចាស់ ........... | 25 |
| **ជំពូក ៨** | ៖ | ព្រះគ្រីស្ទជាអ្នកបង្រួបបង្រួម .............. | 27 |
| **ជំពូក ៩** | ៖ | ឆន្ទះសេរី ......................................... | 35 |
| **ជំពូក ១០** | ៖ | ការត្រាស់ហៅដ៏ស័ក្តិសិទ្ធិ .................... | 37 |
| **ជំពូក ១១** | ៖ | ការរាប់ជាសុចរិត .............................. | 40 |
| **ជំពូក ១២** | ៖ | ការទទួលជាកូនចិញ្ចឹម ....................... | 43 |
| **ជំពូក ១៣** | ៖ | ការញែកចេញជាបរិសុទ្ធ ..................... | 44 |
| **ជំពូក ១៤** | ៖ | ជំនឿដែលបានសង្គ្រោះ ...................... | 46 |

| | | | |
|---|---|---|---|
| **ជំពូក ១៥** | ៖ | ការប្រែចិត្តសំរាប់ជីវិត | |
| | | និង សេចក្តីសង្គ្រោះ .......................... | 49 |
| **ជំពូក ១៦** | ៖ | ការប្រព្រឹត្តិល្អ ................................... | 52 |
| **ជំពូក ១៧** | ៖ | សេចក្តីខ្ជាប់ខ្ជួននៃពួកបរិសុទ្ធ ............. | 56 |
| **ជំពូក ១៨** | ៖ | ការដឹងច្បាស់ អំពីព្រះគុណ | |
| | | និង សេចក្តីសង្គ្រោះ ......................... | 59 |
| **ជំពូក ១៩** | ៖ | ក្រិត្យវិន័យរបស់ព្រះជាម្ចាស់ ............. | 63 |
| **ជំពូក ២០** | ៖ | ដំណឹងល្អ និង ឥទ្ធិពលរបស់វា ........... | 68 |
| **ជំពូក ២១** | ៖ | សេរីភាពរបស់គ្រីស្ទបរិស័ទ | |
| | | និង សេរីភាពនៃបញ្ញាចិត្ត ................... | 71 |
| **ជំពូក ២២** | ៖ | ថ្ងៃថ្វាយបង្គំព្រះ និង | |
| | | ថ្ងៃឈប់សំរាក ................................. | 74 |
| **ជំពូក ២៣** | ៖ | សម្បថ និង | |
| | | បំណាន់ដែលត្រឹមត្រូវ ......................... | 79 |
| **ជំពូក ២៤** | ៖ | ច្បាប់រដ្ឋ ........................................ | 81 |
| **ជំពូក ២៥** | ៖ | អាពាហ៍ពិពាហ៍ ................................ | 83 |
| **ជំពូក ២៦** | ៖ | ពួកជំនុំ ............................................ | 84 |
| **ជំពូក ២៧** | ៖ | ការប្រកបគ្នារបស់ពួកបរិសុទ្ធ ............ | 92 |
| **ជំពូក ២៨** | ៖ | ពិធីបុណ្យជ្រមុជទឹក | |
| | | និង ពិធីលៀងព្រះអម្ចាស់ ................ | 94 |

| | | | |
|---|---|---|---|
| **ជំពូក ២៩** | ៖ | ពិធីបុណ្យជ្រមុជទឹក ........................... | 95 |
| **ជំពូក ៣០** | ៖ | ពិធីលៀងព្រះអម្ចាស់ ......................... | 96 |
| **ជំពូក ៣១** | ៖ | សណ្ឋានរបស់មនុស្សក្រោយពី ស្លាប់ទៅ និង ការរស់ឡើងវិញ .......... | 101 |
| **ជំពូក ៣២** | ៖ | ការជំនុំជំរះចុងក្រោយ ...................... | 103 |

# បុព្វកថា

មានសៀវភៅជាច្រើនត្រូវបានសរសេរ និង ប្រើប្រាស់សំរាប់អានដើម្បីជំនួយដល់សេចក្តីជំនឿរបស់គ្រីស្ទបរិស័ទ ។ តែចំពោះសៀវភៅគោលលទ្ធិជំនឿនេះវិញ ជាគន្លង ឬ ជាបន្ទាត់ដែលបានយកចេញពីព្រះគម្ពីរពីសេចក្តីពិតដែលយើងអាចអនុវត្តតាម ។ វាជាគោលសំខាន់ ដើម្បីអោយជំនឿរបស់យើង មានគោលដៅច្បាស់លាស់ ។ មិនត្រឹមតែប៉ុណ្ណោះ វាក៏ដឹកនាំយើងអោយស្គាល់ពីព្រះហឫទ័យ និង ផែនការរបស់ព្រះជាម្ចាស់សំរាប់រាស្ត្របរិសុទ្ធរបស់ទ្រង់ផងដែរ ។ តាមរយៈនេះ យើង អាចយល់ពីគ្រប់ទាំងការអាថ៌កំបាំង អំពីសេចក្តីពិតនៃព្រះគុណអស្ចារ្យទ្រង់បាន ។ អ្នកដែលអាចអនុវត្តតាមគោលលទ្ធិនេះបាន គឺមានតែរាស្ត្រពិតប្រាកដរបស់ទ្រង់ប៉ុណ្ណោះ ។

មានមតិមួយចំនួនតែងនិយាយថា មិនចាំបាច់មានគោលលទ្ធិទេ តែមតិនេះ ជាមតិទុទិដ្ឋិនិយមវិញ ។ ប្រទេសនិមួយៗមានច្បាប់ផ្សេងៗពីគ្នា តែបើប្រទេសគ្មានច្បាប់ទេ ប្រទេសនោះ ជាប្រទេសអនាធិបតេយ្យសេរីឥតព្រំដែន ។ ដូច្នេះយើងគួរមានគោលលទ្ធិច្បាស់លាស់ ដើម្បីរក្សាភាពពិតនៃសេចក្តីជំនឿ កុំអោយរវើរវាយតាមគំនិតរបស់មនុស្ស តាមឥទ្ធិពលរបស់អ្នកមានអំណាច ឬ អ្នកដែលមានរោបាបំប្លែងព្រះបន្ទូល ឬពួកក្រុមខុសឆ្គងផ្សេងៗ ។ ជាទីបញ្ចប់ ខ្ញុំសូមអរគុណចំពោះព្រះជាម្ចាស់ដែលបានផ្គត់ផ្គង់ការបកប្រែ និងបោះពុម្ពនេះ ។ សូមអរគុណចំពោះព្រះជាម្ចាស់ !

គ្រូគង្វាលនៃក្រុមជំនុំមេត្តាករុណា

**នួន ឆេង**

# ជំពូក ១
# ព្រះគម្ពីរបរិសុទ្ធ

១. ព្រះគម្ពីរបរិសុទ្ធគឺជាច្បាប់តែមួយគត់ ដែលពេញលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវមិនមានកំហុស ហើយមានគ្រប់ទាំងចំណេះដឹងសេចក្តីជំនឿ និងការស្តាប់បង្គាប់[១] ។ តាមរយៈធម្មជាតិ ហើយនិងការងារនៃស្នាព្រះហស្តរបស់ព្រះ និងការទំនុកបំរុងរបស់ទ្រង់ បានបង្ហាញអោយឃើញពីសេចក្តីល្អ ប្រាជ្ញាញាណ និងអំណាចរបស់ទ្រង់ ។ ដូចនេះគេគ្មានការដោះសារណាមួយ ក្នុងការដែលពួកគេមិនជឿនោះឡើយ ប៉ុន្តែធម្មជាតិ ហើយនិងការងារនៃស្នាព្រះហស្តរបស់ទ្រង់ទាំងនោះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ការស្គាល់អំពីព្រះជាម្ចាស់ និងបំណងព្រះហឫទ័យរបស់ទ្រង់ គឺជាការចាំបាច់សំរាប់សេចក្តីសង្គ្រោះ[២] ។ ដូច្នេះក្នុងកាលៈទេសៈខ្លះ និងតាមរបៀបខ្លះ[៣] ព្រះដ៏មានសេចក្តីមេត្តាករុណា បានបង្ហាញអំពីអង្គទ្រង់ និងធ្វើអោយពួកជំនុំរបស់ទ្រង់ បានស្គាល់ពីបំណងព្រះហឫទ័យរបស់ទ្រង់ ។ ហើយលើសពីនោះទៅទៀត ទ្រង់ធ្វើអោយការបើកសំដែងអំពីអង្គទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់ បានកត់ទុកទាំងស្រុងអំពីការបើកសំដែងនោះ សំរាប់ធានាការការពារ ការផ្សព្វាយពីសេចក្តីពិត ការតាំងឡើង និងសេចក្តីកំសាន្តចិត្តរបស់ពួកជំនុំ ដើម្បីប្រឆាំងនឹងនិស្ស័យពុករលួយរបស់មនុស្ស និងការព្យាបាទរបស់អារក្សសាតាំង និងលោកិយនេះ ។ ហើយរបៀបដែលព្រះ

បានប្រើ ដើម្បីបើកសំដែងពីបំណងព្រះហឫទ័យរបស់ទ្រង់នេះ បានចប់សព្វគ្រប់ហើយ[៤] ដូច្នេះព្រះគម្ពីរបរិសុទ្ធពិតជាចាំបាច់ខ្លាំងណាស់ សំរាប់មនុស្ស ដើម្បីអោយបានស្គាល់ព្រះ និងបំណងព្រះហឫទ័យរបស់ទ្រង់ ។

[១] ២ធី ៣:១៥-១៧; អេសា ៨:២០; លូ ១៦:២៩, ៣១; អេ ២:២០ ។ [២]រ៉ូម ១:១៩-២១; ២:១៤, ១៥; ទំនុក ១៩:១-៣ ។ [៣]ហេ ១:១ ។ [៤]សុ ២២:១៩-២១; រ៉ូម ១៥:៤; ២ពេ ១:១៩, ២០ ។

២. ព្រះគម្ពីរបរិសុទ្ធ ឬក៏ព្រះបន្ទូលកត់ត្រាទុករបស់ព្រះ មាននៅក្នុងកណ្ឌព្រះគម្ពីរទាំងអស់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីដូចខាងក្រោមនេះ

**គម្ពីរសញ្ញាចាស់** - លោកុប្បត្តិ, និក្ខមនំ, លេវីវិន័យ, ជនគណនា, ចោទិយកថា, យ៉ូស្វេ, ចៅហ្វាយ, នាងរស់, សាំយូអែលទី១ និង ទី២, ពង្សាវតារក្សត្រទី១ និង ទី២ របាក្សត្រទី១ និង ទី២, អែសរ៉ា, នេហេមា, នាងអេសធើរ, យ៉ូប, ទំនុកដំកើង, សុភាសិត, សាស្តា, បទចំរៀងសាឡូម៉ូន, អេសាយ, យេរេមា, បរិទេវ, អេសេគាល, ដានីយ៉ែល, ហូសេ, យ៉ូអែល, អេម៉ុស, អូបាឌា, យ៉ូណាស, មីកា, ណាហ៊ុម, ហាបាគុក, សេផានា, ហាកាយ, សាការី, ម៉ាឡាគី ។

**គម្ពីរសញ្ញាថ្មី** - ម៉ាថាយ, ម៉ាកុស, លូកា, យ៉ូហាន, កិច្ចការ, រ៉ូម, កូរិនថូសទី១ និង ទី២, កាឡាទី, អេភេសូរ, ភីលីព, កូល៉ុស,

ថែស្សាឡូនីចទី១ និង ទី២, ធីម៉ូថេទី១ និង ទី២, ទីតុស, ភីលេម៉ូន, ហេព្រើរ, យ៉ាកុប, ពេត្រុសទី១ និង ទី២, យ៉ូហាន ទី១, ទី២ និង ទី៣, យូដាស, វិវរណៈ ។

គ្រប់បទគម្ពីរទាំងអស់នេះគឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលអោយតែងទេ ដើម្បីធ្វើខ្នាតនៃសេចក្តីជំនឿ និងជីវិត[៥] ។

[៥] ២ធី ៣:១៦ ។

៣. មានសៀវភៅឯទៃទៀត ដែលគេហៅជាទូទៅថា “អាប៉ូគ្រីហ្វា” (The Apocrypha) ។ សៀវភៅទាំងនេះ ព្រះទ្រង់មិនបានបញ្ចេញព្រះវិញ្ញាណអោយតែងទេ ហើយវាក៏មិនមែនជាផ្នែកណាមួយនៃព្រះគម្ពីរបរិសុទ្ធ ឬជាច្បាប់នៃព្រះគម្ពីរដែរ ។ ដូច្នេះហើយ បានជាវាមិនមានអំណាចចំពោះពួកជំនុំនៃព្រះជាម្ចាស់ ។ ប៉ុន្តែវាបានទទួលការអនុញ្ញាតអោយប្រើប្រាស់តាមរបៀប ដូចជាសំណេរទូទៅរបស់មនុស្សជាតិធម្មតាតែប៉ុណ្ណោះ[៦] ។

[៦] លូ ២៤:២៧, ៤៤; រ៉ូម ៣:២ ។

៤. ការបញ្ជាក់នៃអំណាចរបស់ព្រះគម្ពីរ គឺមកពីខ្លួនវាផ្ទាល់ ។ អំណាចនៃព្រះគម្ពីរបរិសុទ្ធ មិនមែនអាងលើទីបន្ទាល់របស់មនុស្ស ឬ ពួកជំនុំណាម្នាក់នោះឡើយ ។ ផ្ទុយទៅវិញ ព្រះគម្ពីរផ្អែកទៅលើព្រះជាម្ចាស់ទាំងស្រុង ដែលទ្រង់ជាអ្នកនិពន្ធ និងជាសេចក្តីពិត ។ ដូចនេះហើយ យើងគួរទទួលវាដោយព្រោះ វាគឺជាព្រះបន្ទូលរបស់ព្រះ[៧] ។

[៧] ២ពេ ១:១៩-២១; ២ធី ៣:១៦; ២ថែស ២:១៣; ១យ៉ូន ៥:៩ ។

៥. ទីបន្ទាល់នៃក្រុមជំនុំរបស់ព្រះ អាចនឹងមានឥទ្ធិពលធ្វើអោយយើងគិត ដើម្បីអោយយើងកោតសរសើរ និងអោយតំលៃខ្ពស់ទៅលើព្រះគម្ពីរភាពជាលក្ខណ:ស្ថានសួគ៌នៃមាតិកាដ៏មានប្រសិទ្ធភាព នៃសេចក្តីបង្រៀនរបស់វា និងរចនាបទដ៏អស្ចារ្យ ព្រមទាំងការព្រមព្រៀងគ្នានៃគ្រប់ផ្នែកទាំងអស់ តាំងពីដើមដំបូង រហូតដល់ចុងបញ្ចប់ ។ ការទាំងអស់នេះធ្វើអោយយើងជឿថា នេះជាព្រះគម្ពីររបស់ព្រះអង្គ ។ សេចក្តីពិតគ្រប់ផ្នែកទាំងអស់នោះ ថ្វាយគ្រប់សិរីរុងរឿងទាំងអស់ដល់ព្រះជាម្ចាស់ ហើយវាជាសេចក្តីពិតដែលបង្រៀនពីផ្លូវតែមួយគត់ នៃសេចក្តីសង្គ្រោះ ព្រមទាំងមានគុណលក្ខណ: និងសេចក្តីគ្រប់លក្ខណ៍ដ៏ពោរពេញផ្សេងៗទៀតជាច្រើន ដែលបានផ្តល់នូវភស្តុតាងជាបរិបូរថា វាជាព្រះបន្ទូលរបស់ព្រះមែន ។ សំខាន់ជាងនេះទៅទៀត វាគឺជាការងាររបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តរបស់យើង ដែលធ្វើអោយយើងជឿថា ព្រះគម្ពីរគឺជាសេចក្តីពិត ហើយវាមានអំណាចព្រះប្រាកដមែន[៨] ។

[៨]យ៉ូន ១៦:១៣, ១៤; ១កូ ២:១០-១២; ១យ៉ូន ២:២០, ២៧ ។

៦. គ្រប់ទាំងព្រះបន្ទូលនៃព្រះ សុទ្ធតែជាការបើកសំដែងគ្រប់ផ្នែក អំពីភាពចាំបាច់សំរាប់សិរីល្អរបស់ទ្រង់ផ្ទាល់ ហើយនិង សំរាប់សេចក្តីសង្គ្រោះ សេចក្តីជំនឿ និងជីវិតរបស់មនុស្ស ដែលមានកត់ត្រាទុកយ៉ាងច្បាស់ចំៗ ឬដោយប្រយោលក្នុងព្រះគម្ពីរបរិសុទ្ធ ។ យើងមិនត្រូវបន្ថែមអ្វីណាមួយទៅក្នុងព្រះគម្ពីរជាដាច់ខាត ទោះជាយើងគិតថា ការនោះជាការបើកសំដែងថ្មីដោយព្រះវិញ្ញាណបរិសុទ្ធ ឬ ជាប្រពៃណី

ទំនៀមទំលាប់ល្អរបស់មនុស្សក៏ដោយ[៩] ។ ទោះជាយ៉ាងណាក៏ដោយ យើងដឹងថា យើងត្រូវការពន្លឺផ្នែកខាងក្នុងពីព្រះវិញ្ញាណ ដើម្បីអោយយើងយល់បានយ៉ាងត្រឹមត្រូវ នូវអ្វីដែលព្រះគម្ពីរបានបើកសំដែង[១០] ។ យើងក៏ទទួលស្គាល់ថា ផ្នែកខ្លះនៃការថ្វាយបង្គំព្រះ និងការគ្រប់គ្រងក្រុមជំនុំដែលជាសកម្មភាពទូទៅនៅក្នុងក្រុមជំនុំ គួរត្រូវសំរេចចិត្តដោយយល់ដល់កាលៈទេសៈ និងសុភវិនិច្ឆ័យរបស់គ្រីស្ទបរិស័ទដែរ ។ ប៉ុន្តែការទាំងអស់នេះគួរតែអោយមានការឯកភាពគ្នា ទៅនឹងច្បាប់ទូទៅនៃព្រះបន្ទូលរបស់ព្រះ ។ យើងមិនគួរធ្វើអោយវាប្រាស់ចាកពីច្បាប់របស់ព្រះទេ[១១] ។

[៩] ២ធី ៣:១៥-១៧; កា ១:៨, ៩ ។ [១០]យ៉ូន ៦:៤៥; ១កូ ២:៩-១២ ។ [១១]១កូ ១១:១៣, ១៤; ១៤:២៦, ៤០ ។

៧. ផ្នែកខ្លះនៅក្នុងព្រះគម្ពីរ គឺមិនច្បាស់ដូចជាផ្នែកឯទៀតផ្សេងទៀតទេ ហើយមនុស្សខ្លះក៏អាចយល់ច្រើនជាងអ្នកផ្សេងទៀតដែរ[១២] ។ ប៉ុន្តែអ្វីដែលយើងត្រូវការដឹងសំរាប់សេចក្តីសង្គ្រោះ ហើយនិងអ្វីដែលយើងត្រូវជឿ និងស្តាប់បង្គាប់តាម បានបង្រៀននិងពន្យល់យ៉ាងច្បាស់នៅកន្លែងផ្សេងៗ ។ ដូចនេះហើយ អ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់ និងអ្នកដែលមិនមានការអប់រំ ក៏ពួកគេអាចយល់យ៉ាងច្បាស់បានដែរ ប្រសិនបើពួកគេព្យាយាមយល់[១៣] ។

[១២] ២ពេ ៣:១៦ ។ [១៣]ទំនុក ១៩:៧; ១១៩:១៣០ ។

៨. ព្រះគម្ពីរសញ្ញាចាស់ត្រូវបានកត់ត្រាជាភាសាហេព្រើរ (ដែលជាភាសាដើមនៃរាស្ត្ររបស់ព្រះកាលពីសម័យបុរាណ)[១៤] ហើយព្រះគម្ពីរសញ្ញាថ្មីត្រូវបានកត់ត្រាជាភាសាក្រិក (ភាសាដែលជាតិសាសន៍ជាច្រើនបានចេះជាទូទៅនាសម័យនោះ) ។ ព្រះបានបញ្ចេញព្រះវិញ្ញាណទ្រង់អោយតែងព្រះគម្ពីរទាំងពីរនេះ ទុកជាប្រភពដើម ហើយត្រូវបានថែរក្សាអោយបានបរិសុទ្ធគ្រប់សម័យកាល ដោយការថែរក្សាយកព្រះទ័យទុកដាក់ និងការទំនុកបំរុងរបស់ទ្រង់ ។ ហេតុដូចនេះ ព្រះគម្ពីរទាំងពីរនេះគឺពិតប្រាកដជាព្រះបន្ទូលរបស់ព្រះមែន ។ ការមិនព្រមព្រៀងគ្នាណាមួយនៅក្នុងក្រុមជំនុំ ព្រះគម្ពីរទាំងនេះគឺជាអំណាចលើគ្រប់ទាំងអស់ នៅក្នុងសេចក្តីជំនឿរបស់គ្រីស្ទបរិស័ទ[១៥] ។ រាស្ត្រទាំងអស់របស់ព្រះមានសិទ្ធិ និងយកចិត្តទុកដាក់ចំពោះព្រះគម្ពីរ ហើយពួកគេក៏ត្រូវបានបង្គាប់អោយអាន[១៦] និងស្រាវជ្រាវរកបទគម្ពីរទាំងនោះ ដោយកោតខ្លាចដល់ព្រះដែរ[១៧] ។ ប៉ុន្តែដោយព្រោះតែ ប្រជារាស្ត្ររបស់ព្រះមួយចំនួនមិនចេះភាសាដើមទាំងពីរនេះ (ភាសាហេព្រើរ និងភាសាក្រិក) ដូច្នេះហើយព្រះគម្ពីរគួរត្រូវបានបកប្រែជាភាសាគ្រប់ជាតិសាសន៍[១៨] យ៉ាងនេះមនុស្សនឹងទទួលចំណេះដឹងអំពីព្រះ ហើយ ពួកគេអាចគោរពថ្វាយបង្គំដល់ទ្រង់តាមរបៀបដែលត្រឹមត្រូវបាន ។ តាមរយៈភាពអត់ធ្មត់ និងការកំសាន្តចិត្តនៃព្រះគម្ពីរ នាំអោយពួកគេមានសេចក្តីសង្ឃឹម[១៩] ។

[១៤]រ៉ូម ៣:២ ។ [១៥]អេសា ៨:២០ ។ [១៦]កិច្ច ១៥:១៥ ។ [១៧]យ៉ូន ៥:៣៩ ។ [១៨]១កូ ១៤:៦, ៩, ១១, ១២, ២៤, ២៨ ។ [១៩]កូល ៣:១៦ ។

៩. ក្បួនច្បាប់ ដែលមិនចេះខុសសំរាប់ការបកស្រាយព្រះគម្ពីរនោះ គឺមានតែព្រះគម្ពីរផ្ទាល់ប៉ុណ្ណោះ មានន័យថា ការបកស្រាយផ្នែកមួយដោយផ្អែកលើផ្នែកមួយផ្សេងទៀត ។ ដូច្នេះហើយ សំនួរទាំងឡាយណាអំពីសេចក្តីពិត និងការយល់ដឹងច្បាស់លាស់ពីបទគម្ពីរនោះ ត្រូវតែស្រាវជ្រាវរកអត្ថបទគម្ពីរផ្សេងទៀត ដែលសំដែងច្បាស់ជាងបទគម្ពីរនោះ មកបង្ហាញ[២០] ។

[២០] ២ពេ ១:២០, ២១; កិច្ច ១៥:១៥, ១៦ ។

១០. គ្រប់ការដែលមិនព្រមព្រៀងគ្នាខាងជំនឿរបស់យើង គួរត្រូវសំរេចដោយព្រះគម្ពីរតែមួយប៉ុណ្ណោះ ។ រាល់ច្បាប់ផ្សេងៗរបស់ក្រុមប្រឹក្សា និងគំនិតរបស់អ្នកនិពន្ធពីបុរាណ ហើយនិងការបង្រៀនរបស់មនុស្ស ព្រមទាំងគំនិតពិសេសៗ នោះគួរទទួលយក ឬក៏ បដិសេធមិនទទួលយក គឺត្រូវផ្អែកទៅលើការបង្រៀនរបស់ព្រះគម្ពីរ ដែលព្រះបានប្រទានមកយើងរាល់គ្នាដោយព្រះវិញ្ញាណបរិសុទ្ធ ។ នៅក្នុងការសំរេចចិត្តបែបនេះ មានន័យថាសេចក្តីជំនឿរបស់យើង បានរកឃើញដំណោះស្រាយរបស់វាហើយ[២១] ។

[២១]ម៉ាថ ២២:២៩, ៣១, ៣២; អេ ២:២០; កិច្ច ២៨:២៣ ។

# ជំពូក ២
# ព្រះជាម្ចាស់ និង ព្រះត្រៃឯកបរិសុទ្ធ

១. មានព្រះតែមួយប៉ុណ្ណោះ ដែលមានព្រះជន្មរស់នៅសព្វថ្ងៃ និងជាព្រះដ៏ពិតប្រាកដ[១] ។ ទ្រង់មានព្រះជន្មគង់នៅដោយអង្គឯង ហើយវត្តមាន និងភាពគ្រប់លក្ខណ៍របស់ទ្រង់គ្មានព្រំខណ្ឌឡើយ[២] ។ ក្រៅពីទ្រង់ គ្មានអ្នកណាម្នាក់អាចយល់ពីនិស្ស័យរបស់ទ្រង់បានឡើយ[៣] ។ ទ្រង់ជាវិញ្ញាណបរិសុទ្ធ[៤] គេមិនអាចមើលឃើញទ្រង់បានឡើយ ហើយទ្រង់គ្មានរូបកាយ គ្មានអវយវៈ និងគ្មានអារម្មណ៍មនុស្សដែលតែងតែប្រែប្រួលនោះទេ ។ មានទ្រង់តែមួយប៉ុណ្ណោះ ដែលគង់នៅអស់កល្បជានិច្ចបាន ហើយទ្រង់គង់នៅក្នុងពន្លឺដ៏ចែងចាំង សំរាប់មនុស្សដែលតែងតែស្លាប់[៥] ។ ទ្រង់មិនចេះប្រែប្រួល[៦] ។ ទ្រង់ធំអស្ចារ្យ[៧] លើសជាងគំនិតរបស់យើង ។ ទ្រង់គង់នៅអស់កល្បជានិច្ច[៨] យើងមិនអាចយល់ពីទ្រង់បានទេ ។ ទ្រង់មានគ្រប់អំណាចព្រះចេស្តា[៩] ហើយគ្មានព្រំខណ្ឌ ។ ទ្រង់បរិសុទ្ធ[១០] មានប្រាជ្ញា សេរីភាព និងមានភាពពេញលេញបំផុត ។ ទ្រង់ធ្វើគ្រប់ការទាំងអស់ ទៅតាមបំណងព្រះហឫទ័យដែលមិនចេះប្រែប្រួល និងសុចរិតរបស់ទ្រង់[១១] សំរាប់ជាសិរីល្អរបស់ទ្រង់ផ្ទាល់[១២] ។ ទ្រង់មានសេចក្តីស្រឡាញ់ ភាពទន់សណ្តោស និងសេចក្តីមេត្តាករុណាបំផុត ។ ទ្រង់មានសេចក្តីល្អ និងសេចក្តីពិតដ៏ពោរពេញ ។ ទ្រង់អត់ទោសគ្រប់ទាំងសេចក្តីទុច្ចរិត អំពើរំលង និងអំពើបាប ។ ទ្រង់ប្រទានរង្វាន់ ដល់

អស់អ្នកណាដែលខិតខំស្វែងរកទ្រង់ ដោយប្រុងប្រយ័ត្ន[១៣] ។ ប៉ុន្តែទ្រង់ស្អប់អំពើបាប[១៤] ។ ទ្រង់នឹងមិនទតរំលង ឬក៏ ប្រណីដល់អ្នកណាដែលមានទោសឡើយ[១៥] ហើយទ្រង់ធ្វើការជំនុំជំរះដោយយុត្តិធម៌ដ៏បរិបូរ និងគួរអោយស្ញែងខ្លាចបំផុត [១៦] ។

[១]១កូ ៨:៤, ៦; ចោទិ ៦:៤ ។ [២]យេ ១០:១០; អេសា ៤៨:១២ ។ [៣]និក្ខ ៣:១៤ ។ [៤]យ៉ូន ៤:២៤ ។ [៥]១ធី១:១៧; ចោទិ៤:១៥, ១៦ ។ [៦]ម៉ាឡ ៣:៦ ។ [៧]១ពង្សា ៨:២៧; យេ ២៣:២៣ ។ [៨]ទំនុក ៩០:២ ។ [៩]លោក ១៧:១ ។ [១០]អេសា ៦:៣ ។ [១១]ទំនុក ១១៥:៣; អេសា ៤៦:១០ ។ [១២]សុ ១៦:៤; រ៉ូម ១១:៣៦ ។ [១៣]និក្ខ ៣៤:៦, ៧; ហេ ១១:៦ ។ [១៤]ទំនុក ៥:៥, ៦ ។ [១៥]និក្ខ ៣៤:៧; ណា ១:២, ៣ ។ [១៦]នេ ៩:៣២, ៣៣ ។

២. ព្រះជាម្ចាស់ទ្រង់មានគ្រប់ទាំងជីវិត[១៧] សិរីរុងរឿង[១៨] សេចក្តីល្អ[១៩] និងព្រះពរនៅក្នុងអង្គទ្រង់ផ្ទាល់ មានន័យថាទ្រង់មានគ្រប់របស់ទាំងអស់ ។ ទ្រង់មិនត្រូវការអ្វីណាមួយពីស្នាព្រះហស្ថ ដែលទ្រង់បានបង្កើតមកនោះទេ ហើយ ទ្រង់ក៏មិនត្រូវការសិរីល្អពីរបស់ទាំងអស់នោះដែរ[២០] ។ ផ្ទុយទៅវិញ ទ្រង់សំដែងសិរីល្អរបស់ទ្រង់នៅក្នុង និងតាមរយៈរបស់ទាំងនោះវិញ ។ ទ្រង់គឺជាប្រភពដើម ហើយជាដើមដំបូងនៃអ្វីៗទាំងអស់ ទ្រង់គឺជាផ្លូវទឹក ហើយទ្រង់ក៏ជាចុងបំផុតដែរ[២១] ។ ទ្រង់មានអំណាចដ៏ខ្ពង់ខ្ពស់ពេញលេញ លើរបស់ទាំងអស់ដែលទ្រង់បានបង្កើតមក ។ ទ្រង់ប្រើប្រាស់របស់ទាំងនោះតាមការដែលទ្រង់សព្វព្រះហឫទ័យប្រើ ហើយទ្រង់ធ្វើសំរាប់ពួកគេ ឬ ចំពោះពួកគេតាមតែ

ព្រះទ័យទ្រង់[២២] ។ នៅចំពោះទ្រង់ អ្វីៗគ្រប់យ៉ាងនៅជាអាក្រាត និងបើកចំហ[២៣] ។ ព្រះតំរិះរបស់ទ្រង់គ្មានព្រំខណ្ឌ ហើយមិនចេះខុស ។ ទ្រង់មិនពឹងផ្អែកលើអ្វីៗដែលជាស្នាព្រះហស្តរបស់ទ្រង់ទេ ហើយក៏គ្មានអ្វីដែលទ្រង់មិនស្គាល់ច្បាស់ដែរ[២៤] ។ រាល់ការសំរេចព្រះហឫទ័យរបស់ទ្រង់ ហើយអ្វីៗដែលទ្រង់ធ្វើ ឬក៏អ្វីៗដែលទ្រង់ទាមទារ សុទ្ធតែបរិសុទ្ធបំផុតទាំងអស់[២៥] ។ មនុស្ស និងពួកទេវតាជាស្នាព្រះហស្តរបស់ទ្រង់ដូច្នេះពួកគេគួរតែថ្វាយបង្គំ[២៦] បំរើ ស្តាប់បង្គាប់ ហើយនិងធ្វើអ្វីៗផ្សេងទៀតដែលទ្រង់ទាមទារអោយយើងធ្វើ ។

[១៧]យ៉ូន ៥:២៦ ។ [១៨]ទំនុក ១៤៨:១៣ ។ [១៩]ទំនុក ១១៩:៦៨ ។ [២០]យ៉ូប ២២:២, ៣ ។ [២១]រ៉ូម ១១:៣៤-៣៦ ។ [២២]ដា ៤:២៥, ៣៤, ៣៥ ។ [២៣]ហេ ៤:១៣ ។ [២៤]អេសេ ១១:៥; កិច្ច ១៥:១៨ ។ [២៥]ទំនុក ១៤៥:១៧ ។ [២៦]វិវ ៥:១២-១៤ ។

៣. នៅក្នុងលក្ខណៈជាព្រះដ៏ឥតព្រំខណ្ឌនេះ មានអង្គបុគ្គលបីដែលរួមគ្នា គឺ ព្រះវរបិតា ព្រះរាជបុត្រា (ឬព្រះបន្ទូល) និងព្រះវិញ្ញាណបរិសុទ្ធ[២៧] ។ អង្គបុគ្គលទាំងបីនេះមាននិស្ស័យ អំណាច និងភាពអស់កល្បតែមួយប៉ុណ្ណោះ ។ អង្គបុគ្គលនីមួយៗ ជាព្រះមួយរយភាគរយ ប៉ុន្តែទ្រង់ជាព្រះតែមួយទេ ។ យើងមិនអាចបែងចែកទ្រង់ជាផ្នែកបានឡើយ[២៨] ។ ព្រះវរបិតាមិនមានព្រះជន្មមកពីអង្គណាផ្សេងឡើយ ។ ព្រះរាជបុត្រាមានព្រះជន្មមកពីព្រះវរបិតា[២៩] ។ ព្រះវិញ្ញាណបរិសុទ្ធមកពីព្រះវរបិតា និងព្រះរាជបុត្រា[៣០] ។ អង្គទាំងបីនេះ ជាព្រះតែមួយប៉ុណ្ណោះដែលគង់នៅ

អស់កល្ប និងគ្មានព្រំខណ្ឌ ហើយយើងមិនគួរបែងចែកនិស្ស័យរបស់ទ្រង់ជាបីផ្នែកឡើយ ។ ព្រះទាំងបីអង្គបុគ្គលនេះបានបង្ហាញអោយឃើញពីលក្ខណៈខុសគ្នា តាមរបៀបដែលទ្រង់មានទំនាក់ទំនងគ្នា និងការងារផ្សេងៗដែលអង្គនិមួយៗធ្វើ ។ សេចក្តីបង្រៀននៃព្រះត្រៃឯកនេះគឺជាមូលដ្ឋានគ្រឹះ នៃគ្រប់ការប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់ និងសេចក្តីកំសាន្តចិត្តដែលយើងទទួល ដោយ ការដែលយើងពឹងផ្អែលើទ្រង់ ។

[២៧]១យ៉ូន ៥:៧; ម៉ាថ ២៨:១៩; ២កូ ១៣:១៤ ។ [២៨]និក្ខ ៣:១៤; យ៉ូន ១៤:១១; ១កូ ៨:៦ ។ [២៩]យ៉ូន ១:១៤, ១៨ ។ [៣០]យ៉ូន ១៥:២៦; កា ៤:៦ ។

# ជំពូក ៣
# រាជឱង្ការរបស់ព្រះ

១. ព្រះបានចេញព្រះរាជឱង្ការរបស់ទ្រង់តាំងពីអស់កល្បរៀងមក ហើយអ្វីៗគ្រប់យ៉ាង នឹងកើតឡើងនៅពេលដែលសមស្មួន[១] ហើយទ្រង់ធ្វើការនេះដោយសេរី និងដោយមិនមានការផ្លាស់ប្តូរអ្វីទាំងអស់ ។ ទ្រង់មិនបាច់ពិគ្រោះយោបល់ជាមួយអ្នកណាម្នាក់ឡើយ ។ ទ្រង់ធ្វើតាមតែប្រាជ្ញាញាណ និង ព្រះហឫទ័យរបស់ទ្រង់ប៉ុណ្ណោះ ។ ទោះបីជាទ្រង់បានចេញព្រះរាជឱង្ការ អោយអ្វីៗគ្រប់យ៉ាងបានកើតឡើងក៏ដោយ

ប៉ុន្តែទ្រង់មិនក្លាយជាអ្នកនិពន្ធអំពើបាបទេ ហើយ យើងក៏មិនអាចបន្ទោសព្រះ ថាទ្រង់មានបាបដែរ[២] ។ សេចក្តីបន្ទោសដោយព្រោះអំពើបាប គឺជារបស់អ្នកដែលធ្វើអាក្រក់ប៉ុណ្ណោះ ។ បន្ថែមពីនេះទៅទៀត នៅពេលដែលព្រះមានព្រះរាជឱង្ការ ទ្រង់មិនបំពានដល់ឆន្ទៈរបស់មនុស្សទេ ។ ព្រះរាជឱង្ការរបស់ព្រះគឺជាបុព្វហេតុទីមួយ ហើយវាធ្វើការជាមួយបុព្វហេតុបន្ទាប់បន្សំដែរ[៣] ។ នៅក្នុងរាល់ចំនុចខាងលើនេះ យើងអាចឃើញព្រះប្រាជ្ញាញាណ អំណាច ព្រះចេស្តា និងសេចក្តីស្មោះត្រង់របស់ព្រះ ដែលទ្រង់បានធ្វើគ្រប់ការទាំងអស់ តាមការដែលទ្រង់បានចេញព្រះរាជឱង្ការ[៤] ។

[១]អេសា ៤៦:១០; អេ ១:១១; ហេ ៦:១៧; រ៉ូម ៩:១៥, ១៨ ។ [២]យ៉ា ១:១៣; ១យ៉ូន ១:៥ ។ [៣]កិច្ច ៤:២៧, ២៨; យ៉ូន ១៩:១១ ។ [៤]ជន ២៣:១៩; អេ ១:៣-៥ ។

២. ព្រះមិនបានធ្វើអោយព្រះរាជឱង្ការរបស់ទ្រង់ មានមូលដ្ឋានផ្អែកទៅលើបុព្វញាណ ឬ ព្រះតំរិះរបស់ទ្រង់ដែលជ្រាបពីអនាគតនោះទេ[៥] ។ ព្រះរាជឱង្ការរបស់ទ្រង់ កើតឡើងមុនបុព្វញាណ ដូចនេះព្រះរាជឱង្ការរបស់ព្រះ គឺជាហេតុផលដែលអ្វីគ្រប់យ៉ាងបានកើតឡើង[៦] ។

[៥]កិច្ច ១៥:១៨ ។ [៦]រ៉ូម ៩:១១, ១៣, ១៦, ១៨ ។

៣. ព្រះរាជឱង្ការដែលទ្រង់បានបង្កើតឡើង គឺដើម្បីបង្ហាញពីសិរីរុងរឿងរបស់ទ្រង់ ។ ព្រះបានតំរូវទុកមនុស្សនិងពួកទេវតាខ្លះជាមុន ដើម្បី

អោយមានជីវិតអស់កល្បជានិច្ច តាមរយៈព្រះយេស៊ូវគ្រីស្ទ[៧] ដើម្បីអោយបានសរសើរដំកើងដល់ព្រះគុណដ៏អស្ចារ្យរបស់ទ្រង់[៨] ។ រីឯពួកអ្នកឯទៃទៀត ត្រូវទុកអោយវិនាសនៅក្នុងអំពើបាបរបស់ពួកគេ ដើម្បីទទួលការកាត់ទោសដ៏យុត្តិធម៌ ហើយនិងដើម្បីបង្ហាញពីភាពយុត្តិធម៌ដ៏អស្ចារ្យរបស់ទ្រង់[៩] ។

[៧]១ធី ៥:២១; ម៉ាថ ២៥:៣៤ ។ [៨]អេ ១:៥, ៦ ។ [៩]រ៉ូម ៩:២២, ២៣; យូ ៤ ។

៤. ដូច្នេះពួកទេវតា និងមនុស្សដែលព្រះបានតំរូវទុកជាមុនទាំងអស់នោះគឺសុទ្ធតែត្រូវបានរៀបចំឡើងជាពិសេស និងមិនអាចកែប្រែបាន ។ ពួកគេមានចំនួនជាក់លាក់ច្បាស់លាស់ និង បានកំណត់យ៉ាងត្រឹមត្រូវ ហើយមិនអាចបន្ថែមបន្ថយបានឡើយ[១០] ។

[១០] ២ធី ២:១៩; យ៉ូន ១៣:១៨ ។

៥. ព្រះបានជ្រើសរើសអស់អ្នកដែលបានតំរូវទុកជាមុន អោយមានជីវិត តាំងពីមុនកំណើតផែនដីមកម្ល៉េះ ទៅតាមគោលបំណងដ៏អស់កល្បជានិច្ច និងមិនចេះប្រែប្រួល និងដោយព្រះតំរិះដ៏អាថ៌កំបាំង និងការសព្វព្រះហឫទ័យរបស់ទ្រង់ ។ ព្រះជាម្ចាស់បានជ្រើសរើសពួកគេមក នៅក្នុងព្រះគ្រីស្ទ អោយមកឯសិរីរុងរឿងដ៏អស់កល្បជានិច្ច ដោយសារព្រះគុណ និងសេចក្តីស្រឡាញ់របស់ទ្រង់[១១] ទោះបីជាពួកគេមិនស័ក្តិសមអោយទ្រង់ជ្រើសរើសក៏ដោយ[១២] ។

[១១]អេ ១:៤, ៩, ១១; រ៉ូម ៨:៣០; ២ធី ១:៩; ១ថែស ៥:៩ ។ [១២]រ៉ូម ៩:១៣, ១៦; អេ ២:៥, ១២ ។

៦. ពិតមែនហើយ ព្រះបានតែងតាំង អ្នកដែលទ្រង់បានតំរូវទុកជាមុន អោយបានដំកើងឡើង ដោយគោលបំណងដ៏អស់កល្បនិងដ៏មានសេរីភាព នៃព្រះហឫទ័យរបស់ទ្រង់ ។ លើសពីនោះទៅទៀត ទ្រង់ក៏បានតាំងជាមុននូវគ្រប់មធ្យោបាយ ដើម្បីអោយគោលបំណងនេះនឹងបានកើតឡើងដែរ[១៣] ។ ដោយទ្រង់បានជ្រើសរើសពួកកូនចៅរបស់លោកអ័ដាម ដូចនេះហើយ ពួកគេដែលគួរត្រូវបានបំផ្លាញដោយសារការធ្លាក់ទៅក្នុងអំពើបាបរបស់លោកអ័ដាមនោះ ទ្រង់បានមានព្រះហឫទ័យ អោយពួកគេគួរទទួលបានការប្រោសលោះដោយសារព្រះគ្រីស្ទវិញ[១៤] ។ ពួកគេត្រូវបានត្រាស់ហៅមកយ៉ាងស័ក្តិសិទ្ធិ អោយមកក្នុងសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ ។ លើសពីនោះទៅទៀត ដោយព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅពេលដែលសមស្ទួន ពួកគេត្រូវបានរាប់ជាសុចរិត ជាកូនចិញ្ចឹម ជាបរិសុទ្ធ[១៥] ហើយ ត្រូវបានរក្សាដោយអំណាចរបស់ទ្រង់តាមរយៈសេចក្តីជំនឿ ដើម្បីអោយបានសេចក្តីសង្គ្រោះ[១៦] ។ ក្រៅពីពួកអ្នកដែលទ្រង់បានតំរូវទុកជាមុន នោះគ្មានអ្នកណាអាចនឹងទទួលការដ៏អស្ចារ្យនេះបានទេ[១៧] ។

[១៣]១ពេ ១:២; ២ថែស ២:១៣ ។ [១៤]១ថែស ៥:៩, ១០ ។ [១៥]រ៉ូម ៨:៣០; ២ថែស ២:១៣ ។ [១៦]១ពេ ១:៥ ។ [១៧]យ៉ូន ៦:៦៤; ១០:២៦; ១៧:៩ ។

៧. សេចក្តីបង្រៀននៃការតំរូវទុកជាមុន គឺជាសេចក្តីដ៏អាថិកំបាំង ដូច នេះ យើងត្រូវថែរក្សាដោយការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ជាពិសេស ចំពោះបំណងព្រះហឫទ័យរបស់ព្រះ ដែលបានបើកសំដែងក្នុងព្រះបន្ទូលរបស់ទ្រង់ ។ នៅពេលដែលគេកំពុងតែស្តាប់បង្គាប់ព្រះបន្ទូលនោះពួកគេនឹងដឹងយ៉ាងច្បាស់ថា ពួកគេជាអ្នកដែលព្រះបានជ្រើសរើសដ៏នៅអស់កល្បជានិច្ច តាមរយៈភាពជាក់លាក់នៃការត្រាស់ហៅដ៏ស័ក្តិសិទ្ធិ[១៨] ។ តាមមធ្យោបាយនេះ ការតំរូវទុកជាមុន នឹងកាន់តែបង្កើនអោយមានការសរសើរចំពោះព្រះ[១៩] ហើយនិង ការអស្ចារ្យដែលគួរកោតសរសើរស្ញប់ស្ញែងរបស់ទ្រង់ ។ ជាទីបញ្ចប់ ការតំរូវទុកជាមុន នឹងជំរុញអោយមានការបន្ទាបខ្លួន[២០] និងការព្យាយាម ។ មិនតែប៉ុណ្ណោះ ការតំរូវទុកជាមុន នាំអោយមានការកំសាន្តចិត្តដ៏ច្រើន ដល់អស់អ្នកដែលស្តាប់បង្គាប់តាមដំណឹងល្អ ដោយស្មោះត្រង់[២១] ។

[១៨]១ថែស ១:៤, ៥; ២ពេ ១:១០ ។ [១៩]អេ ១:៦; រ៉ូម ១១:៣៣ ។ [២០]រ៉ូម ១១:៥, ៦, ២០ ។ [២១]លូ ១០:២០ ។

# ជំពូក ៤
# ការបង្កើតរបស់ព្រះ

១. កាលដើមដំបូងឡើយ ការនេះបានគាប់ព្រះហឫទ័យដល់ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ[១] សំរាប់ការបង្ហាញពីសិរីល្អនៃព្រះចេស្តា[២] ប្រាជ្ញា និងសេចក្តីល្អដ៏អស់កល្បរបស់ទ្រង់ ក្នុងការបង្កើតលោកិយនេះ និងរបស់សព្វសារពើទាំងអស់ ទាំងមើលឃើញនិងមើលមិនឃើញក្នុងរវាង៦ថ្ងៃ ហើយអ្វីៗគ្រប់ទាំងអស់ល្អណាស់[៣] ។

[១]យ៉ូប ២៦:១៣; យ៉ូន ១:២, ៣; ហេ ១:២ ។ [២]រ៉ូម ១:២០ ។ [៣]លោក ១:៣១; កូល ១:១៦ ។

២. ក្រោយពីបានបង្កើតរបស់ទាំងអស់រួចមក ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងស្រី[៤] ហើយអោយពួកគេមានអំណាចលើរបស់សព្វសារពើទាំងអស់នៅលើផែនដីនេះ ។ ទ្រង់បានប្រទានអោយបុរសនិងស្ត្រីមានវិចារណញ្ញាណ និងវិញ្ញាណដែលមិនចេះស្លាប់[៥] ហើយគ្រប់ផ្នែកទាំងអស់អោយស័ក្តិសមទៅនឹងជីវិតរបស់ពួកគេ ដែលបានរស់នៅយ៉ាងសុខដុមរមនាជាមួយទ្រង់ ។ ព្រះទ្រង់បានបង្កើតពួកគេអោយដូចរូបអង្គទ្រង់ អោយមានចំណេះដឹង សេចក្តីសុចរិត និងភាពបរិសុទ្ធពិតប្រាកដ[៦] ហើយ រួមទាំងក្រិត្យវិន័យរបស់ព្រះជាម្ចាស់នៅក្នុងចិត្តរបស់គេគ្រប់គ្នា[៧] ព្រមទាំងអោយមានអំណាច ដើម្បីនឹងស្តាប់បង្គាប់ក្រិត្យវិន័យទាំងអស់នោះយ៉ាងពេញលេញទៀតផង ។ ប៉ុន្តែ ព្រះបាន

ប្រទានអោយពួកគេមានឆន្ទៈសេរី ដែលពួកគេអាចផ្លាស់ប្តូរឆន្ទៈរបស់ពួកគេបានតាមចិត្ត ដូច្នេះ ការរំលងលើក្រិត្យវិន័យ គឺជាលទ្ធភាពមួយដែលអាចកើតឡើងបាន[៨] ។

[៤]លោក ១:២៧ ។ [៥]លោក ២:៧ ។ [៦]លោក ១:២៦; សាស ៧:២៩ ។ [៧]រ៉ូម ២:១៤, ១៥ ។ [៨]លោក ៣:៦ ។

៣. ក្រៅពីក្រិត្យវិន័យដែលបានកត់ត្រាទុកក្នុងចិត្តគេហើយ នោះពួកគេក៏បានទទួលបញ្ញត្តិថា មិនអោយបរិភោគផ្លែពីដើមដឹងខុសត្រូវឡើយ[៩] ។ ក្នុងពេលដែលពួកគេបានរក្សាបញ្ញត្តិនេះបានត្រឹមត្រូវ នោះពួកគេក៏បានអរសប្បាយ ដោយបានរួមសហភាពជាមួយព្រះជាម្ចាស់ និងមានអំណាចគ្រប់គ្រងលើសត្វទាំងអស់[១០] ។

[៩]លោក ២:១៧ ។ [១០]លោក ១:២៦, ២៨ ។

# ជំពូក ៥
# ការទំនុកបំរុងរបស់ព្រះជាម្ចាស់

១. ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើទាំងអស់ ដោយអំណាច និងប្រាជ្ញាដ៏ឥតព្រំខណ្ឌរបស់ទ្រង់ ។ ដោយអង្គទ្រង់ផ្ទាល់ ទ្រង់បានរៀបចំរបស់ទាំងអស់ អោយមានសណ្តាប់ធ្នាប់ ហើយទ្រង់ក៏គ្រប់គ្រងលើគ្រប់របស់សព្វសារពើនោះ[១] តាំងពីរបស់ដែលធំបំផុត រហូតមកដល់របស់ដែលមិនសំខាន់សោះ[២] តាំងតែពីពេលដែលទ្រង់បានបង្កើតរបស់ទាំងអស់នោះមក ទៅតាមការទំនុកបំរុងដែលប្រកបដោយប្រាជ្ញាញាណ និងបរិសុទ្ធរបស់ទ្រង់ ។ ទ្រង់សំរេចនូវគោលបំណងដែលទ្រង់បានបង្កើតពួកគេមក ទៅតាមបុព្វញ្ញាណដែលមិនចេះខុស និងព្រះហឫទ័យដែលមានសេរីភាពពេញលេញហើយមិនចេះផ្លាស់ប្រែរបស់ទ្រង់ ដើម្បីសរសើរដំកើងដល់សិរីរុងរឿងនៃប្រាជ្ញា អំណាច សេចក្តីយុត្តិធម៌ សេចក្តីល្អដ៏គ្មានព្រំដែន និងសេចក្តីមេត្តាករុណារបស់ទ្រង់[៣] ។

[១]ហេ ១:៣; យ៉ូប ៣៨:១១; អេសា ៤៦:១០, ១១; ទំនុក ១៣៥:៦ ។ [២]ម៉ាថ ១០:២៩-៣១ ។ [៣]អេ ១:១១ ។

២. គ្មានអ្វីដែលកើតឡើងដោយចៃដន្យ (ឬដោយព្រេងសំណាង) ក្រៅពីការទំនុកបំរុងរបស់ព្រះឡើយ[៤] ។ ព្រះគឺជាបុព្វហេតុដំបូងដែលនាំអោយគ្រប់ព្រឹត្តិការណ៍ទាំងអស់បានកើតឡើង ដូច្នេះ ការទាំងអស់នេះមិនអាចផ្លាស់ប្តូរ ហើយខុសឆ្គងឡើយ[៥] ព្រោះពួកវាពាក់ព័ន្ធទៅនឹងព្រះ

រាជឱង្ការ និងបុព្វញាណរបស់ព្រះ ។ ប៉ុន្តែដោយការទំនុកបំរុងរបស់ទ្រង់ ទ្រង់ប្រើបុព្វហេតុទីពីរ ដើម្បីអោយគោលបំណងរបស់ទ្រង់កើតឡើង ដោយភាពចាំបាច់ ដោយសេរី ឬ ដោយផ្អែកទៅលើរបៀបផ្សេងៗ[៦] ។

[៤]សុ ១៦:៣៣ ។ [៥]កិច្ច ២:២៣ ។ [៦]លោក ៨:២២ ។

៣. ជាធម្មតា នៅក្នុងការទំនុកបំរុងរបស់ទ្រង់ ទ្រង់ប្រើមធ្យោបាយផ្សេងៗ[៧] ។ ប៉ុន្តែ ទ្រង់អាចមានសេរីភាព នឹងធ្វើការដោយគ្មានមធ្យោបាយទាំងនោះ[៨] ឬ ដោយសារអ្វីដែលលើសពីមធ្យោបាយទាំងនោះ[៩] ហើយជួនកាល ទ្រង់ក៏អាចធ្វើប្រឆាំងទៅនឹងមធ្យោបាយទាំងនោះក៏បានដែរ ស្រេចតែព្រះហឫទ័យទ្រង់ចង់ធ្វើ[១០] ។

[៧]កិច្ច ២៧:៣១, ៤៤; អេសា ៥៥:១០, ១១ ។ [៨]ហូ ១:៧ ។ [៩]រ៉ូម ៤:១៩-២១ ។ [១០]ដា ៣:២៧ ។

៤. អំណាចព្រះចេស្តាដ៏ខ្លាំងពូកែ និងប្រាជ្ញាដែលមិនអាចយល់ដល់ ព្រមទាំងសេចក្តីល្អដែលគ្មានព្រំខណ្ឌរបស់ព្រះ មានអំណាច និងមានឥទ្ធិពលខ្លាំងណាស់ សូម្បីតែការធ្លាក់ក្នុងអំពើបាបរបស់មនុស្សដំបូង ហើយនិងអំពើបាបផ្សេងៗរបស់ពួកទេវតា និងមនុស្ស[១១] សុទ្ធតែកើតឡើងតាមគោលបំណងរបស់ទ្រង់ទាំងអស់ ។ ការនេះ មិនមែនជាការអនុញ្ញាតអោយយើងធ្វើអ្វីមួយស្រេចតែចិត្តនោះទេ ប៉ុន្តែនៅក្នុងរបៀបជាច្រើន ទ្រង់បានដាក់កំរិត បង្អាប់ដល់ ហើយគ្រប់គ្រងអំពើបាបនានា[១២] ដោយប្រាជ្ញាញាណ និងដោយអំណាចព្រះចេស្តា ដើម្បីអោយ

ការអាក្រក់នេះកើតឡើង ទៅតាមគោលបំណងដ៏បរិសុទ្ធរបស់ទ្រង់វិញ[១៣] ។ ប៉ុន្តែ ភាពពោរពេញដោយអំពើបាប ដែលពាក់ព័ន្ធទៅនឹងសកម្មភាពអាក្រក់ទាំងនេះ សុទ្ធតែមកពីពួកទេវតា និងមនុស្សប៉ុណ្ណោះ មិនមែនមកពីព្រះទេ ។ ព្រះទ្រង់បរិសុទ្ធ និងសុចរិតបំផុត ហើយទ្រង់មិនអាចក្លាយជាមេបង្កើត ឬ អ្នកគាំទ្រនូវអំពើបាបឡើយ[១៤] ។

[១១]រ៉ូម ១១:៣២-៣៤; ២សាំ ២៤:១; ១របា ២១:១ ។ [១២] ២ពង្ស ១៩:២៨; ទំនុក ៧៦:១០ ។ [១៣]លោក ១:២០, ៥០:២០; អេសា ១០:៦, ៧, ១២ ។ [១៤]ទំនុក ១:២១; ១យ៉ូន ២:១៦ ។

៥. ព្រះជាម្ចាស់ដែលមានគ្រប់ទាំងប្រាជ្ញា សេចក្ដីសុចរិត និងព្រះគុណផងនោះ ជាញឹកញាប់ទ្រង់អោយកូនរបស់ទ្រង់ធ្លាក់ទៅក្នុងសេចក្ដីល្បួងផ្សេងៗ និងអោយពួកគេមានបទពិសោធន៍ អំពីភាពពោរពេញដោយអំពើបាបនៃចិត្តគំនិតរបស់ពួកគេ ។ ការដែលទ្រង់ធ្វើនេះ គឺដើម្បីដាក់វិន័យដល់ពួកគេ ដោយព្រោះ អំពើបាបដែលពួកគេបានប្រព្រឹត្ត ឬ ដើម្បីបង្រៀនពួកគេអំពីការបន្ទាបខ្លួន ដោយបង្ហាញដល់ពួកគេនូវអំណាចនៃសេចក្ដីអាក្រក់ និងសេចក្ដីបោកបញ្ឆោតដែលនៅជាប់ក្នុងចិត្តរបស់ពួកគេ ។ គោលបំណងរបស់ទ្រង់ ក៏ដើម្បីធ្វើអោយពួកគេភ្ញាក់ដឹងខ្លួនថា ពួកគេត្រូវការពឹងដល់ទ្រង់ទាំងស្រុង ហើយគ្រប់ពេលវេលាដើម្បីអោយទ្រង់ជួយការពារពួកគេ ដើម្បីប្រឆាំងនឹងអំពើបាបនៅពេលអនាគត ។ គោលបំណងដ៏យុត្តិធម៌និង បរិសុទ្ធរបស់ទ្រង់នេះ បានកើតឡើងតាមរបៀបនេះនិងតាមរបៀបផ្សេងៗទៀតដែរ[១៥] ដូច្នេះ គ្រប់ការ

ដែលកើតឡើង ចំពោះអ្នកដែលទ្រង់បានជ្រើសរើសនោះសុទ្ធតែជាការតាំងឡើងរបស់ទ្រង់ទាំងអស់ សំរាប់ជាសិរីល្អរបស់ទ្រង់ ហើយនិងសំរាប់ជាសេចក្ដីល្អរបស់ពួកគេ[១៦] ។

[១៥] ២របា ៣២:២៥, ២៦, ៣១; ២កូ ១២:៧-៩ ។ [១៦]រ៉ូម ៨:២៨ ។

៦. ព្រះទ្រង់ប្រព្រឹត្តិបែបផ្សេងចំពោះមនុស្សអាក្រក់ និងមនុស្សទមិឡល្មើស ពីព្រោះទ្រង់គឺជាចៅក្រមដ៏សុចរិត ។ ទ្រង់ប្រទានអោយគេនូវសេចក្ដីងងឹតងងល់ និងភាពរឹងត្អឹងនៃចិត្តរបស់ពួកគេ សំរាប់អំពើបាបរបស់ពួកគេ[១៧] ។ ព្រះក្ដាប់ព្រះគុណរបស់ទ្រង់ជាប់ ដើម្បីមិនអោយពួកគេអាចនឹងបើកចិត្តគំនិតរបស់ពួកគេបាន[១៨] ហើយជួនកាល ទ្រង់ដកយកនូវអំណោយទាន ដែលទ្រង់បានប្រទានពរដល់គេ មកវិញ[១៩] ។ ទ្រង់ក៏ដាក់ពួកគេទៅក្នុងស្ថានភាពនានា ដែលចិត្តអាក្រក់របស់ពួកគេប្រើជាឱកាសសំរាប់អំពើបាប[២០] ឬយើងអាចនិយាយបានថា ទ្រង់បោះបង់ចោលពួកគេទៅក្នុងសេចក្ដីពុករលួយរបស់ពួកគេ ហើយ ទៅក្នុងការល្បួងរបស់លោកិយ ព្រមទាំងទៅក្នុងអំណាចរបស់សាតាំងផង[២១] ។ លទ្ធផលរបស់វា គឺពួកគេបានមានចិត្តរឹងរូសដោយខ្លួនឯង ។ តាមរបៀបដូចគ្នានេះ ព្រះបានធ្វើអោយអ្នកដទៃទៀតមានចិត្តទន់វិញ[២២] ។

[១៧]រ៉ូម ១:២៤-២៦, ២៨; ១១:៧, ៨ ។ [១៨]ចោទិ ២៩:៤ ។ [១៩]ម៉ាថ ១៣:១២ ។ [២០]ចោទិ ២:៣០; ២ពង្ស ៨:១២, ១៣ ។ [២១]ទំនុក ៨១:១១, ១២; ២ថែស ២:១០-១២ ។ [២២]និក្ខ ៨:១៥, ៣២; អេសា ៦:៩, ១០; ១ពេ ២:៧, ៨ ។

៧. ការទំនុកបំរុងទូទៅរបស់ព្រះ គឺសំរាប់អ្វីៗទាំងអស់ ប៉ុន្តែជារបៀបពិសេសមួយ ការទំនុកបំរុងរបស់ទ្រង់ គឺដើម្បីថែរក្សាពួកជំនុំរបស់ទ្រង់ ។ រាល់កិច្ចការទាំងអស់ដែលបានគ្រប់គ្រងដោយការទំនុកបំរុងរបស់ទ្រង់ គឺដើម្បីសេចក្តីល្អរបស់ពួកជំនុំរបស់ទ្រង់[២៣] ។

[២៣]១ធី ៤:១០; អេម ៩:៨, ៩; អេសា ៤៣:៣-៥ ។

# ជំពូក ៦
# ការធ្លាក់ចុះរបស់មនុស្ស អំពើបាប និង ទណ្ឌកម្ម

១. ព្រះជាម្ចាស់បានបង្កើតមនុស្សមកអោយសុចរិត និងឥតខ្ចោះ ហើយព្រមទាំងបានប្រទានច្បាប់ដ៏សុចរិតដល់គេ ដើម្បីថែរក្សាការពារជីវិតរបស់គេក្នុងពេលដែលគេស្តាប់បង្គាប់ ប៉ុន្តែព្រះជាម្ចាស់បានគំរាមដល់គេថា គេនឹងត្រូវស្លាប់ ប្រសិនបើគេមិនស្តាប់បង្គាប់តាម[១] ។ ការស្តាប់បង្គាប់របស់លោកអ័ដាម មិនបានយូរទេ ។ អារក្សសាតាំងប្រើល្បិចដោយប្រើសត្វពស់ដែលមានល្បិចកល អោយអូសទាញនាងអេវ៉ាអោយធ្លាក់ទៅក្នុងអំពើបាប ។ បន្ទាប់មកនាងនាំលោកអ័ដាមអោយវង្វេងដែរ ពួកគេទាំងពីរបានល្មើសនឹងច្បាប់ ដោយស្ម័គ្រពីចិត្ត គ្មាននរណាបង្ខិតបង្ខំអ្វីទាំងអស់ គឺពួកគេល្មើសនឹងការបង្គាប់របស់ព្រះថា

មិនអោយបរិភោគផ្លែពីដើមឈើនោះ[២] ដោយខ្លួនឯង ។ ដោយយោង ទៅលើប្រាជ្ញា និងព្រះដំរិះ ដ៏បរិសុទ្ធរបស់ទ្រង់ ការកើតឡើងនេះ គឺព្រះជាម្ចាស់ទ្រង់បានសព្វព្រះហឫទ័យ អោយកើតឡើង ទៅតាមផែនការសំរាប់សិរីល្អរបស់ទ្រង់ផ្ទាល់ ។

[១]លោក ២:១៦, ១៧ ។ [២]លោក ៣:១២, ១៣; ២កូ ១១:៣ ។

២. ដោយព្រោះអំពើបាបនេះ ឪពុកម្តាយដើមដំបូងរបស់យើង បានដាច់ចេញពីសេចក្តីសុចរិតដែលមានពីអតីតកាល ហើយ ការរួមសហភាពជាមួយនឹងព្រះ ក៏បានបាក់បែកដែរ ។ ដោយព្រោះបាបនេះ អំពើបាបបានឆ្លងរាលដាលដល់យើងគ្រប់គ្នា ហើយគ្រប់គ្នាបានទទួលសេចក្តីស្លាប់ដែរ[៣] ។ មនុស្សទាំងអស់គ្នាបានត្រឡប់ទៅជាស្លាប់នៅក្នុងអំពើបាប[៤] ហើយបានធ្វើអោយខូចគ្រប់ផ្នែកទាំងអស់នៃព្រលឹង និងរូបកាយ[៥] ។

[៣]រ៉ូម ៣:២៣ ។ [៤]រ៉ូម ៥:១២ ។ [៥]ទីត ១:១៥; លោក ៦:៥; យេ ១៧:៩; រ៉ូម ៣:១០-១៩ ។

៣. គ្រួសាររបស់មនុស្ស គឺមានឫសគល់ពីមនុស្សពីរនាក់ដំបូង ។ លោកអ័ដាម និងនាងអេវ៉ាបានតំណាងអោយមនុស្សជាតិទាំងអស់ ហើយព្រះទ្រង់ក៏រាប់ទោសនៃអំពើបាបនោះ ដល់ពួកកូនចៅជំនាន់ក្រោយទាំងអស់របស់ពួកគេដែរ[៦] ។ ពួកកូនចៅទាំងនោះក៏បានទទួលនិស្ស័យពុករលួយតាំងពីកំណើតរបស់ពួកគេមក[៧] ដូច្នេះ ពួកកូនចៅរបស់ពួកគេ

ច្បាស់ជាត្រូវធ្លាក់ទៅក្នុងអំពើបាប ហើយក្លាយជាកូននៃសេចក្តីក្រោធ[៨] ជាអ្នកបំរើអំពើបាប ជាអ្នកដែលសេចក្តីស្លាប់បានគ្រប់គ្រង[៩] និងជាអ្នកដែលមានសេចក្តីវេទនាខាងឯព្រលឹងវិញ្ញាណនៅពេលបច្ចុប្បន្ននេះ និងនៅអស់កល្បជានិច្ចជាមិនខាន ប្រសិនបើព្រះអម្ចាស់យេស៊ូវគ្រីស្ទ មិនបានប្រោសលោះពួកគេអោយរួចចេញពីការទាំងអស់នោះ[១០] ។

[៦]រ៉ូម ៥:១២-១៩; ១កូ ១៥:២១, ២២, ៤៥, ៤៩ ។ [៧]ទំនុក ៥១:៥; យ៉ូប ១៤:៤ ។ [៨]អេ ២:៣ ។ [៩]រ៉ូម ៦:២០; ៥:១២ ។ [១០]ហេ ២:១៤, ១៥; ១ថែស ១:១០ ។

៤. អំពើបាបដែលមនុស្សបានប្រព្រឹត្ត គឺជាផលផ្លែនៃនិស្ស័យពុករលួយដែលបានឆ្លងរាលដាលមកពួកគេ តាមរយ:ឪពុកម្តាយដំបូងរបស់ពួកគេ (លោក អ័ដាម និងនាងអេវ៉ា)[១១] ។ ដោយព្រោះនិស្ស័យពុករលួយនេះ មនុស្សទាំងអស់មានទំនោរចិត្តចង់ធ្វើតែការអាក្រក់ ។ អំពើបាបបានធ្វើអោយពួកគេស្ទើរតែមិនអាចធ្វើល្អបាន ។ ពួកគេមានភាពផ្ទុយទាំងស្រុងទៅនឹងអ្វីៗដែលល្អ[១២] ។

[១១]យ៉ា ១:១៤, ១៥; ម៉ាថ ១៥:១៩ ។ [១២]រ៉ូម ៨:៧; កូល ១:២១ ។

៥. កំឡុងជីវិតនៅផែនដីនេះ និស្ស័យពុករលួយនៅតែបន្សល់ទុកដល់អស់អ្នកដែលកើតមកពីព្រះ គឺអ្នកដែលកើតជាថ្មី[១៣] ។ ជាការពិតណាស់ តាមរយ:ព្រះគ្រីស្ទ អំពើបាបត្រូវបានអត់ទោសអោយ និងត្រូវបានផ្ចាញ់

ប៉ុន្តែនិស្ស័យពុករលួយ ហើយនិងគ្រប់ទាំងបញ្ហាដែលមកពីនិស្ស័យពុករលួយនោះ នៅតែជាអំពើបាបដដែល[១៤] ។

[១៣]រ៉ូម ៧:១៨, ២៣; សាស ៧:២០; ១យ៉ូន ១:៨ ។ [១៤]រ៉ូម ៧:២៣-២៥; កា ៥:១៧ ។

# ជំពូក ៧
# សេចក្តីសញ្ញារបស់ព្រះជាម្ចាស់

១ មនុស្សត្រូវបានបង្កើត អោយមានសមត្ថភាពក្នុងការគិតពិចារណា ហើយពួកគេដឹងថា ពួកគេគួរស្តាប់បង្គាប់ដល់ទ្រង់ដែលជាព្រះអាទិកររបស់ពួកគេ ។ ប៉ុន្តែគំលាតរវាងព្រះជាម្ចាស់ និងមនុស្សឆ្ងាយពីគ្នាខ្លាំងណាស់ ដូច្នេះពួកគេមិនអាចនឹងទទួលជីវិតជារង្វាន់បានឡើយ ។ អញ្ចឹងហើយ បានជាព្រះបានយាងចុះមកដោយស្ម័គ្រព្រះទ័យ ដើម្បីធ្វើអោយការនេះកើតឡើងបាន ដោយតាំងសញ្ញាជាមួយនឹងពួកគេ[១] ។

[១]លូ ១៧:១០; យ៉ូប ៣៥:៧, ៨ ។

២. លើសពីនេះទៅទៀត មនុស្សបានបណ្តោយខ្លួនឯងអោយធ្លាក់ទៅក្នុងបណ្តាសានៃក្រិត្យវិន័យ ដោយអំពើបាបរបស់ខ្លួន ។ ព្រះទ្រង់ក៏សព្វព្រះហឫទ័យប្រទានសេចក្តីសញ្ញានៃព្រះគុណដល់ពួកគេ[២] ។ សេចក្តីសញ្ញានេះ ទ្រង់ប្រទានអោយដោយឥតគិតថ្លៃដល់មនុស្សមានបាប គឺជា

ជីវិត និងសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ តែទ្រង់តម្រូវអោយពួកគេជឿដល់ទ្រង់ ដើម្បីអោយបានទទួលនូវជីវិត និងសេចក្តីសង្គ្រោះនោះ[៣] ។ ហើយទ្រង់ក៏បានសន្យាថា នឹងប្រទានព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដល់អស់អ្នកដែលទ្រង់បានជ្រើសរើស អោយមានជីវិតអស់កល្បជានិច្ច ដើម្បីអោយពួកគេអាចនឹងជឿដល់ទ្រង់ដោយស្ម័គ្រពីចិត្តបាន[៤] ។

[២]លោក ២:១៧; កា ៣:១០; រ៉ូម ៣:២០, ២១ ។ [៣]រ៉ូម ៨:៣; ម៉ាក ១៦:១៥, ១៦; យ៉ូន ៣:១៦ ។ [៤]អេសេ ៣៦:២៦, ២៧; យ៉ូន ៦:៤៤, ៤៥; ទំនុក ១១០:៣ ។

៣. សេចក្តីសញ្ញានេះ ត្រូវបានបើកសំដែងនៅក្នុងដំណឹងល្អ ។ ជាដំបូងបានបើកសំដែងអោយអ័ដាម ដោយការសន្យាអំពីសេចក្តីសង្គ្រោះតាមរយៈពូជរបស់ស្ត្រី[៥] ហើយក្រោយមក បានបើកសំដែងមួយជំហានម្តងៗ រហូតមកដល់ការបើកសំដែងពេញលេញនៃសេចក្តីសង្គ្រោះនោះបានចប់សព្វគ្រប់ក្នុងព្រះគម្ពីរសញ្ញាថ្មី[៦] ។ សេចក្តីសង្គ្រោះនៃអ្នកដែលបានជ្រើសរើស គឺអាស្រ័យទៅលើសេចក្តីសញ្ញានៃការប្រោសលោះដែលបានសំរេចដោយអស់កល្បរវាងព្រះវរបិតា និងព្រះរាជបុត្រា[៧] ។ ដោយសារតែបានព្រះគុណនៃសេចក្តីសញ្ញានេះប៉ុណ្ណោះ ទើបកូនចៅរបស់អ័ដាមដែលបានដួលចុះទាំងអស់នោះ បានទទួលការសង្គ្រោះជីវិត និងព្រះពរនៃការដែលមិនចេះស្លាប់ ។ លក្ខខណ្ឌនៃការប្រទានពរដល់

លោកអ័ដាមមាននៅពេលដែលគាត់ពុំទាន់បានធ្វើខុសនោះ មិនអាចប្រើដើម្បីអោយព្រះទទួលស្គាល់កូនចៅរបស់គាត់បានឡើយ[៨] ។

[៥]លោក ៣:១៥ ។ [៦]ហេ ១:១ ។ [៧] ២ធី ១:៩; ទីត ១:២ ។ [៨]ហេ ១១:៦, ១៣; រ៉ូម ៤:១-៥; កិច្ច ៤:១២; យ៉ូន ៨:៥៦ ។

# ជំពូក ៨
# ព្រះគ្រីស្ទជាអ្នកបង្រួបបង្រួម

១. ក្នុងគោលបំណងរបស់ព្រះជាម្ចាស់ ទ្រង់សព្វព្រះហឫទ័យជ្រើសរើស និងតាំងព្រះអម្ចាស់យេស៊ូវ ជាព្រះរាជបុត្រាតែមួយរបស់ទ្រង់ ដោយអនុលោមទៅតាមសេចក្តីសញ្ញាដែលបានធ្វើឡើងរវាងព្រះជាម្ចាស់ និងព្រះអម្ចាស់យេស៊ូវ ដោយអោយព្រះយេស៊ូវធ្វើជាអ្នកបង្រួបបង្រួមរវាងព្រះ និងមនុស្ស[១] ជាហោរា[២] ជាសង្ឃ[៣] ជាស្តេច[៤] ជាសិរសារ និងជាព្រះអង្គសង្គ្រោះនៃពួកជំនុំរបស់ទ្រង់[៥] ។ មិនតែប៉ុណ្ណោះ ទ្រង់ក៏ជាអ្នកគ្រងមរតកនៃគ្រប់របស់ទាំងអស់[៦] ហើយ ជាចៅក្រមនៃលោកិយទាំងមូល[៧] ។ តាំងពីអស់កល្បរៀងមក ព្រះជាម្ចាស់បានប្រទានមនុស្សជាតិមួយចំនួនដល់បុត្រារបស់ព្រះអង្គ ដើម្បីអោយធ្វើជាពូជរបស់ព្រះរាជបុត្រានោះ ហើយនៅពេលដែលសមស្មួន ព្រះអម្ចាស់

យេស៊ូវនឹងប្រោសលោះ ត្រាស់ហៅ រាប់ជាសុចរិត ញែកជាបរិសុទ្ធ និងដំកើងពួកគេឡើង[៨] ។

[១]អេសា ៤២:១; ១ពេ ១:១៩, ២០ ។ [២]កិច្ច ៣:២២ ។ [៣]ហេ ៥:៥, ៦ ។ [៤]ទំនុក ២:៦; លូ ១:៣៣ ។ [៥]អេ ១:២២, ២៣ ។ [៦]ហេ ១:២ ។ [៧]កិច្ច ១៧:៣១ ។ [៨]អេសា ៥៣:១០; យ៉ូន ១៧:៦; រ៉ូម ៨:៣០ ។

២. ព្រះរាជបុត្រានៃព្រះ ដែលទ្រង់ជាអង្គទីពីរនៅក្នុងព្រះត្រៃឯកបរិសុទ្ធ ហើយទ្រង់ជាព្រះដ៏អស់កល្ប និងជាព្រះដ៏ពិត ។ ទ្រង់ក៏ជារស្មីដ៏ត្រចះត្រចង់នៃសិរីល្អរបស់ព្រះវរបិតា ហើយទ្រង់ស្មើគ្នានឹងព្រះវរបិតា ។ ពិភពលោកនេះបានកើតឡើងដោយសារទ្រង់ ហើយទ្រង់ក៏ទ្រទ្រង់ និងគ្រប់គ្រងរបស់ទាំងអស់ដែលទ្រង់បានបង្កើតមកនោះដែរ ។ នៅពេលវេលាកំណត់បានមកដល់ ទ្រង់បានយកនិស្ស័យជាមនុស្សធម្មតា ទាំងមានលក្ខណៈនិងសេចក្តីកំសោយគ្រប់យ៉ាងដូចជាមនុស្សដែរ[៩] តែទ្រង់មិនមានបាបដូចមនុស្សទេ[១០] ។ ទ្រង់បានយកកំណើត ដោយព្រះវិញ្ញាណបរិសុទ្ធ បានចាប់ទំផ្ទៃរបស់នាងព្រហ្មចារិនីម៉ារា ។ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើនាង គឺព្រះចេស្តានៃព្រះដ៏ខ្ពស់បំផុតបានមកគ្របបាំងនាងដោយស្រមោល ។ ដូច្នេះទ្រង់បានប្រសូតមកជាកូនរបស់ស្ត្រីម្នាក់នៃពួកកុលសម្ព័ន្ធយូដា ដែលជាវង្សានុវង្សរបស់លោកអ័ប្រាហាំនិងដាវីឌ ដោយយោងតាមព្រះគម្ពីរ[១១] ។ ដូចនេះ និស្ស័យពីរដ៏គ្រប់លក្ខណ៍ហើយផ្សេងគ្នានេះ គឺជានិស្ស័យមនុស្ស និងជានិស្ស័យព្រះបានរួមមកតែមួយក្នុងអង្គបុគ្គលតែមួយទាំងស្រុង ។ ប៉ុន្តែនិស្ស័យទាំង

ពីរនេះរួមគ្នា មិនធ្វើអោយនិស្ស័យណាមួយក្នុងចំណោមនិស្ស័យទាំងពីរនេះប្រែប្រួល លាយឡំ ឬ ច្របូកច្របល់ចូលគ្នាឡើយ ។ ដូច្នេះព្រះរាជបុត្រានៃព្រះ គឺជាព្រះដ៏ពិតប្រាកដ ហើយក៏ជាមនុស្សដ៏ពិតប្រាកដដែរ ។ ប៉ុន្តែទ្រង់ជាព្រះគ្រីស្ទតែមួយប៉ុណ្ណោះ ដែលទ្រង់ជាអ្នកបង្រួបបង្រួមតែមួយ រវាងព្រះជាម្ចាស់ និងមនុស្ស[១២] ។

[៩]យ៉ូន ១:១៤; កា ៤:៤ ។ [១០]រ៉ូម ៨:៣; ហេ ២:១៤, ១៦, ១៧; ៤:១៥ ។ [១១]ម៉ាថ ១:២២, ២៣; លូ ១:២៧, ៣១, ៣៥ ។ [១២]រ៉ូម ៩:៥; ១ធី ២:៥ ។

៣. និស្ស័យទាំងពីរនេះគឺ និស្ស័យព្រះ និងនិស្ស័យមនុស្ស បានរួមគ្នានៅក្នុងតួអង្គព្រះរាជបុត្រា ដែលព្រះជាម្ចាស់បានញែកជាបរិសុទ្ធ និងបានចាក់ប្រេងតាំងអោយ ដោយព្រះវិញ្ញាណបរិសុទ្ធដែលគ្មានកំរិត[១៣] ។ នៅក្នុងទ្រង់ មានគ្រប់ទាំងគុណលក្ខណៈនៃប្រាជ្ញា និងចំណេះដឹង[១៤] ។ ទ្រង់មានពោរពេញទៅដោយ អ្វីៗដែលធ្វើអោយគាប់ដល់ព្រះហឫទ័យព្រះវរបិតា[១៥] ដូចជាទ្រង់បរិសុទ្ធ គ្មានគ្រោះថ្នាក់ គ្មានសៅហ្មងដោយអំពើបាប[១៦] ហើយទ្រង់ពេញដោយព្រះគុណ និងសេចក្តីពិត[១៧] ។ ដូច្នេះទ្រង់មានលក្ខណៈសម្បត្តិពិតប្រាកដសំរាប់មុខតំណែង ជាអ្នកបង្រួបបង្រួម និង ជាអ្នកធានា[១៨] ។ ទ្រង់មិនបានសំរេចព្រះហឫទ័យធ្វើការងារនេះដោយអង្គទ្រង់ផ្ទាល់នោះទេ ប៉ុន្តែគឺព្រះវរបិតាវិញ[១៩] ដែលបានហៅទ្រង់មកបំពេញភារកិច្ចនេះ ។ មិនតែប៉ុណ្ណោះ ព្រះវរបិតាក៏បានប្រទានគ្រប់ទាំងអំណាច ការជំនុំជំរះ និងព្រះរាជបញ្ជារបស់ទ្រង់ដល់ព្រះយេស៊ូវ ដើម្បីអោយអនុវត្តតាមផងដែរ[២០] ។

[១៣]ទំនុក ៨៥:៧; កិច្ច ១០:៣៨ ; យ៉ូន ៣:៣៤ ។ [១៤]កូល ២:៣ ។ [១៥]កូល ១:១៩ ។ [១៦]ហេ ៧:២៦ ។ [១៧]យ៉ូន ១:១៤ ។ [១៨]ហេ ៧:២២ ។ [១៩]ហេ ៥:៥; [២០]យ៉ូន ៥:២២ ,២៧; ម៉ាថ ២៨:១៨; កិច្ច ២:៣៦ ។

៤. ព្រះអម្ចាស់យេស៊ូវបានទទួលការងារ ជាអ្នកបង្រួបបង្រួម ដោយស្ម័គ្រព្រះហឫទ័យ[២១] ដើម្បីបំពេញព្រះបរមភារកិច្ចនេះ គឺទ្រង់ត្រូវធ្វើតាមក្រិត្យវិន័យរបស់ព្រះ[២២] ហើយក៏ត្រូវធ្វើវាអោយបានសំរេច ដោយគ្រប់លក្ខណ៍ផងដែរ ។ ទ្រង់ក៏ត្រូវរងទណ្ឌកម្មសំរាប់យើង ជាទណ្ឌកម្មដែលយើងរាល់គ្នាគួរទទួល[២៣] ។ ទ្រង់បានត្រឡប់ទៅជាតួបាប ហើយបានទទួលបណ្តាសាជំនួសយើង[២៤] ។ ទ្រង់ទ្រាំទ្រការរងទុក្ខដ៏វេទនានៅក្នុងព្រលឹងរបស់ទ្រង់ រួមទាំងការឈឺចាប់ដ៏ឥតគណនានៅក្នុងរូបកាយរបស់ទ្រង់ផង[២៥] ។ ទ្រង់ត្រូវគេយកទៅឆ្កាង ហើយទ្រង់បានសុគត ។ ពេលនោះទ្រង់ពិតជាសុគតមែន ប៉ុន្តែរូបកាយរបស់ទ្រង់មិនបានស្អុយរលួយទេ[២៦] ។ នៅថ្ងៃទីបី ទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ[២៧] ជាមួយនឹងរូបកាយដដែល ដែលបានទទួលការឈឺចាប់កាលពីមុន[២៨] ។ ហើយជាមួយរូបកាយដដែលនោះទៀត ទ្រង់ក៏បានយាងទៅឯនគរស្ថានសួគ៌វិញ[២៩] ព្រមទាំងគង់នៅខាងស្តាំនៃព្រះវរបិតា ធ្វើជាអ្នកអង្វរជំនួសយើង[៣០] ហើយ ទ្រង់នឹងត្រឡប់មកវិញជាថ្មីម្តងទៀត នៅថ្ងៃចុងបំផុតនៃផែនដីនេះ ដើម្បីនឹងជំនុំជំរះទោសរបស់មនុស្ស និងពួកទេវតាទាំងអស់ផង[៣១] ។

[២១]ទំនុក ៨០:៧, ៨; ហេ ១០:៥-១០; យ៉ូន ១០:១៨ ។ [២២]កា ៤:៤; ម៉ាថ ៣:១៥ ។ [២៣]កា ៣:១៣; អេសា ៥៣:៦; ១ពេ ៣:១៨ ។ [២៤] ២កូ ៥:២១ ។ [២៥]ម៉ាថ ២៦:៣៧, ៣៨; លូ ២២:៤៤; ម៉ាថ ២៧:៤៦ ។ [២៦]កិច្ច ១៣:៣៧ ។ [២៧]១កូ ១៥:៣, ៤ ។ [២៨]យ៉ូន ២០:២៥, ២៧ ។ [២៩]ម៉ាក ១៦:១៩; កិច្ច ១:៩-១១ ។ [៣០]រ៉ូម ៨:៣៤; ហេ ៩:២៤ ។ [៣១]កិច្ច ១០:៤២; រ៉ូម ១៤:៩, ១០; កិច្ច ១:១១; ២ពេ ២:៤ ។

៥. ការស្តាប់បង្គាប់ និងយញ្ញបូជាដ៏គ្រប់លក្ខណ៍ដែលព្រះយេស៊ូវបានថ្វាយដល់ព្រះជាម្ចាស់តាមរយៈព្រះវិញ្ញាណដ៏អស់កល្ប ទ្រង់បានធ្វើអោយមានការស្កប់ព្រះទ័យនៃសេចក្តីយុត្តិធម៌ របស់ព្រះជាម្ចាស់[៣២] ។ ព្រះយេស៊ូវបាននាំមកនូវការផ្សះផ្សា និងទិញមរតកដ៏អស់កល្បជានិច្ចមួយនៅក្នុងនគរស្ថានសួគ៌ ដើម្បីនឹងប្រគល់អោយអស់អ្នកណាដែលព្រះវរបិតាបានប្រទានដល់ទ្រង់[៣៣] ។

[៣២]ហេ ៩:១៤; ១០:១៤; រ៉ូម ៣:២៥, ២៦ ។ [៣៣]យ៉ូន ១៧:២; ហេ ៩:១៥ ។

៦. ទោះបីជា ថ្លៃនៃការប្រោសលោះមិនទាន់បានសងមុនពេល ដែលព្រះយេស៊ូវបានយកកំណើតនៅលើផែនដីនេះក៏ដោយ ប៉ុន្តែ តំលៃប្រសិទ្ធភាព និង អត្ថប្រយោជន៍នានានៃការប្រោសលោះរបស់ទ្រង់នោះបានមានទំនាក់ទំនងជាមួយនឹងអ្នកដែលទ្រង់បានជ្រើសរើស នៅគ្រប់ជំនាន់ទាំងអស់ គឺតាំងពីដើមកំណើតនៃផែនដីមក ។ តាមរយៈព្រះបន្ទូលសន្យារបស់ទ្រង់ គំរូ និងយញ្ញបូជានានា បានបង្ហាញអោយឃើញថា

ទ្រង់ជាពូជរបស់ស្ត្រី “កូនចៅ” ដែលត្រូវកិនក្បាលពស់ “អារក្ស សាតាំង”[៣៤] ហើយកូនចៀមក៏ត្រូវបានសំឡាប់តាំងពីកំណើតផែនដីនេះ មកដែរ[៣៥] ។ ម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតទៅ ព្រះជាម្ចាស់ទ្រង់ នៅតែដដែល[៣៦] ។

[៣៤]១កូ ៤:១០; ហេ ៤:២; ១ពេ ១:១០, ១១ ។ [៣៥]វិវ ១៣:៨ ។ [៣៦]ហេ ១៣:៨ ។

៧. នៅក្នុងការងារជាអ្នកបង្រួបបង្រួមរវាងព្រះ និងមនុស្សរបស់ទ្រង់ ព្រះគ្រីស្ទបានធ្វើការទៅតាមនិស្ស័យទាំងពីររបស់ទ្រង់ ។ និស្ស័យជាព្រះ និងនិស្ស័យជាមនុស្សរបស់ទ្រង់ ធ្វើការតាមភាពត្រឹមត្រូវរបស់និស្ស័យ នីមួយៗនោះឯង ។ ប៉ុន្តែ ដោយព្រះគ្រីស្ទជាអង្គបុគ្គលតែមួយ ដូច្នេះ ជួនកាលអ្វីដែលជាលក្ខណ:របស់និស្ស័យមួយ អាចបង្ហាញអោយ ឃើញ នៅក្នុងនិស្ស័យមួយផ្សេងទៀតដែរ[៣៧] ។

[៣៧]យ៉ូន ៣:១៣; កិច្ច ២០:២៨ ។

៨. អស់អ្នកណាដែលព្រះយេស៊ូវបានប្រោសលោះ ទ្រង់បានប្រើការ ប្រោសលោះនោះសំរាប់ជាប្រយោជន៍ និងភ្ជាប់ទំនាក់ទំនងជាមួយពួក គេដែរ ។ ទ្រង់ទូលអង្វរជំនួស[៣៨] និងបង្រួបបង្រួមពួកគេមកតែមួយ ដោយព្រះវិញ្ញាណរបស់ទ្រង់ ហើយទ្រង់នឹងបើកសំដែងអាថ៌កំបាំងនៃ សេចក្តីសង្គ្រោះដល់ពួកគេ តាមរយៈព្រះបន្ទូលរបស់ទ្រង់ ។ ទ្រង់ដឹកនាំ ពួកគេអោយបានជឿ និងស្តាប់បង្គាប់[៣៩] ហើយទ្រង់គ្រប់គ្រងលើចិត្ត

របស់ពួកគេ ដោយព្រះបន្ទូលនិងព្រះវិញ្ញាណរបស់ទ្រង់ដែរ[៩០] ។ ទ្រង់បានយកឈ្នះលើខ្មាំងសត្រូវរបស់ពួកគេទាំងអស់ ដោយអំណាចព្រះចេស្តាដ៏ខ្លាំងពូកែ និងប្រាជ្ញាដ៏ឧត្តមរបស់ទ្រង់[៩១] ។ គ្រប់ការទាំងអស់នេះ ទ្រង់បានប្រើវិធីដែលមានភាពចុះសំរុងគ្នាជាមួយទ្រង់ សំរាប់ការតាំងឡើងដ៏អស្ចារ្យ និងយល់មិនដល់នៃការទំនុកបំរុងរបស់ទ្រង់ ។ ការទាំងអស់នេះបានសំរេចឡើងតាមរយៈមហាព្រះគុណដ៏មានសេរីភាពរបស់ទ្រង់ ព្រោះគ្មានលក្ខខណ្ឌណាដែលមនុស្សអាចនឹងធ្វើ ដើម្បីអោយបានទទួលការទាំងអស់នោះបានទេ[៩២] ។

[៣៨]យ៉ូន ៦:៣៧; ១០:១៥, ១៦; ១៧:៩; រ៉ូម ៥:១០ ។ [៣៩]យ៉ូន ១៧:៦; អេ ១:៩; ១យ៉ូន ៥:២០ ។ [៩០]រ៉ូម ៨:៩, ១៤ ។ [៩១]ទំនុក ១១០:១; ១កូ ១៥:២៥, ២៦ ។ [៩២]យ៉ូន ៣:៨; អេ ១:៨ ។

៩. តំណែងធ្វើជាអ្នកបង្រួបបង្រួមរវាងព្រះជាម្ចាស់និងមនុស្ស គឺមានតែព្រះគ្រីស្ទប៉ុណ្ណោះ ដែលស័ក្តិសមចំពោះតំណែងនេះ ដែលទ្រង់គឺជាហោរា ជាសំដេចសង្ឃ និងជាមហាក្សត្រនៃពួកជំនុំរបស់ព្រះទាំងអស់ ។ ហើយតំណែងនេះមិនអាចនឹងផ្ទេរពីព្រះគ្រីស្ទ ទៅអោយអ្នកណាម្នាក់ទៀតបានឡើយ សូម្បីតែបន្តិចបន្តួចក៏ដោយ[៩៣] ។

[៩៣]១ធី ២:៥ ។

១០. មុខដំណែងទាំងបីរបស់ព្រះគ្រីស្ទ ពិតជាចាំបាច់ណាស់សំរាប់យើង ។ ព្រោះថា យើងល្ងង់ខ្លៅ យើងត្រូវការទ្រង់ដើម្បីអោយធ្វើជា

ហោរា[៩៤] ។ ដោយព្រោះតែការដាច់ទំនាក់ទំនងរបស់យើងពីព្រះជាម្ចាស់ និងភាពមិនគ្រប់លក្ខណ៍នៃការបំរើរបស់យើង នោះយើងត្រូវការអោយទ្រង់ធ្វើជាសំដេចសង្ឃ ដើម្បីនឹងផ្សះផ្សាយើងរាល់គ្នា នឹងព្រះជាម្ចាស់ ដើម្បីអោយទ្រង់បានទទួលស្គាល់យើង[៩៥] ។ ដោយព្រោះយើងបានបែរចេញពីព្រះហើយ យើងមិនអាចនឹងត្រឡប់ទៅឯទ្រង់វិញបានទេ មិនតែប៉ុណ្ណោះទៀតសោត យើងក៏ត្រូវការសេចក្ដីសង្គ្រោះ និងសុវត្ថិភាពអោយរួចពីសត្រូវខាងឯព្រលឹងវិញ្ញាណរបស់យើងផងដែរ ។ យ៉ាងនោះហើយ បានជាយើងត្រូវការទ្រង់ធ្វើជាព្រះមហាក្សត្ររបស់យើង ដើម្បីអោយទ្រង់គ្រប់គ្រង ទាញ ប្រោស និងការពារថែរក្សាយើងទាំងអស់គ្នា រហូតទាល់តែយើងបានទៅឯល់នគរស្ថានសួគ៌របស់ទ្រង់[៩៦] ។

[៩៤]យ៉ូន ១:១៨ ។ [៩៥]កូល ១:២១; កា ៥:១៧ ។ [៩៦]យ៉ូន ១៦:៨; ទំនុក ១១០:៣; លូ ១:៧៤, ៧៥ ។

# ជំពូក ៩
# ឆន្ទះសេរី

១. ជាធម្មតា ព្រះទ្រង់បានប្រទានអោយមនុស្សមានឆន្ទៈដែលមានសេរីភាព និងអំណាច ដើម្បីអោយយើងជ្រើសរើសដោយគ្មានការបង្ខិតបង្ខំ ឬ ការជំរុញអោយធ្វើល្អ ឬ អាក្រក់[១] ។

[១]ម៉ាថ ១៧:១២; យ៉ា ១:១៤; ចោទិ ៣០:១៩ ។

២. នៅក្នុងភាពដែលគ្មានទោសរបស់ខ្លួន មនុស្សមានសេរីភាព និងអំណាច ដើម្បីធ្វើការដែលល្អ និង ជាទីគាប់ដល់ព្រះហឫទ័យព្រះជាម្ចាស់[២] ។ ប៉ុន្តែការនេះនឹងមិនមានស្ថេរភាពទេ ដូច្នេះហើយ មនុស្សអាចនឹងត្រូវធ្លាក់ចេញពីស្ថានភាពនោះវិញ[៣] ។

[២]សាស ៧:២៩ ។ [៣]លោក ៣:៦ ។

៣. ការដែលបានធ្លាក់ទៅក្នុងអំពើបាប មនុស្សបានបាត់បង់សមត្ថភាពនៃការសំរេចចិត្តទាំងស្រុង ដើម្បីនឹងធ្វើការល្អណាមួយខាងឯវិញ្ញាណដែលមកពីសេចក្តីសង្គ្រោះនោះ[៤] ។ ដូច្នេះមនុស្សខាងសាច់ឈាមគ្រប់រូប (មិនមែនខាងឯវិញ្ញាណ) គឺពួកគេបានស្លាប់នៅក្នុងអំពើបាប[៥] ហើយទាស់ប្រឆាំងដាច់ខាតទៅនឹងអ្វីដែលជាការល្អ ។ ដូច្នេះ គេមិនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំផ្លាស់បំប្រែខ្លួនឯង ដោយកំលាំង

ផ្លាល់ខ្លួនអោយបានបែរទៅរកព្រះបានទេ សូម្បីតែរៀបចំខ្លួនដើម្បីនឹងបែរទៅរកព្រះ នោះក៏គ្មានផង[៦] ។

[៤]រ៉ូម ៥:៦; ៨:៧ ។ [៥]អេ ២:១, ៥ ។ [៦]ទីត ៣:៣-៥; យ៉ូន ៦:៤៤ ។

៤. នៅពេលដែលព្រះជាម្ចាស់បំផ្លាស់បំប្រែមនុស្សមានបាប ទ្រង់នាំពួកគេចេញពីអំពើបាប ដោយដាក់ពួកគេទៅក្នុងព្រះគុណរបស់ទ្រង់ នោះមានន័យថា ទ្រង់បានស្រាយពួកគេចេញពីចំណងអំពើបាបហើយ[៧] ។ ហើយ ដោយព្រះគុណទ្រង់តែមួយ ទ្រង់ធ្វើអោយពួកគេមានឆន្ទះនឹងអាចធ្វើការល្អខាងឯវិញ្ញាណវិញបាន[៨] ។ ប៉ុន្តែ ពួកគេនៅតែមានសេចក្តីអាក្រក់ខ្លះដែរ ដ្បិតច្នេះឆន្ទះរបស់ពួកគេ គឺមិនដែលចង់ធ្វើការល្អទាំងស្រុងនោះទេ តែក៏ចង់ធ្វើការអាក្រក់ដែរ[៩] ។

[៧]កូល ១:១៣; យ៉ូន ៨:៣៦ ។ [៨]ភី ២:១៣ ។ [៩]រ៉ូម ៧:១៥, ១៨, ១៩, ២១, ២៣ ។

៥. ឆន្ទះរបស់មនុស្សត្រូវបានបង្កើតឡើង ដោយមានសេរីភាព ភាពគ្រប់លក្ខណ៍ និងដោយការមិនផ្លាស់ប្តូរ ដើម្បីធ្វើតែការល្អ បន្ទាប់ពីពួកគេត្រូវបានដំកើងឡើង គឺមិនមែនមុនពេលដែលពួកគេត្រូវបានដំកើងឡើងនោះទេ[១០] ។

[១០]អេ ៤:១៣ ។

# ជំពូក ១០

# ការត្រាស់ហៅដ៏ស័ក្តិសិទ្ធិ

១. អស់អ្នកដែលទ្រង់បានតំរូវទុកជាមុនអោយមានជីវិត នៅពេលកំណត់ ទ្រង់សព្វព្រះហឫទ័យ នឹងប្រទាននូវការត្រាស់ហៅដ៏សក្តិសិទ្ធិមួយដល់ពួកគេ[១]តាមរយៈព្រះបន្ទូល និងព្រះវិញ្ញាណរបស់ទ្រង់ ។ ទ្រង់ត្រាស់ហៅពួកគេចេញពីអំពើបាប និងសេចក្តីស្លាប់ដែលពួកគេមានតាំងពីកំណើត ដើម្បីនាំពួកគេមកក្នុងព្រះគុណ និងសេចក្តីសង្គ្រោះដោយព្រះយេស៊ូវគ្រីស្ទ[២] ។ ព្រះជាម្ចាស់បានប្រទានចំណេះដឹងដល់គំនិតរបស់គេដោយព្រះវិញ្ញាណ ដើម្បីអោយបានយល់ពីអ្វីៗរបស់ព្រះជាម្ចាស់[៣] ។ ទ្រង់ក៏បានដកយកអស់ទាំងចិត្តរឹងដូចថ្មរបស់ពួកគេ ហើយទ្រង់ប្រទានអោយពួកគេមានចិត្តទន់ដូចជាសាច់វិញ[៤] ។ ទ្រង់បានកែពួកគេជាថ្មីហើយតាមរយៈអំណាចព្រះចេស្តារបស់ទ្រង់ ទ្រង់បានធ្វើអោយពួកគេស្វែងរក និងធ្វើតាមនូវអ្វីដែលល្អ ។ នៅពេលដំណាលគ្នានោះដែរ ទ្រង់បានទាញពួកគេអោយចូលទៅឯព្រះយេស៊ូវគ្រីស្ទ[៥] ហើយពួកគេបានមកដោយសេរីគ្មានការបង្ខិតបង្ខំ ដ្បិតព្រះទ្រង់បានធ្វើអោយពួកគេមានឆន្ទះ ដោយព្រះគុណរបស់ទ្រង់[៦] ។

[១]រ៉ូម ៨:៣០; ១១:៧; អេ ១:១០, ១១; ២ថែស ២:១៣, ១៤ ។ [២]អេ ២:១-៦ ។ [៣]កិច្ច ២៦:១៨; អេ ១:១៧, ១៨ ។ [៤]អេសេ ៣៦:២៦ ។

[៥]ចោទិ ៣០:៦; អេសេ ៣៦:២៧; អេ ១:១៩ ។ [៦]ទំនុក ១១០:៣; បទ ១:៤ ។

២. ការត្រាស់ហៅដ៏ស័ក្តិសិទ្ធិនេះ គឺជាលទ្ធផលដែលបានមក ពីព្រះគុណដ៏ពិសេស និងដ៏មានសេរីភាពរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ។ មនុស្សបានស្លាប់នៅក្នុងអំពើបាប និងក្នុងសេចក្តីរំលងរបស់ពួកគេ រហូតទាល់ព្រះវិញ្ញាណបរិសុទ្ធបានប្រទានជីវិតថ្មី ហើយបានកែពួកគេជាថ្មីឡើង[៧] ។ ដូច្នេះ មនុស្សមិនបានចូលរួមធ្វើអ្វីទាំងអស់ នៅក្នុងកិច្ចការនៃសេចក្តីសង្គ្រោះនេះ ពីព្រោះព្រះគុណនេះមិនមែនមកដោយសារតែព្រះបានទតឃើញជាមុន ថាមានអ្វីដែលល្អនៅក្នុងមនុស្សនោះទេ ហើយក៏មិនមែនដោយសារអំណាចណាមួយ នៅក្នុងមនុស្សនោះដែរ[៨] ។ តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ មនុស្សអាចនឹងឆ្លើយតបចំពោះការត្រាស់ហៅ ហើយអាចទទួលយកព្រះគុណដែលព្រះបានប្រទានមកនោះបាន ហើយការនេះកើតឡើងបានដោយសារអំណាចដ៏អស្ចារ្យតែមួយ ដែលបានប្រោសអោយព្រះគ្រីស្ទរស់ពីស្លាប់ឡើងវិញ[៩] ។

[៧]១កូ ២:១៤; អេ ២:៥; យ៉ូន ៥:២៥ ។ [៨] ២ធី១:៩; អេ ២:៨ ។ [៩]អេ ១:១៩, ២០ ។

៣. ទារកដែលព្រះបានជ្រើសរើស ហើយបានស្លាប់ក្នុងភាពជាទារករបស់ខ្លួន នោះនឹងត្រូវបានកើតជាថ្មី ហើយបានសង្គ្រោះដោយព្រះគ្រីស្ទតាមរយៈព្រះវិញ្ញាណ[១០] ដែលទ្រង់ធ្វើការនៅគ្រប់ពេល គ្រប់ទីកន្លែង និងគ្រប់វិធី តាមព្រះហឫទ័យទ្រង់[១១] ។ អស់អ្នកដែលទ្រង់បានជ្រើស

រើសហើយ តែខ្វះកាយសតិសម្បទាគ្រប់គ្រាន់ហើយមិនអាចយល់ពីដំណឹងល្អបាននោះ ព្រះក៏បានសង្គ្រោះពួកគេតាមរបៀបនោះដែរ ។

[10]យ៉ូន ៣:៣, ៥, ៦ ។ [11]យ៉ូន ៣:៨ ។

៤. ចំពោះពួកអ្នកផ្សេងទៀតដែលមិនបានជ្រើសរើស ទោះបើជាពួកគេអាចនឹងត្រូវបានត្រាស់ហៅមក តាមរយៈកិច្ចការនៃអ្នកប្រកាសព្រះបន្ទូល ហើយ ពួកគេអាចឯកពិសោធន៍ក្នុងកិច្ចការទូទៅមួយចំនួននៃព្រះវិញ្ញាណក្តី[12] ក៏ពួកគេនឹងមិនបានសង្គ្រោះដែរ[13] ព្រោះព្រះវរបិតាមិនបានទាញពួកគេមកឯព្រះគ្រីស្ទ ។ ដូច្នេះក្នុងហេតុផលនេះ ពួកគេមិនអាចមកឯព្រះគ្រីស្ទដោយពិតប្រាកដបានឡើយ ។ លើសពីនេះទៅទៀត អស់អ្នកណាដែលមិនជឿលើព្រះយេស៊ូវគ្រីស្ទ នោះនឹងមិនបានសង្គ្រោះឡើយ ទោះបីជាពួកគេខំប្រឹងប្រែងរៀបចំជីវិតរស់នៅក្នុងរបៀបដែលល្អ ហើយ ខិតខំកាន់តាមសាសនារបស់ខ្លួនក៏ដោយ[14] ។

[12]ម៉ាថ ២២:១៤; ១៣:២០, ២១; ហេ ៦:៤-៦ ។ [13]យ៉ូន ៦:៤៤, ៤៥, ៦៥; ១យ៉ូន ២:២៤, ២៥ ។ [14]កិច្ច ៤:១២; យ៉ូន ៤:២២; ១៧:៣ ។

# ជំពូក ១១
# ការរាប់ជាសុចរិត

១. អស់អ្នកណាដែលព្រះជាម្ចាស់បានត្រាស់ហៅមក នោះទ្រង់ក៏បានរាប់គេជាសុចរិតដែរ[១] ទ្រង់បានធ្វើការនេះដោយព្រោះការអត់ទោសដល់អំពើបាបរបស់ពួកគេ ហើយក៏រាប់ និងទទួលពួកគេ ជាសុចរិត[២] ។ ការនេះមិនមែនបានកើតឡើង ដោយព្រោះអ្វីណាមួយដែលជារបស់ពួកគេ ឬក៏ ពួកគេបានធ្វើការណាមួយ អោយបានរាប់ជាសុចរិតនោះឡើយ ប៉ុន្តែគឺជាព្រះដែលទ្រង់បានធ្វើការនោះ ដោយព្រោះតែព្រះគ្រីស្ទមួយអង្គប៉ុណ្ណោះ[៣] ។ សេចក្ដីសុចរិតដែលព្រះបានដាក់នៅក្នុងពួកគេ គឺជាការដែលទ្រង់រាប់ពួកគេជាសុចរិត គឺមិនមែនជាសេចក្ដីជំនឿរបស់ពួកគេ ហើយក៏មិនមែនជាការប្រព្រឹត្តនៅក្នុងការរស់នៅ ហើយក៏មិនមែនជាការស្ដាប់បង្គាប់តាមដំណឹងល្អដែលពួកគេធ្វើនោះដែរ ប៉ុន្តែដោយសារតែការស្ដាប់បង្គាប់របស់ព្រះគ្រីស្ទប៉ុណ្ណោះ ។ ការស្ដាប់បង្គាប់របស់ព្រះគ្រីស្ទមានពីរផ្នែក គឺ ការស្ដាប់បង្គាប់ដែលសកម្មរបស់ទ្រង់ចំពោះក្រិត្យវិន័យទាំងស្រុង និង ការស្ដាប់បង្គាប់ដែលអសកម្មរបស់ទ្រង់ ដែលទ្រង់ត្រូវបានគេធ្វើគត់ ។ ដូច្នេះអស់អ្នកណាដែលបានរាប់ជាសុចរិត ពួកគេបានទទួលការសំរាកដោយជំនឿនៃសេចក្ដីសុចរិត របស់ព្រះគ្រីស្ទ ។ ហើយសេចក្ដីជំនឿនេះមិនមែនកើតឡើងដោយខ្លួនគេផ្ទាល់នោះទេ តែវាជាអំណោយទានរបស់ព្រះវិញ[៤] ។

[១]រ៉ូម ៣:២៩; ៨:៣០ ។ [២]រ៉ូម ៩:៥-៨; អេ ១:៧ ។ [៣]១កូ ១:៣០, ៣១; រ៉ូម ៥:១៧-១៩ ។ [៤]ភី ៣:៨, ៩; អេ ២:៨-១០; យ៉ូន ១:១២; រ៉ូម ៥:១៧ ។

២. ជំនឿដែលបានទទួលដោយពឹងលើព្រះគ្រីស្ទនិងសេចក្ដីសុចរិតរបស់ទ្រង់ គឺជាមធ្យោបាយតែមួយគត់នៃការរាប់ជាសុចរិត[៦] ។ ប៉ុន្តែជំនឿនេះ មិនមែនមានតែឯង នៅក្នុងជីវិតអ្នកដែលបានរាប់ជាសុចរិតនោះទេ ប៉ុន្តែជានិច្ចជាកាល វាបានរួមជាមួយនឹងព្រះគុណដែលជួយសង្គ្រោះផងដែរ ។ ហើយជំនឿនេះក៏មិនមែនជាជំនឿដែលស្លាប់ដែរ ប៉ុន្តែ មានសកម្មភាពដោយសេចក្ដីស្រឡាញ់វិញ[៧] ។

[៦]រ៉ូម ៣:២៨ ។ [៧]កា ៥:៦; យ៉ា ២:១៧, ២២, ២៦ ។

៣. តាមរយៈការស្ដាប់បង្គាប់និងការសុគតរបស់ទ្រង់ ព្រះគ្រីស្ទបានសងថ្លៃបំណុលទាំងអស់ ជំនួសពួកអ្នកដែលបានរាប់ជាសុចរិត ដោយយញ្ញបូជារបស់ទ្រង់ ដែលព្រះលោហិតបានហូរលើឈើឆ្កាងរបស់ទ្រង់ ហើយទ្រង់បានរងទុក្ខ ហើយបានទទួលទោសជំនួសពួកគេ នោះទ្រង់បានធ្វើអោយព្រះជាម្ចាស់បានស្កប់ព្រះហឫទ័យពេញលេញ យ៉ាងសមរម្យ និងដោយពិតប្រាកដចំពោះសេចក្ដីយុត្តិធម៌របស់ទ្រង់[៨] ។ ប៉ុន្តែការរាប់ជាសុចរិតរបស់ពួកគេ គឺមកពីព្រះគុណទាំងស្រុង ពីព្រោះទីមួយ ព្រះគ្រីស្ទគឺជាអំណោយរបស់ព្រះ ដើម្បីធ្វើអ្វីៗទាំងអស់ជំនួសពួកគេ ។ ទីពីរ ការស្ដាប់បង្គាប់របស់ព្រះគ្រីស្ទ ហើយនិង ព្រះគ្រីស្ទពេញព្រះទ័យនឹងតំរូវការនៃក្រិត្យវិន័យ នោះព្រះជាម្ចាស់បានទទួលយកការនោះសំរាប់ពួកគេ ។ ហើយទីបី គ្មានអ្វីនៅក្នុងពួកគេដែលគួរអោយពួកគេ

សមនឹងទទួលសេចក្ដីមេត្តាករុណាទាំងអស់នេះឡើយ[៩] ។ ដូច្នេះ ទាំងសេចក្ដីយុត្តិធម៌ និងទាំងព្រះគុណដ៏ពេញបរិបូណ៌របស់ព្រះជាម្ចាស់ មានសិរីរុងរឿងនៅក្នុងការរាប់ជាសុចរិតរបស់មនុស្សមានបាប[១០] ។

[៨]ហេ ១០:១៤; ១ពេ ១:១៨, ១៩; អេសា ៥៣:៥, ៦ ។ [៩]រ៉ូម ៨:៣២; ២កូ ៥:២១ ។ [១០]រ៉ូម ៣:២៦; អេ ១:៦, ៧; ២:៧ ។

៤. តាំងពីអស់កល្បរៀងមក ព្រះជាម្ចាស់បានដាក់ព្រះរាជឱង្ការ ដើម្បីរាប់ជាសុចរិត ដល់អ្នកដែលទ្រង់បានជ្រើសរើសទាំងអស់[១១] ហើយនៅក្នុងពេលវេលាដែលមកដល់ ព្រះគ្រីស្ទបានសុគតជំនួសអំពើបាបរបស់ពួកគេ ហើយបានរស់ឡើងវិញ ដើម្បីអោយពួកគេបានសុចរិត[១២] ។ ប៉ុន្តែពួកគេម្នាក់ៗមិនទាន់បានរាប់ជាសុចរិតដោយផ្ទាល់នោះទេ ទាល់តែដល់ពេលកំណត់ ទើបព្រះវិញ្ញាណបរិសុទ្ធធ្វើអោយកិច្ចការរបស់ព្រះគ្រីស្ទបានចូលជាធរមានសំរាប់ពួកគេបាន[១៣] ។

[១១]កា ៣:៨; ១ពេ ១:២; ១ធី ២:៦ ។ [១២]រ៉ូម ៤:២៥ ។ [១៣]កូល ១:២១, ២២; ទីត ៣:៤-៧ ។

៥. ព្រះជាម្ចាស់នៅតែបន្តអត់ទោសបាប ដល់អស់អ្នកដែលបានរាប់ជាសុចរិត[១៤] ។ ទោះបីជាពួកគេនឹងមិនធ្លាក់ចេញ ពីការរាប់ជាសុចរិតរបស់ខ្លួនក៏ដោយ[១៥] ប៉ុន្តែពួកគេអាចនឹងត្រូវធ្លាក់ចេញដែរ ដោយព្រោះតែអំពើបាបរបស់ពួកគេ ដែលមិនគាប់ដល់ព្រះហឫទ័យព្រះវរបិតា[១៦] ។ ជាធម្មតា ការដែលមិនគាប់ព្រះហឫទ័យដល់ទ្រង់នេះ នឹងនៅតែបន្តទៀត

ទាល់តែពួកគេបានបន្ទាបខ្លួន លន់តួអំពើបាប សូមការអត់ទោស និង ត្រឡប់មកឯសេចក្តីជំនឿរបស់ពួកគេ និងប្រែចិត្តជាថ្មីឡើងវិញ[១៧] ។

[១៤]ម៉ាថ ៦:១២; ១យ៉ូន ១:៧, ៩ ។ [១៥]យ៉ូន ១០:២៨ ។ [១៦]ទំនុក ៨៩:៣១-៣៣ ។ [១៧]ទំនុក ៣២:៥; ទំនុក ៥១; ម៉ាថ ២៦:៧៥ ។

៦. អ្នកជឿនៅក្នុងសម័យសញ្ញាចាស់ ត្រូវបានរាប់ជាសុចរិត នៅក្នុង របៀបដូចគ្នាបេះបិទទៅនឹងការរាប់ជាសុចរិត ដល់អ្នកជឿទាំងអស់នៅ ក្នុងសម័យសញ្ញាថ្មីនេះដែរ[១៨] ។

[១៨]កា ៣:៩; រ៉ូម ៤:២២-២៤ ។

# ជំពូក ១២
# ការទទួលជាកូនចិញ្ចឹម

១. អស់អ្នកដែលបានរាប់ជាសុចរិត ព្រះជាម្ចាស់បានសព្វព្រះហឫទ័យ យកពួកគេធ្វើជាកូនចិញ្ចឹម ដោយយល់ដល់ព្រះរាជបុត្រាតែមួយរបស់ ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ[១] ។ ដោយព្រះគុណនេះ ពួកគេត្រូវបានរាប់ជា កូនរបស់ព្រះជាម្ចាស់ ហើយពួកគេពេញចិត្តចំពោះ សេរីភាព និង ឯកសិទ្ធិជាកូនរបស់ព្រះ[២] ។ លើសពីនោះទៀត ពួកគេមានព្រះនាមទ្រង់ ដែលទ្រង់បានដាក់អោយ[៣] ហើយពួកគេបានទទួលវិញ្ញាណនៃការរាប់ ទុកជាកូនចិញ្ចឹម[៤] ។ ពួកគេចូលដល់បល្ល័ង្គនៃព្រះគុណដោយភាពក្លាហាន

ហើយស្រែកឡើងថា “ឱអ័ប្បាព្រះវរបិតាអើយ”[៥] ។ ពួកគេបានទទួលការអាណិតអាសូរ[៦] ការការពារ[៧] ការផ្គត់ផ្គង់[៨] និងទទួលការដាក់វិន័យពីទ្រង់ ក្នុងនាមជាឪពុកម្នាក់[៩] ។ ហើយពួកគេមិនដែលបានទទួលការបំបរបង់ចោលទេ[១០] តែត្រូវបានដៅចំណាំទុករហូតដល់ថ្ងៃនៃការប្រោសលោះវិញ[១១] ហើយពួកគេនឹងបានទទួលសេចក្ដីសន្យា អោយធ្វើជាអ្នកស្នងមរតកនៃសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច[១២] ។

[១]អេ ១:៥; កា ៤:៤, ៥ ។ [២]យ៉ូន ១:១២; រ៉ូម ៨:១៧ ។ [៣] ២កូ ៦:១៨; វិវរ ៣:១២ ។ [៤]រ៉ូម ៨:១៥ ។ [៥]កា ៤:៦; អេ ២:១៨ ។ [៦]ទំនុក ១០៣:១៣ ។ [៧]សុ ១៤:២៦ ។ [៨]១ពេ ៥:៧ ។ [៩]ហេ ១២:៦ ។ [១០]អេសា ៥៤:៨, ៩; បរិ ៣:៣១ ។ [១១]អេ ៤:៣០ ។ [១២]ហេ ១:១៤; ៦:១២ ។

# ជំពូក ១៣
# ការញែកចេញជាបរិសុទ្ធ

១. អស់អ្នកណាដែលរួមមកក្នុងព្រះគ្រីស្ទ ជាពួកអ្នកដែលទ្រង់បានត្រាស់ហៅមក ហើយជាពួកអ្នកដែលបានកើតជាថ្មី ពួកគេមានចិត្តថ្មីនិងវិញ្ញាណថ្មីដែលទ្រង់បានបង្កើតនៅក្នុងពួកគេ តាមរយៈការសុគតនិងការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ ហើយអោយពួកគេកាន់តែបានបរិសុទ្ធឡើង[១] ដោយសារព្រះបន្ទូលនិងព្រះវិញ្ញាណដែលរស់នៅក្នុងពួកគេ[២] ។ រីឯអំណាចនៃអំពើបាបដែលគ្រប់គ្រងរូបកាយពួកគេនោះ

ត្រូវបានបំផ្លាញចោលទាំងស្រុងវិញ[៣] ហើយសេចក្តីប៉ងប្រាថ្នានៃអំពើបាបរបស់រូបកាយកំពុងតែអន់ថយទៅៗ ហើយទីបំផុតវាបានចាញ់ទាំងស្រុង[៤] ។ ហើយព្រះគុណដែលបានសង្គ្រោះ[៥] ក្នុងរាស្ត្ររបស់ព្រះគ្រីស្ទកាន់តែមានកំលាំងខ្លាំងឡើងៗ នោះពួកគេអាចអនុវត្តភាពបរិសុទ្ធដ៏ពិតប្រាកដទាំងអស់នេះបាន ។ បើគេគ្មានភាពបរិសុទ្ធទេ គ្មាននរណាម្នាក់អាចនឹងឃើញព្រះជាម្ចាស់បានឡើយ[៦] ។

[១]កិច្ច ២០:៣២; រ៉ូម ៦:៥,៦ ។ [២]យ៉ូន ១៧:១៧; អេ ៣:១៦-១៩; ១ថែស ៥:២១-២៣ ។ [៣]រ៉ូម ៦:១៤ ។ [៤]កា ៥:២៤ ។ [៥]កូល ១:១១ ។ [៦] ២កូ ៧:១; ហេ ១២:១៤ ។

២. ការញែកចេញជាបរិសុទ្ធនេះ មាននៅពេញក្នុងបុគ្គលនោះ[៧] ប៉ុន្តែមិនមានភាពគ្រប់លក្ខណ៍នៅក្នុងជីវិតនេះទេ ពីព្រោះពួកគេនៅមានសេសសល់សេចក្តីខូចអាក្រក់ខ្លះ នៅគ្រប់កន្លែងទាំងអស់ នៅក្នុងជីវិតរបស់ពួកគេនៅឡើយ[៨] ។ ការនោះ គឺជាសង្គ្រាមឥតឈប់ឈរមួយដែលមិនអាចផ្សះផ្សាគ្នាបាន គឺសេចក្តីប៉ងប្រាថ្នានៃសាច់ឈាមទាស់ប្រឆាំងនឹងព្រះវិញ្ញាណ ហើយព្រះវិញ្ញាណទាស់ប្រឆាំងនឹងសាច់ឈាម[៩] ។

[៧]១ថែស ៥:២៣ ។ [៨]រ៉ូម ៧:១៨, ២៣ ។ [៩]កា ៥:១៧; ១ពេ ២:១១ ។

៣. នៅក្នុងសង្គ្រាមនេះ ជួនកាលការសេសសល់នៃសេចក្តីខូចអាក្រក់បានយកឈ្នះលើការច្បាំងនេះ[១០] ប៉ុន្តែតាមរយៈការផ្តល់កំលាំងអោយដោយឥតឈប់ឈរពីព្រះវិញ្ញាណដែលញែកជាបរិសុទ្ធ របស់ព្រះគ្រីស្ទ

នោះផ្នែកដែលបង្កើតជាថ្មី នឹងមានជ័យជំនះវិញ[១១] ។ ហេតុនោះហើយ ពួកបរិសុទ្ធរីកចំរើនឡើង នៅក្នុងព្រះគុណនៃភាពបរិសុទ្ធដែលកំពុងតែគ្រប់លក្ខណ៍ក្នុងសេចក្តីកោតខ្លាចដល់ព្រះ ។ ពួកគេកំពុងតែស្វែងរកជីវិតបែបស្ថានសួគ៌ ដោយស្តាប់បង្គាប់គ្រប់ទាំងបញ្ញត្តិនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ដែលព្រះគ្រីស្ទជាសិរសា និងជាស្តេចបានប្រទានអោយពួកគេ[១២] ។

[១០]រ៉ូម ៧:២៣ ។ [១១]រ៉ូម ៦:១៤ ។ [១២]អេ ៤:១៥,១៦; ២កូ ៣:១៨; ៧:១ ។

# ជំពូក ១៤
# ជំនឿដែលបានសង្គ្រោះ

១. ពួកអ្នករើសតាំងរបស់ព្រះអាចនឹងជឿតាមបាន ដោយសារព្រះគុណនៃសេចក្តីជំនឿលើការសង្គ្រោះព្រលឹងរបស់ពួកគេ ដែលជាកិច្ចការរបស់ព្រះវិញ្ញាណនៃព្រះគ្រីស្ទនៅក្នុងចិត្តរបស់ពួកគេ[១] ហើយជាធម្មតានាំអោយបានសំរេច ដោយកិច្ចការនៃការប្រកាសព្រះបន្ទូលនៃព្រះ[២] ។ ព្រះគុណនៃសេចក្តីជំនឿក៏បង្កើន និងផ្តល់កំលាំងកាន់តែខ្លាំង ដោយពិធីជ្រមុជទឹក ពិធីលៀងព្រះអម្ចាស់ សេចក្តីអធិស្ឋាន និងរបៀបផ្សេងៗទៀត ដែលព្រះជាម្ចាស់បានកំណត់ឡើងផងដែរ[៣] ។

[១] ២កូ ៤:១៣; អេ ២:៨ ។ [២]រ៉ូម ១០:១៤, ១៧ ។ [៣]លូ ១៧:៥; ១ពេ ២:២; កិច្ច ២០:៣២ ។

២. តាមរយៈសេចក្តីជំនឿ គ្រីស្ទបរិស័ទម្នាក់ជឿពិតប្រាកដនូវអ្វីដែលបើកសំដែងនៅក្នុងព្រះបន្ទូល ដែលជាអំណាចនៃព្រះជាម្ចាស់[៤] ។ ហើយគ្រីស្ទបរិស័ទ ក៏យល់ដឹងថា មានភាពអស្ចារ្យនៅក្នុងព្រះបន្ទូលរបស់ព្រះដែលខ្ពស់លើសជាងសំណេរផ្សេងៗ និងគ្រប់របស់ទាំងអស់នៅលើពិភពលោកនេះ[៥] ដោយព្រោះថា ព្រះបន្ទូលបង្ហាញអោយឃើញពីសិរីរុងរឿងរបស់ព្រះជាម្ចាស់ តាមរយៈលក្ខណៈរបស់ទ្រង់ ឧត្តមភាពនៃនិស្ស័យរបស់ព្រះគ្រីស្ទ និងតំណែងនានារបស់ទ្រង់ ព្រមទាំងព្រះចេស្តា និងភាពពេញលេញនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងកិច្ចការ និងកិច្ចប្រតិបត្តិការណ៍ផ្សេងៗរបស់ទ្រង់ ។ ដូច្នេះគ្រីស្ទបរិស័ទអាចទុកចិត្តលើសេចក្តីពិត[៦] ហើយបំរើទៅតាមតំរូវការនានារបស់ព្រះគម្ពីរ ។ គាត់ស្តាប់បង្គាប់តាមបញ្ញត្តិ[៧] ហើយពេលដែលគេព្យាការគំរាម គេក៏ភ័យញ័រ[៨] ហើយគេស្រវាអោបព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ សំរាប់ជីវិតនេះ និងសំរាប់ជីវិតនៅពេលខាងមុខ[៩] ។ ប៉ុន្តែសកម្មភាពចំបង នៃសេចក្តីជំនឿដែលបានសង្គ្រោះ ទាក់ទងទៅនឹងព្រះគ្រីស្ទ គឺត្រូវព្រមទួលជឿទ និងសំរាកក្នុងទ្រង់តែមួយប៉ុណ្ណោះ ដើម្បីអោយបានរាប់ជាសុចរិត ញែកជាបរិសុទ្ធ និងជីវិតអស់កល្បជានិច្ច ។ ការទាំងអស់នេះបានមក ដោយសេចក្តីសញ្ញានៃព្រះគុណ[១០] ។

[៤]កិច្ច ២៨:១៤ ។ [៥]ទំនុក ១៩:៧-១០; ១១៩:៧២ ។ [៦] ២ធី ១:១២ ។ [៧]យ៉ូន ១៥:១៤ ។ [៨]អេសា ៦៦:២ ។ [៩]ហេ ១១:១៣ ។ [១០]យ៉ូន ១:១២; កិច្ច ១៦:៣១; កា ២:២០; កិច្ច ១៥:១១ ។

៣. សេចក្ដីជំនឿពិត អាចមានកំរិតខុសគ្នា ។ វាអាចនឹងខ្សោយ ឬខ្លាំង[១១] ។ ប៉ុន្តែ ទោះបីជាសេចក្ដីជំនឿនេះមានភាពទន់ខ្សោយបំផុតក៏ដោយ វាក៏នៅតែមានលក្ខណៈខុសគ្នាឆ្ងាយណាស់ពីសេចក្ដីជំនឿ និងព្រះគុណសាមញ្ញនៃអ្នកដែលជឿបណ្ដោះអាសន្នដែរ[១២] ។ ជាលទ្ធផល ទោះបីជាសេចក្ដីជំនឿពិត អាចនឹងទទួលរងការវាយប្រហារជាញឹកញយ និងខ្សោយទៅៗក្ដី ប៉ុន្តែវានឹងទទួលជ័យជំនះនៅចុងបញ្ចប់[១៣] ។ សេចក្ដីជំនឿនោះនឹងរីកចំរើនទៅៗ នៅក្នុងគ្រីស្ទបរិស័ទជាច្រើន រហូតដល់ពួកគេទទួលការធានាអះអាងពេញលេញ តាមរយៈព្រះគ្រីស្ទ[១៤] ជាអ្នកមេផ្ដើម និងជាមេសំរេចសេចក្ដីជំនឿរបស់យើង[១៥] ។

[១១]ហេ ៥:១៣, ១៤; ម៉ាថ ៦:៣០; រ៉ូម ៤:១៩, ២០ ។ [១២] ២ពេ ១:១ ។ [១៣]អេ ៦:១៦; ១យ៉ូន ៥:៤, ៥ ។ [១៤]ហេ ៦:១១, ១២; កូល ២:២ ។ [១៥]ហេ ១២:២ ។

# ជំពូក ១៥
# ការប្រែចិត្តសំរាប់ជីវិត និង សេចក្តីសង្គ្រោះ

១. ពួកជ្រើសរើសរបស់ព្រះមួយចំនួន មិនបានផ្លាស់ប្រែរហូតទាល់តែដល់ពួកគេមានវ័យចាស់ ។ ពួកគេបាននៅតែបន្តធ្វើតាមសេចក្តីប៉ងប្រាថ្នា ការសប្បាយរីករាយខាងសេចក្តីអាក្រក់ផ្សេងៗរបស់ពួកគេ ។ បន្ទាប់មក ការត្រាស់ហៅដ៏ស័ក្តិសិទ្ធិរបស់ព្រះបានទៅដល់ពួកគេ ហើយទ្រង់បានប្រទានអោយពួកគេនូវ ការប្រែចិត្តដែលនាំទៅកាន់ជីវិតអស់កល្បជានិច្ច[១] ។

[១]ទីត ៣:២-៥ ។

២. គ្មានមនុស្សណាម្នាក់ដែលល្អ ហើយមិនធ្វើបាបទេ[២] ។ សូម្បីតែមនុស្សល្អបំផុត គាត់អាចនឹងប្រព្រឹត្តិអំពើបាបដ៏ធំ ដែលជាទីស្អប់ខ្ពើមដល់ព្រះ តាមរយៈអំណាចនៃការបោកបញ្ឆោតនៃនិស្ស័យសាច់ឈាមរបស់គាត់ និងសេចក្តីពុករលួយដ៏អាក្រក់ដែលនៅខាងក្នុងគាត់ ហើយ និង កំលាំងនៃសេចក្តីល្បួងផងដែរ ។ ហេតុនេះហើយ ទ្រង់បានប្រទានសេចក្តីសញ្ញានៃព្រះគុណនេះមក ដោយសេចក្តីមេត្តាករុណាដល់អស់អ្នកជឿដែលបានធ្វើបាបហើយបានដួល នឹងបានកែជាថ្មីឡើងវិញតាមរយៈការប្រែចិត្តទៅឯសេចក្តីសង្គ្រោះ[៣] ។

[២]សាស ៧:២០ ។ [៣]លូ ២២:៣១, ៣២ ។

៣. ការប្រែចិត្តដែលបានសង្គ្រោះ គឺជាព្រះគុណនៃដំណឹងល្អមួយ[៤] ដែលព្រះវិញ្ញាណបរិសុទ្ធបណ្តាលអោយមនុស្សម្នាក់ បានដឹងខ្លួនពីសេចក្តីអាក្រក់ជាច្រើនប្រភេទនៃអំពើបាបរបស់គាត់ ។ ទ្រង់បានប្រទានអោយគេមានជំនឿក្នុងព្រះគ្រីស្ទ ដើម្បីអោយគេបានបន្ទាបខ្លួនផ្ទាល់ដោយព្រោះអំពើបាបរបស់គេ ។ ការបន្ទាបខ្លួននេះ បានបង្ហាញដោយការសោកស្តាយចំពោះអំពើបាប ការកោតខ្លាចដល់ព្រះ ហើយនិងមានចិត្តស្អប់ដល់អំពើបាបរបស់គាត់យ៉ាងខ្លាំង ព្រមទាំងមានចិត្តគួរខ្ពើមខ្លួនឯងផង[៥] ។ នៅក្នុងការប្រែចិត្តបែបនេះ អ្នកនោះត្រូវតែអធិស្ឋានផងដែរសំរាប់ការអត់ទោស និងសំរាប់កម្លាំងនៃព្រះគុណ ។ ហើយការប្រែចិត្តនេះ គួរមានគោលបំណង និងការខិតខំខ្នះខ្នែង ។ ការទាំងអស់នេះបានមកពី ការផ្តល់អំណាចអោយ ដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីនឹងដើរនៅចំពោះព្រះជាម្ចាស់ ជាមួយនឹងជីវិតដែលគាប់ព្រះហឫទ័យដល់ទ្រង់ក្នុងគ្រប់ការទាំងអស់ផង[៦] ។

[៤]សាក ១២:១០; កិច្ច ១១:១៨ ។ [៥]អេសេ ៣៦:៣១; ២កូ ៧:១១ ។ [៦]ទំនុក ១១៩:៦, ១២៨ ។

៤. ដោយព្រោះថា យើងនៅតែមានរូបកាយដែលមានបាប ហើយវាមានទំនោរទៅនឹងអំពើបាប ដូចនេះហើយ យើងត្រូវតែបន្តការប្រែចិត្តរបូតដល់អស់មួយជីវិតរបស់យើង ។ ដូច្នេះកាតព្វកិច្ចរបស់មនុស្ស គឺ

ត្រូវប្រែចិត្តចំពោះអំពើបាបផ្សេងៗដែលខ្លួនបានដឹង ហើយ ប្រែចិត្ត ដោយយកចិត្តទុកដាក់[៧] ។

[៧]លូ ១៩:៨; ១ធី ១:១៣, ១៥ ។

៥. ព្រះជាម្ចាស់បានប្រទានការផ្គត់ផ្គង់នេះ តាមរយៈព្រះយេស៊ូវគ្រីស្ទ នៅក្នុងសេចក្តីសញ្ញានៃព្រះគុណ សំរាប់ការការពារថែរក្សាពួកអ្នកជឿ នៅក្នុងផ្លូវនៃសេចក្តីសង្គ្រោះ ។ ទោះបីអំពើបាបដែលតូចបំផុត ក៏តម្រូវអោយមានការផ្តន្ទាទោសដែរ[៨] ប៉ុន្តែ អស់អ្នកណាដែលបានប្រែចិត្តវិញ នោះគ្មានអំពើបាបណាដែលធំពេក ដែលព្រះមិនអាចអត់ទោសអោយបាននោះទេ[៩] ។ ការនេះធ្វើអោយមានភាពចាំបាច់ជានិច្ច សំរាប់ការប្រកាសអំពីការប្រែចិត្ត ។

[៨]រ៉ូម ៦:២៣ ។ [៩]អេសា ១:១៦-១៨; ៥៥:៧ ។

# ជំពូក ១៦
# ការប្រព្រឹត្តិល្អ

១. ការប្រព្រឹត្តិល្អ គឺជាកិច្ចការទាំងឡាយណា ដែលព្រះជាម្ចាស់ទ្រង់បានបង្គាប់ក្នុងព្រះបន្ទូលបរិសុទ្ធរបស់ទ្រង់ប៉ុណ្ណោះ[១] ទើបគួរចាត់ទុកថាជាការប្រព្រឹត្តិល្អ ។ ការប្រព្រឹត្តិនានាដែលមិនមានសំដែងនៅក្នុងព្រះគម្ពីរ ហើយបានប្រឌិតឡើងពីមនុស្ស ដោយការឧស្សាហ៍ខាងភាពល្ងិតល្ងង់ ឬ តាមការឆបោកណាមួយនៃចេតនាល្អរបស់ពួកគេ នោះមិនមែនជាការប្រព្រឹត្តិល្អទេ[២] ។

[១]មីកា ៦:៨; ហេ ១៣:២១ ។ [២]ម៉ាថ ១៥:៩; អេសា ២៩:១៣ ។

២. ការប្រព្រឹត្តិល្អនេះ គឺបានអនុវត្តដោយស្តាប់បង្គាប់ចំពោះបញ្ញើរបស់ព្រះជាម្ចាស់ ដែលការនោះជាផលផ្លែ និងភស្តុតាងនៃសេចក្តីជំនឿដ៏រស់ និងពិតប្រាកដ[៣] ។ តាមរបៀបនេះ ពួកអ្នកជឿបានបង្ហាញនូវការអរព្រះគុណ[៤] ការពង្រឹងការធានាអះអាងដ៏មានការជឿជាក់[៥] ការស្អាងចិត្តបងប្អូនរបស់ពួកគេ ការធ្វើអោយទីបន្ទាល់នៃពួកអ្នកជឿ កាន់តែមានការជឿទុកចិត្តឡើង[៦] ហើយនិងពួកគេបញ្ឈប់បបូរមាត់នៃពួកបច្ចាមិត្តដែលប្រឆាំងនឹងដំណឹងល្អ ។ និយាយអោយខ្លីទៅ ពួកគេថ្វាយសិរីរុងរឿងដល់ព្រះ[៧] ដែលបានបង្កើតគេជាមនុស្សថ្មីនៅក្នុងព្រះគ្រីស្ទ[៨] ហើយពួកគេបង្កើតផលផ្លែនៃភាពបរិសុទ្ធ ដែលនាំអោយមានជីវិតអស់កល្បជានិច្ច[៩] ។

[៣]យ៉ា ២:១៨, ២២ ។ [៤]ទំនុក ១១៦:១២, ១៣ ។ [៥]១យ៉ូន ២:៣, ៥; ២ពេ ១:៥-១១ ។ [៦]ម៉ាថ ៥:១៦ ។ [៧]១ធី ៦:១; ១ពេ ២:១៥; ភី ១:១១ ។ [៨]អេ ២:១០ ។ [៩]រ៉ូម ៦:២២ ។

៣. ពួកគេពុំមានសមត្ថភាពខ្លួនឯង ដើម្បីនឹងធ្វើការល្អទាំងអស់នេះទេ ប៉ុន្តែ ពួកគេបានទទួលសមត្ថភាពសំរាប់ការល្អទាំងនេះ មកពីព្រះវិញ្ញាណនៃព្រះគ្រីស្ទវិញ[១០] ។ ប៉ុន្តែ លើសពីនោះទៅទៀត ព្រះគុណដែលពួកគេបានទទួលពីព្រះនៅគ្រាដំបូងបង្អស់នៃសេចក្តីជំនឿរបស់ពួកគេ នោះពួកគេនៅតែត្រូវការការប៉ះពាល់ពីព្រះថែមទៀត ដើម្បីអោយពួកគេមានសមត្ថភាព ព្រមទាំងធ្វើអោយពួកគេមានចិត្តចង់ធ្វើកិច្ចការ ដែលគាប់ព្រះហឫទ័យដល់ទ្រង់[១១] ។ ប៉ុន្តែ បើព្រះវិញ្ញាណមិនបានប៉ះពាល់ពួកគេទេ នោះមិនមានន័យថា ពួកគេត្រូវតែធ្វេសប្រហែសចំពោះទំនួលខុសត្រូវរបស់គេនោះឡើយ ។ ពីព្រោះពួកគេត្រូវតែប្រុងប្រយ័ត្ន និងឧស្សាហ៍ ហើយ កកូរព្រះគុណដែលមាននៅក្នុងពួកគេ អោយមានសកម្មភាពឡើង[១២] ។

[១០]យ៉ូន ១៥:៤, ៥ ។ [១១]២កូ ៣:៥; ភី ២:១៣ ។ [១២]ភី ២:១២; ហេ ៦:១១, ១២; អេសា ៦៤:៧ ។

៤. ទោះជាមនុស្សដែលបានស្តាប់បង្គាប់ ហើយបានចំរើនឡើងកាន់តែខ្ពស់បំផុតតាមការដែលគេអាចធ្វើបាននៅក្នុងជីវិតនេះក៏ដោយ ក៏ពួកគេមិនអាចធ្វើគ្រប់ទាំងការទាមទាររបស់ព្រះបានដែរ ។ ពួកគេនៅខ្វះចន្លោះច្រើនណាស់ចំពោះកាតព្វកិច្ចដែលពួកគេគួរធ្វើ[១៣] ។

[១៣]យ៉ូប ៩:២; ៣; កា ៥:១៧; លូ ១៧:១០ ។

៥. ការប្រព្រឹត្តិដ៏ល្អបំផុតរបស់យើង មិនអាចរកអោយបានការអត់ទោសបាប ឬ ការប្រទានអោយមានជីវិតអស់កល្បជានិច្ចពីព្រះហស្តនៃព្រះជាម្ចាស់បានទេ គឺដោយសារតែមានភាពមិនស្មើគ្នាដ៏ធំធេង រវាងការប្រព្រឹត្តិដ៏ល្អបំផុតរបស់យើងនិងសិរីរុងរឿងដែលត្រូវមក ហើយនិងគំលាតដ៏វែងគ្មានព្រំខណ្ឌរវាងយើងនិងព្រះ ។ ការប្រព្រឹត្តិដ៏ល្អបំផុតរបស់យើង មិនអាចនឹងផ្តល់ជាកំរៃ ឬ ធ្វើអោយគ្រប់គ្រាន់សំរាប់បំណុលនៃអំពើបាបរបស់យើងបានឡើយ[១៤] ។ ពិតមែនហើយ នៅពេលដែលយើងបានបំពេញ គ្រប់ទាំងការល្អដែលយើងអាចធ្វើបាន នោះយើងគ្រាន់តែបំពេញកាតព្វកិច្ចរបស់យើង ជាបាវបំរើប៉ុណ្ណោះ ។ យើងគួរចងចាំផងដែរថា ការដែលយើងអាចធ្វើការល្អរបស់យើងបាន នោះគឺជាផលដែលកើតចេញពីកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ[១៥] ។ បើយើងបំពេញការងារល្អទាំងនោះបានដោយខ្លួនឯង នោះវានឹងច្របូកច្របល់បញ្ចូលគ្នាជាមួយភាពកំសោយ និងភាពមិនគ្រប់លក្ខណ៍ជាមិនខាន ។ មិនតែប៉ុណ្ណោះ កិច្ចការនោះ មិនអាចទ្រាំទ្រ នឹងការជំនុំជំរះដ៏ខ្លាំងក្លារបស់ព្រះជាម្ចាស់បានឡើយ[១៦] ។

[១៤]រ៉ូម ៣:២០; អេ ២:៨, ៩; រ៉ូម ៤:៦ ។ [១៥]កា ៥:២២, ២៣ ។ [១៦]អេសា ៦៤:៦; ទំនុក ១៤៣:២ ។

៦. ប៉ុន្តែ ព្រះជាម្ចាស់ នឹងទទួលស្គាល់កិច្ចការល្អរបស់អ្នកជឿតាមរយៈព្រះគ្រីស្ទ ដូចគ្នាទៅនឹងការដែលព្រះគ្រីស្ទបានទទួលស្គាល់ពួកគេយ៉ាង

ដូច្នោះដែរ[១៧] ។ ដូច្នេះ មិនមែនមានន័យថា ពួកអ្នកជឿទាំងអស់ជាមនុស្សដែលគ្មានកំហុសសោះ ហើយមិនអាចបន្ទោសបាននៅចំពោះព្រះភ័ក្ត្ររបស់ព្រះនោះទេ តែទ្រង់បានទតមើលទៅលើពួកគេនៅក្នុងព្រះរាជបុត្រារបស់ទ្រង់នោះវិញ ។ ទ្រង់សព្វព្រះទ័យទទួលស្គាល់ និងប្រទានរង្វាន់ដល់ភាពស្មោះត្រង់ ទោះបើការនោះមានសេចក្តីកំសោយ និងភាពមិនគ្រប់លក្ខណ៍ក៏ដោយ[១៨] ។

[១៧]អេ ១:៦; ១ពេ ២:៥ ។ [១៨]ម៉ាថ ២៥:២១, ២៣; ហេ ៦:១០ ។

៧. ចំពោះការល្អផ្សេងៗ ដែលបានបំពេញដោយមនុស្សដែលមិនបានកើតជាថ្មី ទោះបីជាពួកគេបានធ្វើតាមអ្វីដែលព្រះជាម្ចាស់បានបង្គាប់ក្តី ហើយការល្អនោះសំរាប់ខ្លួនឯងនិងសំរាប់អ្នកដទៃក្តី[១៩] ប៉ុន្តែប្រសិនបើកិច្ចការនោះមិនបានកើតចេញពីចិត្តដោយសេចក្តីជំនឿទេ[២០] នោះក៏មិនបានសំរេចកិច្ចការដោយត្រឹមត្រូវ តាមព្រះបន្ទូលដែរ[២១] ព្រោះគោលបំណងសំខាន់របស់ពួកគេ គឺមិនដើម្បីថ្វាយសិរីល្អដល់ព្រះ[២២] ។ ដូចនេះ ពួកគេជាមនុស្សមានបាប ហើយមិនអាចជាទីគាប់ព្រះទ័យដល់ព្រះបានឡើយ ហើយពួកគេក៏មិនអាចនឹងជួយដល់ខ្លួនឯង ដើម្បីធ្វើអោយស័ក្តិសមនឹងទទួលយកព្រះគុណរបស់ព្រះបានដែរ[២៣] ។ យ៉ាងណាមិញ ប្រសិនបើពួកគេធ្វេសប្រហែសមិនបានធ្វើការល្អនោះវិញ នោះពួកគេកាន់តែមានបាប ហើយរិតតែធ្វើអោយព្រះមិនសព្វព្រះហឫទ័យកាន់តែខ្លាំងឡើងថែមទៀត[២៤] ។

[១៩]២ពង្ស ១០:៣០; ១ពង្ស ២១:២៧, ២៩ ។ [២០]លោក ៤:៥; ហេ ១១:៤, ៦ ។ [២១]១កូ ១៣:១ ។ [២២]ម៉ាថ ៦:២, ៥ ។ [២៣]អេម ៥:២១, ២២; រ៉ូម ៩:១៦; ទីត ៣:៥ ។ [២៤]យ៉ូប ២១:១៤, ១៥; ម៉ាថ ២៥:៤១-៤៣ ។

# ជំពូក ១៧
# សេចក្ដីខ្ជាប់ខ្ជួននៃពួកបរិសុទ្ធ

១. ពួកបរិសុទ្ធ គឺជាពួកអ្នកដែលព្រះជាម្ចាស់បានទទួលដោយសេចក្ដីស្រឡាញ់ និងបានត្រាស់ហៅមក ហើយបានញែកចេញជាបរិសុទ្ធដោយព្រះវិញ្ញាណរបស់ទ្រង់ ។ ទ្រង់បានប្រទានសេចក្ដីជំនឿដ៏ពិសិដ្ឋដល់អ្នកដែលទ្រង់បានជ្រើសរើសនោះ ។ ពួកគេនឹងមិនដែលធ្លាក់ចេញពីស្ថានភាពនៃព្រះគុណទាំងស្រុងឡើយ តែពួកគេនឹងរឹតតែខ្ជាប់ខ្ជួនឡើងនៅស្ថានភាពដ៏ប្រពៃនេះ រហូតដល់ទីបំផុត និងរហូតដល់បានសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច ។ នេះគឺដោយព្រោះតែអំណោយទាន និងការត្រាស់ហៅរបស់ព្រះជាម្ចាស់ដែលមិនចេះប្រែព្រះទ័យ ។ ដូច្នេះហើយបានជាទ្រង់នៅតែថែរក្សា ហើយផ្គត់ផ្គង់ពួកគេ អោយរីកចំរើនឡើងក្នុងសេចក្ដីជំនឿ ការប្រែចិត្ត សេចក្ដីស្រឡាញ់ សេចក្ដីអំណរ សេចក្ដីសង្ឃឹម និងគ្រប់ទាំងព្រះគុណនៃព្រះវិញ្ញាណដែលមិនចេះស្លាប់វិញ[១] ។ ថ្វីបើពួកបរិសុទ្ធរបស់ព្រះជួបប្រទះនឹងសេចក្ដីទុក្ខលំបាក ដែលកើតឡើងទាស់នឹងជីវិតរបស់ពួកគេជាខ្លាំងដូចជា ខ្យល់ព្យុះ និងទឹក

ជំនន់ កើតឡើងមកលើពួកគេក៏ដោយ ក៏មិនអាចបក់ផាត់ពួកគេចេញពីគ្រឹះដ៏រឹងមាំនៃថ្មជ្រុងយ៉ាងឯក ដែលបានដាំទុកក្នុងសេចក្តីជំនឿរបស់ពួកគេបានដែរ ។ ប៉ុន្តែតាមរយៈការមិនជឿ និងសេចក្តីល្បួងរបស់សាតាំង ពន្លឺ និងសេចក្តីស្រលាញ់ត្រូវបានងងឹតបិទបាំងមួយរយៈ[២] ប៉ុន្តែព្រះជាម្ចាស់ទ្រង់នៅតែដដែល ហើយពួកគេប្រាកដថា ពួកគេត្រូវបានថែរក្សាដោយអំណាចព្រះចេស្តារបស់ព្រះ រហូតដល់ពួកគេអរសប្បាយនឹងមរតករបស់ខ្លួន ដោយព្រោះឈ្មោះរបស់ពួកគេ ត្រូវបានកត់ទុកនៅក្នុងព្រះហស្ត និងនៅក្នុងបញ្ជីជីវិតរបស់ទ្រង់ រហូតដល់អស់កល្បជានិច្ចហើយ[៣] ។

[១]យ៉ូន ១០:២៨, ២៩; ភី ១:៦; ២ធី ២:១៩; ១យ៉ូន ២:១៩ ។ [២]ទំនុក ៨៩:៣១, ៣២; ១កូ ១១:៣២ ។ [៣]ម៉ាឡ ៣:៦ ។

២. សេចក្តីខ្ជាប់ខ្ជួននៃពួកបរិសុទ្ធ មិនមែនដោយអាងលើខ្លួនរបស់ពួកគេឡើយ មានន័យថា ពួកគេមិនមែនអាងលើឆន្ទៈសេរីរបស់ពួកគេនោះទេ ។ តាមពិតទៅ ការនេះគឺអាស្រ័យទៅលើភាពមិនប្រែប្រួលនៃព្រះរាជឱង្ការនៃការជ្រើសរើសរបស់ព្រះវិញ[៤] ។ ព្រះរាជឱង្ការនៃការជ្រើសរើសនេះ បានហូរចេញពីសេចក្តីស្រឡាញ់ដ៏មានសេរីភាព និងមិនចេះផ្លាស់ប្តូររបស់ព្រះដ៏ជាព្រះវរបិតា ។ ហើយ វាក៏ត្រូវពឹងអាងទៅលើសេចក្តីល្អ និងការទូលអង្វរជំនួសរបស់ព្រះគ្រីស្ទ ព្រមទាំងការរួមសហភាពនៃពួកបរិសុទ្ធជាមួយទ្រង់ដែរ[៥] ។ លើសពីនេះទៅទៀត ការខ្ជាប់ខ្ជួនរបស់ពួកគេ ត្រូវពឹងលើព្រះបន្ទូលសន្យារបស់ព្រះ[៦] និង វត្តមាន

នៃព្រះវិញ្ញាណរបស់ទ្រង់ ហើយនិងគ្រាប់ពូជរបស់ព្រះដែលនៅក្នុងជីវិតពួកគេ[៧] ព្រមទាំងកិច្ចព្រមព្រៀងនៅក្នុងសេចក្តីសញ្ញានៃព្រះគុណរបស់ព្រះ[៨] ។ គ្រប់ការទាំងអស់នេះបានធានានូវភាពពិតប្រាកដ និងភាពមិនចេះបរាជ័យនៃសេចក្តីខ្ជាប់ខ្ជួនរបស់ពួកបរិសុទ្ធ ។

[៤]រ៉ូម ៨:៣០; ៩:១១, ១៦ ។ [៥]រ៉ូម ៥:៩, ១០; យ៉ូន ១៤:១៩ ។ [៦]ហេ ៦:១៧, ១៨ ។ [៧]១យ៉ូន ៣:៩ ។ [៨]យេ ៣២:៤០ ។

៣. តាមរយៈសេចក្តីល្បួងរបស់អារក្សសាតាំង លោកិយ និង ការសេសសល់នៃសេចក្តីពុករលួយនៅក្នុងពួកគេ ព្រមទាំងការធ្វេសប្រហែសពីរបៀបនៃសេចក្តីខ្ជាប់ខ្ជួន ពួកបរិសុទ្ធនៃព្រះអាចនឹងធ្លាក់ទៅក្នុងអំពើបាបដ៏ធំ ហើយ អាចនឹងបន្តនៅក្នុងអំពើបាបនោះមួយរយៈ[៩] ។ ដូចនេះហើយ ពួកគេអាចនឹងធ្វើអោយព្រះមិនសប្បាយព្រះហឫទ័យ ហើយ អាចនឹងធ្វើអោយព្រះវិញ្ញាណបរិសុទ្ធមានព្រះហឫទ័យព្រួយ[១០] ហើយនឹងធ្វើអោយព្រះគុណ និងសេចក្តីកំសាន្តចិត្តធ្លាក់ចុះខ្សោយ[១១] ហើយពួកគេ នឹងធ្វើ អោយចិត្តខ្លួនឯងរឹងទទឹង ហើយអាច នឹងធ្វើអោយបញ្ញាចិត្តមិនខ្វល់ពីអំពើបាប[១២] ហើយ ថែមទាំងធ្វើអោយអ្នកដទៃមានការឈឺចាប់ និងប៉ះទង្គិចទៀតផង ។ តាមរយៈការទាំងនេះ ពួកគេនឹងទទួលការដាក់ទោសបណ្តោះអាសន្ន[១៣] ។ ប៉ុន្តែនៅទីបំផុត បើពួកគេជាពួកបរិសុទ្ធពិតប្រាកដមែន នោះពួកគេនឹងបានកែជាថ្មីឡើងតាមរយៈសេចក្តីជំនឿលើព្រះគ្រីស្ទយេស៊ូវ ហើយពួកគេនឹងត្រូវបានទទួលការថែរក្សា រហូតដល់ទីបញ្ចប់[១៤] ។

[៩]ម៉ាថ ២៦:៧០, ៧២, ៧៤ ។ [១០]អេសា ៦៤:៥, ៩; អេ ៤:៣០ ។ [១១]ទំនុក ៥១:១០, ១២ ។ [១២]ទំនុក ៣២:៣, ៤ ។ [១៣] ២សាំ ១២:១៤ ។ [១៤]លូ ២២:៣២, ៦១, ៦២ ។

# ជំពូក ១៨
# ការដឹងច្បាស់ អំពីព្រះគុណ និង សេចក្តីសង្គ្រោះ

១. ទោះបីជាពួកអ្នកជឿបណ្តោះអាសន្ន និងមនុស្សដែលមិនកើតជាថ្មី អាចនឹងបញ្ឆោតខ្លួនឯងដោយសេចក្តីសង្ឃឹមក្លែងក្លាយ និងការសន្មត់ដ៏អាក្រក់របស់ពួកគេ ថាជាទីគាប់ព្រះហឫទ័យដល់ព្រះនិងបានសង្គ្រោះក៏ដោយ តែតាមពិតសេចក្តីសង្ឃឹមរបស់គេនេះ នឹងត្រូវវិនាសវិញ[១] ។ ផ្ទុយទៅវិញ អស់អ្នកណាដែលជឿលើព្រះអម្ចាស់យេស៊ូវពិតប្រាកដ និងស្រឡាញ់ទ្រង់ដោយស្មោះត្រង់ ហើយអស់អ្នកណាដែលព្យាយាមដើរក្នុងសេចក្តីជំនឿបានល្អនៅចំពោះទ្រង់ នោះពួកគេនឹងដឹងជាប្រាកដនៅក្នុងជីវិតគេថា ពួកគេកំពុងតែស្ថិតនៅក្នុងព្រះគុណទ្រង់ហើយ ហើយនឹងបានអរសប្បាយ នៅក្នុងសេចក្តីសង្ឃឹមនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់[២] ។ សេចក្តីជំនឿនេះ មិនដែលនាំអោយពួកគេមានសេចក្តីអាម៉ាស់ឡើយ[៣] ។

[១]យ៉ូប ៨:១៣, ១៩; ម៉ាថ ៧:២២, ២៣ ។ [២]១យ៉ូន ២:៣; ៣:១៤, ១៨, ១៩, ២១, ២៤; ៥:១៣ ។ [៣]រ៉ូម ៥:២, ៥ ។

២. សេចក្តីពិតនៃសេចក្តីសង្គ្រោះនេះ មិនមែនជាការស្រមើស្រមៃដោយផ្អែកលើសេចក្តីសង្ឃឹមក្លែងក្លាយនោះទេ ប៉ុន្តែ វាគឺជាការដឹងយ៉ាងពិតប្រាកដមួយនៃសេចក្តីជំនឿ[៤] ដែលបានទទួលមកតាមរយៈព្រះលោហិត និង សេចក្តីសុចរិតរបស់ព្រះគ្រីស្ទ ដែលបានបើកសំដែងក្នុងដំណឹងល្អវិញ[៥] ។ ការនេះក៏បានរកឃើញភស្តុតាងខាងក្នុងនៃព្រះគុណរបស់ព្រះវិញ្ញាណ ដែលមានទំនាក់ទំនងជាមួយនឹងសេចក្តីសន្យា[៦] ក្នុងព្រះគម្ពីរបរិសុទ្ធដែរ ហើយព្រមទាំងទីបន្ទាល់នៃព្រះវិញ្ញាណនៃការទទួលទុកជាកូនចិញ្ចឹម ដែលធ្វើបន្ទាល់ជាមួយនឹងវិញ្ញាណរបស់យើងថា យើងទាំងអស់គ្នាជាកូនរបស់ព្រះផង[៧] ។ លទ្ធផលនៃទីបន្ទាល់នៃការដឹងច្បាស់នេះគឺដើម្បីរក្សាចិត្តរបស់យើងអោយបានបរិសុទ្ធ និងបន្ទាបខ្លួនជានិច្ច[៨] ។

[៤]ហេ ៦:១១, ១៩ ។ [៥]ហេ ៦:១៧, ១៨ ។ [៦] ២ពេ ១:៤, ៥, ១០, ១១ ។ [៧]រ៉ូម ៨:១៥, ១៦ ។ [៨]១យ៉ូន ៣:១-៣ ។

៣. ការដឹងច្បាស់ពីសេចក្តីសង្គ្រោះ គឺមិនមែនជាផ្នែកចាំបាច់នៃសេចក្តីសង្គ្រោះទេ ពីព្រោះអ្នកជឿពិតប្រាកដម្នាក់អាចនឹងរងចាំក្នុងរយៈពេលយ៉ាងយូរ ហើយតស៊ូជាមួយនឹងការលំបាកៗជាច្រើន មុនពេលដែលគាត់បានទទួលការដឹងច្បាស់[៩] ។ ប៉ុន្តែគាត់មិនត្រូវការការបើកសំដែងបន្ថែមទៀត ដើម្បីអោយទទួលបានការដឹងច្បាស់ ពីសេចក្តីសង្គ្រោះនោះទេ ។ ប្រសិនបើ គាត់ចេះប្រើប្រាស់របៀបនៃការទទួលព្រះគុណ

ដោយត្រឹមត្រូវហើយ ហើយប្រសិនបើព្រះវិញ្ញាណជួយគាត់ អោយយល់អំពីការនានាដែលអ្នកជឿបានទទួលពីព្រះហើយ[១០] នោះគាត់នឹងយល់ច្បាស់ ។ ដូច្នេះ នោះគឺជាកាតព្វកិច្ចរបស់គ្រប់គ្នា ដែលត្រូវតែឧស្សាហ៍ព្យាយាមបំផុត តាមការដែលអាចធ្វើទៅបាន ដើម្បីធ្វើអោយដឹងយ៉ាងច្បាស់ពីការត្រាស់ហៅ និងការជ្រើសរើសរបស់គាត់ ។ ដោយធ្វើការទាំងអស់នេះ គាត់នឹងមានបទពិសោធន៍ ទទួលនូវសេចក្ដីសុខសាន្ដ និង សេចក្ដីអំណរនៅក្នុងព្រះវិញ្ញាណបរិសុទ្ធកាន់តែច្រើនឡើង ហើយ គាត់នឹងកាន់តែមានសេចក្ដីស្រលាញ់ និងការអរព្រះគុណដល់ព្រះ ហើយនិងកំលាំង ព្រមទាំងភាពសប្បាយរីករាយ នៅក្នុងការស្ដាប់បង្គាប់ផង ។ ការទាំងអស់នេះ គឺជាលទ្ធផលធម្មតានៃការដឹងច្បាស់ពីសេចក្ដីសង្គ្រោះ[១១] ហើយពួកគេបង្ហាញយ៉ាងច្បាស់ថា ការដឹងច្បាស់នេះមិននាំមនុស្សទៅក្នុងការរស់នៅដ៏ធូររលុងនោះទេ[១២] ។

[៩]អេសា ៥០:១០; ទំនុក ៨៨; ទំនុក ៧៧:១-១២ ។ [១០]១យ៉ូន ៤:១៣; ហេ ៦:១១, ១២ ។ [១១]រ៉ូម ៥:១, ២, ៥; ១៤:១៧; ទំនុក ១១៩:៣២ ។ [១២]រ៉ូម ៦:១, ២; ទីត ២:១១, ១២, ១៤ ។

៤. អ្នកជឿពិតប្រាកដ ជួនកាលអាចនឹងមានអារម្មណ៍ថាខ្សោយ ហើយជួនកាល គេមានអារម្មណ៍ថាខ្លាំង ចំពោះការដឹងច្បាស់នៃសេចក្ដីសង្គ្រោះរបស់ពួកគេ ។ ពួកគេអាចនឹងមានការធ្វេសប្រហែស[១៣] ក្នុងការថែរក្សាអំពីការដឹងច្បាស់របស់ពួកគេ ។ ឧទាហរណ៍ ប្រសិនពួកគេធ្លាក់ចុះទៅក្នុងអំពើបាប ដែលធ្វើអោយប៉ះទង្គិចដល់បញ្ញាចិត្តរបស់ខ្លួន

ហើយធ្វើអោយព្រះវិញ្ញាណព្រួយព្រះហឫទ័យ[១៤] ឬសេចក្តីល្បួងដ៏ខ្លាំងភ្លាមៗ[១៥] ឬ ដោយព្រោះព្រះបានដកពន្លឺរបស់ទ្រង់ចេញ ហើយធ្វើអោយសេចក្តីងងឹត[១៦] ចូលមកគ្របបាំងពួកគេ ។ ជួនកាលទ្រង់ធ្វើយ៉ាងដូច្នេះ ទោះបីជាពួកគេជាអ្នកដែលកោតខ្លាចទ្រង់ក៏ដោយ ។ ប៉ុន្តែ ព្រះមិនដែលដកគ្រាប់ពូជរបស់ព្រះ[១៧] និងជីវិតនៃសេចក្តីជំនឿពីកូនរបស់ទ្រង់ឡើយ[១៨] ។ ដោយហេតុនោះហើយ បានជាយើងអាចស្រឡាញ់ព្រះគ្រីស្ទ និងបងប្អូនប្រុសស្រីរបស់យើងដោយអស់ពីចិត្តបាន ។ ការនេះគឺជាកាតព្វកិច្ចខាងឯព្រលឹងវិញ្ញាណរបស់ពួកគេ តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ ការដឹងច្បាស់នេះ អាចនឹងត្រឡប់មកដូចដើមវិញក្នុងពេលដ៏សមស្ងួនមួយ[១៩] ហើយនៅចន្លោះពេលនោះ វត្តមាននៃព្រះគុណទាំងអស់នេះ នឹងការពារពួកគេមិនអោយអស់សង្ឃឹមឡើយ[២០] ។

[១៣]បទ ៥:២, ៣, ៦ ។ [១៤]ទំនុក ៥១:៨, ១២, ១៤ ។ [១៥]ទំនុក ១១៦:១១; ៧៧:៧, ៨; ៣១:២២ ។ [១៦]ទំនុក ៣០:៧ ។ [១៧]១យ៉ូន ៣:៩ ។ [១៨]លូ ២២:៣២ ។ [១៩]ទំនុក ៤២:៥, ១១ ។ [២០]បរិ ៣:២៦-៣១ ។

# ជំពូក ១៩
# ក្រិត្យវិន័យរបស់ព្រះជាម្ចាស់

១. ព្រះជាម្ចាស់បានប្រទានច្បាប់ទូទៅនៃការស្តាប់បង្គាប់មួយទៅអ័ដាម ដែលបានកត់ត្រាទុកនៅក្នុងចិត្តរបស់គាត់ ហើយនិងច្បាប់ពិសេសមួយ ដែលហាមមិនអោយគាត់បរិភោគផ្លែឈើដឹងខុសត្រូវ[១] ។ ព្រះទ្រង់បាន តំរូវអោយអ័ដាម និង ពូជពង្សរបស់គាត់ទាំងអស់បានស្តាប់បង្គាប់ ដោយផ្ទាល់ខ្លួន ទាំងស្រុង យ៉ាងពិតប្រាកដ និងបន្តឥតឈប់ឈរ[២] ។ ទ្រង់បានសន្យាថានឹងប្រទានជីវិត ប្រសិនបើ ស្តាប់បង្គាប់តាម ក្រិត្យវិន័យរបស់ទ្រង់ ហើយទ្រង់បានគំរាមថានឹងប្រទានសេចក្តីស្លាប់ វិញ ប្រសិនបើមិនស្តាប់បង្គាប់តាមក្រិត្យវិន័យរបស់ទ្រង់ ។ ហើយ ព្រះជាម្ចាស់ក៏បានប្រទានអំណាច និងសមត្ថភាពគ្រប់គ្រាន់អោយដល់ អ័ដាម ដើម្បីរក្សាច្បាប់នោះផងដែរ[៣] ។

[១]លោក ១:២៧; សាស ៧:២៩ ។ [២]រ៉ូម ១០:៥ ។ [៣]កា ៣:១០, ១២ ។

២. ច្បាប់ដដែល ដែលបានសរសេរជាលើកដំបូងនៅក្នុងចិត្តរបស់ មនុស្សនេះ បានបន្តទៅជាច្បាប់គ្រប់លក្ខណ៍នៃសេចក្តីសុចរិតមួយ បន្ទាប់ពីការធ្វើបាបជាលើកដំបូង[៤] ។ ហើយ ព្រះបានប្រទានច្បាប់នោះ មកនៅលើភ្នំ ស៊ីណាយដែលយើងហៅថា ក្រិត្យវិន័យទាំង១០ប្រការ ។ ក្រិត្យវិន័យទាំងអស់នោះ បានចារនៅលើបន្ទះថ្មពីរផ្ទាំង ដែល៤ចំនុច

ដំបូង ប្រាប់ពីកិច្ចការដែលយើងត្រូវធ្វើចំពោះព្រះ និង៦ចំនុចផ្សេងទៀត ប្រាប់ពីកិច្ចការដែលយើងត្រូវធ្វើចំពោះមនុស្ស[៥] ។

[៤]រ៉ូម ២:១៤, ១៥ ។ [៥]ចោទិ ១០:៤ ។

៣. ក្រៅពីក្រិត្យវិន័យទាំងដប់ដែលហៅថាច្បាប់សីលធម៌នេះ ព្រះទ្រង់បានសព្វព្រះហឫទ័យប្រទានដល់ពួកអ៊ីស្រាអែល នូវច្បាប់នៃពិធីផ្សេងៗដែរ ដែលជាច្បាប់បង្ហាញ អំពីអ្វីៗដែលនឹងត្រូវកើតឡើងនៅពេលខាងមុខ ។ ច្បាប់នៃពិធីនានានេះ ចែកចេញជាពីរក្រុមសំខាន់ៗគឺក្រុមទីមួយផ្តោតជាសំខាន់ទៅលើការថ្វាយបង្គំ ដែលសំដែងពីព្រះគ្រីស្ទ ព្រះគុណ សកម្មភាពនានា ការរងទុក្ខ និងគុណប្រយោជន៍ដែលទ្រង់រកបានសំរាប់យើង[៦] ។ ហើយនៅក្រុមទីពីរ ផ្តោតជាសំខាន់ទៅលើសេចក្តីណែនាំផ្សេងៗ ដែលទាក់ទងទៅនឹងកាតព្វកិច្ច ដែលប្រកបដោយសីលធម៌របស់យើង[៧] ។ ច្បាប់នៃពិធីផ្សេងៗទាំងអស់នេះ បានតាំងឡើងដរាបដល់វេលាដែលច្បាប់ទាំងអស់នោះ បានលុបចោលនៅសម័យសញ្ញាថ្មី ដោយព្រះយេស៊ូវគ្រីស្ទដែលជាព្រះម៉ែស៊ីដ៏ពិតប្រាកដ និង ជាអ្នកប្រទានច្បាប់ទាំងនោះមក ។ ដូច្នេះ ទ្រង់បានទទួលអំណាចពីព្រះវរបិតា ដើម្បីលុបចោលច្បាប់នៃពិធីទាំងនោះចេញ[៨] ។

[៦]ហេ ១០:១; កូល ២:១៧ ។ [៧]១កូ ៥:៧ ។ [៨]កូល ២:១៤, ១៦, ១៧; អេ ២:១៤, ១៦ ។

៤. ទ្រង់ក៏បានប្រទានផងដែរ នូវច្បាប់កាត់ក្តីមួយចំនួន ដល់ពួកអ៊ីស្រាអែល តែវាអស់សុពលភាពហើយ ហើយច្បាប់នេះក៏មិនត្រូវបានយកមកអនុវត្តនៅសម័យបច្ចុប្បន្ននេះទៀតដែរ ។ ប៉ុន្តែ គោលការណ៍សុចរិតនៃច្បាប់កាត់ក្តីនៅតែបន្តប្រើជាប្រយោជន៍ នៅក្នុងជីវិតនាពេលបច្ចុប្បន្ននេះវិញ[៩] ។

[៩]១កូ ៩:៨-១០ ។

៥. ការស្តាប់បង្គាប់តាមច្បាប់នៃសីលធម៌ “ក្រិត្យវិន័យទាំងដប់ប្រការ” តំរូវអោយមនុស្សទាំងអស់បានស្តាប់តាម សូម្បីតែអស់អ្នកដែលរាប់ជាសុចរិតដោយសារជំណឿងល្អក៏ដោយ[១០] ។ យើងត្រូវគោរពដល់ខ្លឹមសារនានាដែលនៅក្នុងច្បាប់នោះ ហើយ ត្រូវគោរពដល់អំណាចរបស់ព្រះអាទិករដែលទ្រង់ជាអ្នកនិពន្ធច្បាប់នោះដែរ[១១] ។ នៅក្នុងជំណឿងល្អ ព្រះគ្រីស្ទមិនបានលុបចោលក្រិត្យវិន័យទាំងដប់ប្រការនេះទេ តែផ្ទុយទៅវិញ ទ្រង់បានផ្តោតសង្កត់ធ្ងន់យ៉ាងខ្លាំង ចំពោះករណីយកិច្ចដែលយើងត្រូវស្តាប់បង្គាប់តាមវិញ[១២] ។

[១០]រ៉ូម ១៣:៨-១០; យ៉ា ២:៨, ១០-១២ ។ [១១]យ៉ា ២:១០, ១១ ។ [១២]ម៉ាថ ៥:១៧-១៩, រ៉ូម ៣:៣១ ។

៦. ថ្វីបើ អ្នកជឿពិតប្រាកដមិនឋិតនៅក្រោមក្រិត្យវិន័យដូចជាសេចក្តីសញ្ញានៃការប្រព្រឹត្តិ ដើម្បីអោយបានរាប់ជាសុចរិត ឬត្រូវជាប់ទោសដោយសារវា[១៣] ក៏ដោយ ប៉ុន្តែវាគឺជាការប្រើប្រាស់ដ៏មានសារៈ

ប្រយោជន៍ចំពោះពួកគេ និងអ្នកដទៃផ្សេងទៀតដែរ ដោយព្រោះថា ក្រិត្យវិន័យដែលគ្រប់គ្រងជីវិតនោះ នឹងប្រាប់ពួកគេអោយដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កាតព្វកិច្ចរបស់ពួកគេ ការតំរង់ផ្លូវ និងការចងពួកគេអោយដើរបានត្រឹមត្រូវ ។ វាក៏ជួយពួកគេអោយដឹងពីភាពកខ្វក់ដែលពោរពេញដោយអំពើបាបនៃនិស្ស័យ ជីវិត និងចិត្តរបស់ពួកគេ ហើយក៏ប្រើការនោះសំរាប់ការពិនិត្យមើលខ្លួនឯងផងដែរ ។ ពួកគេអាចនឹងឈប់ប្រព្រឹត្តអំពើបាប ហើយមានចិត្តបន្ទាបខ្លួន និងមានសេចក្តីសំអប់ចំពោះអំពើនេះយ៉ាងខ្លាំងវិញ[១៩] ។ មួយវិញទៀត ពួកគេនឹងមើលឃើញកាន់តែច្បាស់ឡើងថា ពួកគេត្រូវការព្រះគ្រីស្ទ និងការស្តាប់បង្គាប់ដ៏គ្រប់លក្ខណ៍របស់ទ្រង់ចំពោះក្រិត្យវិន័យ ។ ស្រដៀងគ្នានេះដែរ ក្រិត្យវិន័យប្រើសំរាប់ នឹងធ្វើអោយមនុស្សដែលបានកើតជាថ្មីចេះទប់ស្កាត់អំពើអាក្រក់របស់ពួកគេ ដោយព្រោះក្រិត្យវិន័យបានហាមប្រាមគេមិនអោយធ្វើបាប ។ ការគំរាមនៃក្រិត្យវិន័យ បង្ហាញពីអ្វីដែលអំពើបាបសមទទួល ។ បញ្ហានានាដែលពួកគេមិនស្តាប់បង្គាប់ នឹងកើតមានឡើងនៅក្នុងជីវិតរបស់ពួកគេ ទោះបីអ្នកជឿមានសេរីភាពរួចពីបណ្តាសា និង ភាពតឹងរឹងនៃក្រិត្យវិន័យក៏ដោយ ។ សេចក្តីសន្យានៃក្រិត្យវិន័យទាំងអស់នេះ ក៏បង្ហាញដល់ពួកគេផងដែរ អំពីការគាំទ្ររបស់ព្រះចំពោះការស្តាប់បង្គាប់ និង ព្រះពរដែលបានរំពឹងទុក ប្រសិនបើពួកគេស្តាប់បង្គាប់តាម ។ ប៉ុន្តែពួកគេមិនអាចទទួលការសង្គ្រោះ ដោយការស្តាប់បង្គាប់ដែលជាសេចក្តីសញ្ញានៃការប្រព្រឹត្តិឡើយ ។ ប្រសិនបើមនុស្សម្នាក់ពិតជាធ្វើការល្អ ហើយមិនប្រព្រឹត្តិការអាក្រក់ទៀត ដោយ

ព្រោះក្រិត្យវិន័យជំរុញគាត់ នោះមិនមានន័យថា គាត់នៅក្រោមក្រិត្យវិន័យឡើយ ប៉ុន្តែគាត់ពិតប្រាកដជានៅក្រោមព្រះគុណរបស់ព្រះវិញ[១៥] ។

[១៣]រ៉ូម ៦:១៤; កា ២:១៦; រ៉ូម ៨:១; ១០:៤ ។ [១៤]រ៉ូម ៣:២០; ៧:៧ ។ [១៥]រ៉ូម ៦:១២-១៤; ១ពេ ៣:៨-១៣ ។

៧. ចំនុចផ្សេងៗខាងលើបាននិយាយរួចហើយថា ប្រយោជន៏នៃក្រិត្យវិន័យ គឺមិនផ្ទុយនឹងព្រះគុណនៃដំណឹងល្អទេ ប៉ុន្តែពួកវាមានលក្ខណៈស្របគ្នាវិញ[១៦] ។ វិញ្ញាណរបស់ព្រះគ្រីស្ទបានឈ្នះ ហើយធ្វើអោយឆន្ទៈរបស់មនុស្ស អាចស្តាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះបាន ដោយអស់ពីចិត្ត និងដោយចិត្តរីករាយដែលបានបើកសំដែងមក នៅក្នុងក្រិត្យវិន័យដែលបានតំរូវអោយបានសំរេច ។

[១៦]កា ៣:២១; អេសេ ៣៦:២៧ ។

# ជំពូក ២០
# ដំណឹងល្អ និង ឥទ្ធិពលរបស់វា

១. សេចក្តីសញ្ញានៃការប្រព្រឹត្ត ត្រូវបានធ្វើអោយខូចដោយសារអំពើបាប ហើយវាមិនអាចអោយយើងបានទទួលជីវិតទេ ។ ដូច្នេះ ព្រះជាម្ចាស់ទ្រង់បានសព្វព្រះហឫទ័យប្រទានសេចក្តីសន្យា គឺជាព្រះគ្រីស្ទទ្រង់យកកំណើតនឹងព្រហ្មចារិនីម្នាក់ ដែលជាវិធីមួយដើម្បីត្រាស់ហៅអ្នកដែលទ្រង់បានជ្រើសរើស ហើយធ្វើអោយមានសេចក្តីជំនឿ និងការប្រែចិត្ត នៅក្នុងចិត្តរបស់ពួកគេ[១] ។ តាមរយៈ សេចក្តីសន្យានេះបានបង្ហាញ និងសំដែងអោយឃើញពីផ្នែកដ៏សំខាន់នៃដំណឹងល្អថា នោះជាវិធីតែមួយ ដើម្បីធ្វើអោយមនុស្សមានបាបអាចប្រែចិត្ត និងទទួលសេចក្តីសង្គ្រោះបាន[២] ។

[១]លោក ៣:១៥ ។ [២]រ៉ូម ៧:៩ ។

២. សេចក្តីសន្យានៃព្រះគ្រីស្ទ និងសេចក្តីសង្គ្រោះដោយសារទ្រង់ គឺបានសំដែងមកតែពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ[៣] ។ កិច្ចការនៃការបង្កើត និងការទំនុកបំរុង ឬ ពន្លឺធម្មជាតិ ការទាំងនេះមិនបានបង្ហាញអោយយើងឃើញអំពីព្រះគ្រីស្ទ និងព្រះគុណរបស់ទ្រង់ដល់មនុស្សទេ សូម្បីតែ ជារបៀបទូទៅក៏ដោយ[៤] ។ ហើយតាមរបៀបទាំងអស់នេះ ក៏មិនអាចនាំអោយមានសេចក្តីជំនឿដែលបានសង្គ្រោះ ឬ អោយបាន

ការប្រែចិត្តដែរ ពីព្រោះរបៀបទាំងអស់នេះសុទ្ធតែខ្វះការបើកសំដែង អំពីព្រះគ្រីស្ទដោយសេចក្តីសន្យានៃដំណឹងល្អ[៥] ។

[៣]រ៉ូម ១:១៧ ។ [៤]រ៉ូម ១០:១៤, ១៥, ១៧ ។ [៥]សុ ២៩:១៨; អេសា ២៥:៧; ៦០:២, ៣ ។

៣. ការបើកសំដែងនៃដំណឹងល្អចំពោះមនុស្សមានបាប គឺបានសំដែងឡើងតាមសម័យកាល និងទីកន្លែងផ្សេងៗគ្នា ដល់ជាតិសាសន៍ណាមួយ និងមនុស្សណាម្នាក់ ទៅតាមបំណងព្រះហឫទ័យ និងការសព្វព្រះទ័យរបស់ព្រះ[៦] ។ សេចក្តីសន្យានៃការធ្វើអោយស្គាល់ពីដំណឹងល្អនេះ គឺមិនអាស្រ័យលើការដែលមនុស្សពូកែប្រើប្រាស់ដំណឹងល្អទេ ហើយ ក៏មិនអាស្រ័យលើសមត្ថភាពធម្មជាតិរបស់គាត់ ក្នុងការប្រើប្រាស់ព្រះគុណសាមញ្ញរបស់ព្រះនោះដែរ ពីព្រោះព្រះគុណសាមញ្ញមិនអាចធ្វើអោយវាកើតឡើងបានឡើយ[៧] ។ ដូច្នេះ នៅក្នុងសម័យកាលផ្សេងៗគ្នា កំរិតនៃការប្រកាសដំណឹងល្អក៏ផ្សេងៗគ្នាដែរ ជួនកាលវាទៅដល់កន្លែងធំៗ ហើយ ជួនកាលទៅដល់កន្លែងតូចៗចង្អៀត ។ ហើយដំណឹងល្អនេះត្រូវបានផ្តល់អោយដល់មនុស្សណាម្នាក់ និងជាតិសាសន៍ណាមួយមានកំរិតខុសៗគ្នា ដោយអាស្រ័យទៅតាមព្រះទ័យ ដែលប្រកបដោយប្រាជ្ញាញាណរបស់ព្រះ ។

[៦]ទំនុក ១៤៧:២០; កិច្ច ១៦:៧ ។ [៧]រ៉ូម ១:១៨-៣២ ។

៩. ដំណឹងល្អ គឺជាមធ្យោបាយខាងក្រៅតែមួយគត់ ដែលធ្វើអោយមនុស្សបានស្គាល់ព្រះគ្រីស្ទ ហើយនិងព្រះគុណដែលបានសង្គ្រោះ ។ ដំណឹងល្អ មានភាពគ្រប់គ្រាន់ពេញទីសំរាប់គោលបំណងនេះ ។ ប៉ុន្តែមនុស្សបានស្លាប់នៅក្នុងអំពើបាបរបស់ពួកគេរួចទៅហើយ អញ្ចឹងហើយប្រសិនបើមនុស្សនឹងកើតជាថ្មីម្តងទៀត នោះមានន័យថា ពួកគេនឹងត្រូវការអ្វីមួយទៀតដែលលើសពីនោះ ។ ពួកគេត្រូវការ កិច្ចការដ៏សក្តិសិទ្ធិអស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធ ប៉ះពាល់គ្រប់ផ្នែកទាំងអស់នៃវិញ្ញាណរបស់ពួកគេ ដើម្បីបង្កើតជីវិតថ្មី ខាងឯព្រលឹងវិញ្ញាណ[៨] ។ យើងត្រូវការការងារប្រភេទនេះ ដើម្បីអោយបានទទួលនូវការផ្លាស់ប្រែនៅចំពោះព្រះ[៩] ។

[៨]ទំនុក ១១០:៣; ១កូ ២:១៤; អេ ១:១៩, ២០ ។ [៩]យ៉ូន ៦:៤៤; ២កូ ៤:៤, ៦ ។

# ជំពូក ២១
# សេរីភាពរបស់គ្រីស្ទបរិស័ទ និង សេរីភាពនៃបញ្ញាចិត្ត

១. ព្រះគ្រីស្ទបានទិញសេរីភាពដែលមកពីដំណឹងល្អ អោយអ្នកជឿទាំងអស់ ។ សេរីភាពនេះរួមមាន សេរីភាពរួចពីទោសនៃអំពើបាប សេរីភាពរួចផុតពីការថ្កោលទោស សេរីភាពរួចពីសេចក្តីក្រោធរបស់ព្រះ និង សេរីភាពរួចពីបណ្តាសានៃក្រិត្យវិន័យរបស់ព្រះ[១] ។ សេរីភាពនេះ ក៏រួមបញ្ចូលទាំង ការប្រោសអោយរួចពីលោកិយដ៏អាក្រក់នេះ[២] ហើយនិង ពីគ្រប់ទាំងចំណងរបស់អារក្សសាតាំង[៣] ការគ្រប់គ្រងរបស់អំពើបាប[៤] ការឈឺចាប់ដែលមកពីសេចក្តីវេទនា[៥] សេចក្តីភ័យខ្លាចនៃទ្រនិចរបស់សេចក្តីស្លាប់ ជ័យជំនះនៃផ្នូរខ្មោច[៦] ហើយនិង ការវិនាសអន្តរាយដ៏អស់កល្បជានិច្ចផងដែរ[៧] ។ លើសពីនោះទៅទៀត សេរីភាពនេះ ផ្តល់នូវផ្លូវចូលទៅកាន់ឯព្រះ ហើយអោយយើងស្តាប់បង្គាប់ មិនមែនជាការភ័យខ្លាច ដូចជាទាសករនោះទេ[៨] ប៉ុន្តែជាសេចក្តីស្រឡាញ់ដូចជាកូន និង អស់ពីចិត្តវិញ[៩] ។

ពួកអ្នកជឿនៅក្នុងសម័យសញ្ញាចាស់ មានបទពិសោធន៍ក្នុងគ្រប់ទាំងសេរីភាពទាំងអស់នេះ ដោយនៅក្រោមក្រិត្យវិន័យ[១០] ប៉ុន្តែនៅសម័យសញ្ញាថ្មី សេរីភាពរបស់គ្រីស្ទបរិស័ទត្រូវបានពង្រីកវិញ ។ សេរីភាពនៃគ្រីស្ទបរិស័ទសម័យសញ្ញាថ្មីជារួមមាន សេរីភាពរួចពីនឹមនៃ

ក្រិត្យវិន័យនៃពិធីបុណ្យសាសនាដែលក្រុមជំនុំយូដាកាន់តាម ហើយនិង សេចក្តីក្លាហានកាន់តែខ្លាំងឡើង ក្នុងការចូលទៅឯបល្ល័ង្កនៃព្រះគុណ ហើយពួកគេមានព្រះវិញ្ញាណនៃព្រះលើសជាងពួកអ្នកជឿ ដែលនៅមុន សម័យព្រះគ្រីស្ទផង[១១] ។

[១]កា ៣:១៣ ។ [២]កា ១:៤ ។ [៣]កិច្ច ២៦:១៨ ។ [៤]រ៉ូម ៨:៣ ។ [៥]រ៉ូម ៨:២៨ ។ [៦]១កូ ១៥:៥៤-៥៧ ។ [៧]១ថែស ១:១០ ។ [៨]រ៉ូម ៨:១៥ ។ [៩]លូ ១:៧៣-៧៥; ១យ៉ូន ៤:១៨ ។ [១០]កា ៣:៩, ១៤ ។ [១១]យ៉ូន ៧:៣៨, ៣៩; ហេ ១០:១៩-២១ ។

២. ព្រះជាម្ចាស់ផ្ទាល់ ជាព្រះអម្ចាស់នៃបញ្ញាចិត្ត[១២] ។ ទ្រង់បានតាំងបញ្ញាចិត្តនោះឡើង អោយមានសេរីភាពពេញទីពីគោលលទ្ធិទាំងអស់ និងបទបញ្ជានានារបស់មនុស្សដែលអាចនឹងផ្ទុយ ឬក៏ មិនមានចែងនៅក្នុងព្រះបន្ទូលទ្រង់[១៣] ។ ដូច្នេះ ដែលជឿតាមគោលលទ្ធិ និងបទបញ្ជារបស់មនុស្សដោយងងឹតងងុល នោះមានន័យថា ពួកគេកំពុងតែក្បត់ពីបញ្ញាចិត្ត[១៤] ដែលមានសេរីភាពពិតប្រាកដនោះហើយ ។ វាមិនសមហេតុផលហើយ វាគឺជាការវិនាសអន្តរាយដល់សេរីភាពនៃបញ្ញាចិត្តរបស់ពួកគេ នៅពេលណាមនុស្សបានតំរូវអោយអ្នកផ្សេងទៀត បានស្តាប់បង្គាប់តាមដោយងងឹតងងល់[១៥] ។

[១២]យ៉ា ៤:១២; រ៉ូម ១៤:៤ ។ [១៣]កិច្ច ៤:១៩, ២៩; ១កូ ៧:២៣; ម៉ាថ ១៥:៩ ។ [១៤]កូល ២:២០, ២២, ២៣ ។ [១៥]១កូ ៣:៥; ២កូ ១:២៤ ។

៣. អស់អ្នកណាដែលប្រើសេរីភាពនៃគ្រីស្ទបរិស័ទ ទុកជាការដោះសារដើម្បីប្រព្រឹត្តិអំពើបាប ឬក៏ អរសប្បាយជាមួយនឹងសេចក្តីប៉ងប្រាថ្នាខាងអំពើបាបណាមួយ នោះពួកគេធ្វើអោយខូចគោលបំណងដ៏សំខាន់នៃព្រះគុណពីដំណឹងល្អហើយ ។ យ៉ាងនោះ ពួកគេនឹងទទួលនូវការបំផ្លាញ ដែលធ្លាក់មកលើខ្លួនឯងវិញ[១៦] ។ មានន័យថា ពួកគេបំផ្លាញទាំងស្រុងនូវគោលបំណងនៃសេរីភាពរបស់គ្រីស្ទបរិស័ទ ។ គោលបំណងនៃសេរីភាពរបស់គ្រីស្ទបរិស័ទ គឺដើម្បីដោះយើងអោយរួចពីខ្មាំងសត្រូវទាំងអស់របស់យើង យ៉ាងនោះ យើងអាចបំរើព្រះជាម្ចាស់ដោយគ្មានការភ័យខ្លាច ដោយបរិសុទ្ធ និងដោយសេចក្តីសុចរិត នៅចំពោះទ្រង់រាល់ថ្ងៃ រហូតអស់មួយជីវិតរបស់យើង[១៧] ។

[១៦]រ៉ូម ៦:១, ២ ។ [១៧]កា ៥:១៣; ២ពេ ២:១៨, ២១ ។

# ជំពូក ២២
# ថ្ងៃថ្វាយបង្គំព្រះ និង ថ្ងៃឈប់សំរាក

១. ពន្លឺធម្មជាតិបានពិពណ៌នាប្រាប់យ៉ាងច្បាស់ថា មានព្រះមួយអង្គ ដែលទ្រង់ជាម្ចាស់ ហើយមានអធិបតេយ្យភាពលើគ្រប់ទាំងអស់ ។ ទ្រង់យុត្តិធម៌ ទ្រង់ល្អ ហើយទ្រង់ធ្វើល្អដល់គ្រប់ទាំងអស់ ។ ដូច្នេះ គឺទ្រង់នេះហើយ ដែលយើងត្រូវកោតខ្លាច ស្រឡាញ់ សរសើរ ស្រែករកទុកចិត្ត ហើយមនុស្សគួរបំរើដល់ទ្រង់ អោយអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីកំលាំង[១] ។ យ៉ាងណាមិញ ព្រះជាម្ចាស់ផ្ទាល់ បានតាំងអោយមាន របៀបដែលទ្រង់អាចទទួលយកបានតែមួយគត់នៃការថ្វាយបង្គំ តាមព្រះហឫទ័យទ្រង់[២] ។ ដូច្នេះ យើងមិនគួរថ្វាយបង្គំដល់ទ្រង់ ទៅតាមគំនិតរបស់មនុស្ស ឬក៏ តាមរយៈការផ្តល់យោបល់របស់អារក្សសាតាំងនោះទេ ។ គ្រប់ទាំងរូបព្រះ និងគ្រប់ទាំងរបៀបផ្សេងៗទៀតនៃការថ្វាយបង្គំ ដែលព្រះគម្ពីរមិនបានបង្រៀន គឺត្រូវហាមជាដាច់ខាត[៣] ។

[១]យេ ១០:៧; ម៉ាក ១២:៣៣ ។ [២]ចោទិ ១២:៣២ ។ [៣]និក្ខ ២០:៤-៦ ។

២. ការថ្វាយបង្គំ គឺត្រូវថ្វាយដល់ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ តែមួយអង្គប៉ុណ្ណោះ[៤] ។ យើងមិនត្រូវថ្វាយបង្គំដល់ពួកទេវតា ពួកអ្នកបរិសុទ្ធ ឬ មនុស្សសត្វណាឡើយ[៥] ។ ចាប់តាំងពីគ្រាដែលមនុស្សបានធ្លាក់ទៅក្នុងអំពើបាប យើងមិនអាចថ្វាយបង្គំដល់ព្រះ

ដោយគ្មានអ្នកបម្រួបបម្រួមបានឡើយ[៦] ហើយ អ្នកបម្រួបបម្រួមដែលព្រះអាចទទួលយកបាននោះ គឺមានតែព្រះគ្រីស្ទតែមួយប៉ុណ្ណោះ[៧] ។

[៤]ម៉ាថ ៤:៩, ១០; យ៉ូន ៥:២៣; ម៉ាថ ២៨:១៩ ។ [៥]រ៉ូម ១:២៥; កូល ២:១៨; វិវរ ១៩:១០ ។ [៦]យ៉ូន ១៤:៦ ។ [៧]១ធី ២:៥ ។

៣. ព្រះជាម្ចាស់តំរូវអោយមនុស្សទាំងអស់អធិស្ឋាន ហើយថ្វាយការអរព្រះគុណដល់ទ្រង់[៨] ពីព្រោះនោះគឺជាផ្នែកមួយនៃការថ្វាយបង្គំព្រះ ។ ប៉ុន្តែ ដើម្បីធ្វើអោយសេចក្តីអធិស្ឋាននេះ បានគាប់ព្រះហឫទ័យព្រះ គឺត្រូវតែអធិស្ឋាននៅក្នុងព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ[៩] តាមរយៈជំនួយពីព្រះវិញ្ញាណបរិសុទ្ធ[១០] និង ដោយតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ផងដែរ[១១] ។ យើងត្រូវអធិស្ឋានដោយការគោរព បន្ទាបខ្លួន មានចិត្តចង់ ជំនឿ សេចក្តីស្រឡាញ់ និងការខ្ជាប់ខ្ជួន ។ នៅពេលយើងអធិស្ឋានជាមួយអ្នកដទៃទៀត យើងត្រូវប្រើភាសាដែលគេចេះ[១២] ។

[៨]ទំនុក ៩៥:១-៧; ៦៥:២ ។ [៩]យ៉ូន ១៤:១៣, ១៤ ។ [១០]រ៉ូម ៨:២៦ ។ [១១]១យ៉ូន ៥:១៤ ។ [១២]១កូ ១៤:១៦, ១៧ ។

៤. សេចក្តីអធិស្ឋាន គឺត្រូវតែធ្វើឡើងសំរាប់អ្វីគ្រប់យ៉ាងដែលត្រឹមត្រូវ និងសំរាប់មនុស្សគ្រប់ប្រភេទទាំងអស់ ដែលកំពុងតែមានជីវិតរស់នៅសព្វថ្ងៃ ហើយនិងអ្នកដែលមិនទាន់កើតដែរ[១៣] ក៏ប៉ុន្តែ សេចក្តីអធិស្ឋានមិនគួរធ្វើឡើង សំរាប់មនុស្សដែលបានស្លាប់ហើយទេ[១៤] ហើយក៏មិន

គួរធ្វើឡើង សំរាប់អស់អ្នកណាបានធ្វើបាបដែលនាំអោយស្លាប់ដែរ[១៥] ។

[១៣]១ធី ២:១, ២; ២សាំ ៧:២៩ ។ [១៤] ២សាំ ១២:២១-២៣ ។ [១៥]១យ៉ូន ៥:១៦ ។

៥. ផ្នែកនានានៃការថ្វាយបង្គំព្រះ គឺការអានអត្ថបទនៅក្នុងព្រះគម្ពីរ[១៦] ការអធិប្បាយ និងការឮពីព្រះបន្ទូលរបស់ព្រះ[១៧] ការបង្រៀន និងការរំលឹកដាស់តឿនគ្នាទៅវិញទៅមក តាមរយៈគម្ពីរទំនុកដំកើង ចំរៀងសរសើរដំកើងព្រះ ចំរៀងខាងឯវិញ្ញាណ ការច្រៀងដោយអរព្រះគុណនៅក្នុងចិត្តរបស់យើងថ្វាយទៅព្រះជាម្ចាស់[១៨] ព្រមទាំងការរៀបចំពិធីបុណ្យជ្រមុជទឹក[១៩] និងពិធីលៀងព្រះអម្ចាស់ផង[២០] ។ យើងត្រូវធ្វើកិច្ចការទាំងអស់នេះ ដោយស្តាប់បង្គាប់ដល់ទ្រង់ ដោយការយល់ដឹង ដោយសេចក្តីជំនឿ ដោយការគោរព និងដោយការកោតខ្លាចព្រះ ។ មួយវិញទៀត ការបន្ទាបខ្លួន ការតមអាហារ[២១] ការអរព្រះគុណដល់ព្រះ គួរធ្វើឡើងនៅក្នុងឱកាសពិសេសផ្សេងៗ ហើយយើងគួរធ្វើឡើង អោយមានលក្ខណៈបរិសុទ្ធ និងគោរព[២២] ។

[១៦]១ធី ៤:១៣ ។ [១៧] ២ធី ៤:២; លូ ៨:១៨ ។ [១៨]កូល ៣:១៦; អេ ៥:១៩ ។ [១៩]ម៉ាថ ២៨:១៩, ២០ ។ [២០]១កូ ១១:២៦ ។ [២១]អេស ៤:១៦; យ៉ូល ២:១២ ។ [២២]និក្ខ ១៥:១-១៩; ទំនុក ១០៧ ។

៦. នៅក្នុងដំណឹងល្អសម័យបច្ចុប្បន្ន ទាំងសេចក្តីអធិស្ឋាន ទាំងផ្នែកណាមួយផ្សេងទៀតនៃការថ្វាយបង្គំ មិនអាស្រ័យលើទីកន្លែង ឬក៏ ទិសដើម្បីអោយវាមានប្រសិទ្ធិភាពនោះទេ ពីព្រោះយើងគួរថ្វាយបង្គំព្រះគ្រប់ទីកន្លែង ដោយវិញ្ញាណ និងសេចក្តីពិត[២៣] ។ ឧទាហរណ៍ ការថ្វាយបង្គំព្រះជាគ្រួសារ[២៤] រាល់ថ្ងៃ[២៥] ឬ ដោយផ្ទាល់ខ្លួនឯងម្នាក់ៗ[២៦] ឬក៏ ជាមួយពួកជំនុំជាសាធារណៈ ។ ការប្រជុំគ្នាយ៉ាងនេះ គឺទៅតាមព្រះបន្ទូល និងការទំនុកបំរុងរបស់ព្រះ ហើយអ្នកជឿមិនគួរធ្វេសប្រហែស ឬមានចេតនានឹងមិនយកចិត្តទុកដាក់ឡើយ[២៧] ។

[២៣]យ៉ូន ៤:២១; ម៉ាឡ ១:១១; ១ធី ២:៨ ។ [២៤]កិច្ច ១០:២ ។ [២៥]ម៉ាថ ៦:១១; ទំនុក ៥៥:១៧ ។ [២៦]ម៉ាថ ៦:៦ ។ [២៧]ហេ ១០:២៥; កិច្ច ២:៤២ ។

៧. ដោយព្រោះការនេះ គឺជាច្បាប់នៃធម្មជាតិទូទៅ ជាចំណែកនៃពេលវេលាដែលព្រះជាម្ចាស់ទ្រង់បានរៀបចំសំរាប់មនុស្ស នោះយើងគួរតែញែកពេលដាច់ដោយឡែក សំរាប់ការថ្វាយបង្គំព្រះ ។ ដូច្នេះហើយ បានជាទ្រង់ប្រទានបញ្ញត្តិវិជ្ជមាន និងប្រកបដោយសីលធម៌ ហើយ គ្រប់លក្ខណ៍ ទុកជាក្បួន សំរាប់មនុស្សគ្រប់រូប និងគ្រប់ជំនាន់ ។ ព្រះជាម្ចាស់បានជ្រើសរើសមួយថ្ងៃជាពិសេស ក្នុងចំណោម៧ថ្ងៃ ទុកជាថ្ងៃឈប់សំរាក ដើម្បីរក្សាថ្ងៃនោះ ជាថ្ងៃបរិសុទ្ធសំរាប់ទ្រង់[២៨] ។ ចាប់តាំងពីដើមកំណើតនៃផែនដី រហូតមកដល់ការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ ថ្ងៃឈប់សំរាក គឺជាថ្ងៃចុងក្រោយនៃសប្តាហ៍ (ថ្ងៃទី៧) ប៉ុន្តែក្រោយពេលការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ ថ្ងៃនោះត្រូវបានប្តូរទៅជា

ថ្ងៃដំបូងវិញ(ថ្ងៃទី១) ហើយត្រូវបានហៅថា ថ្ងៃនៃព្រះអម្ចាស់[២៩] ។ ការនេះត្រូវបន្តរហូតដល់ថ្ងៃចុងបំផុតនៃផែនដី ទុកជាថ្ងៃសំរាករបស់គ្រីស្ទបរិស័ទ ។ ពិធីនានាដែលត្រូវធ្វើឡើងនៅថ្ងៃទីប្រាំពីរត្រូវលើកចោល ។

[២៨]និក្ខ ២០:៨ ។ [២៩]១កូ ១៦:១, ២; កិច្ច ២០:៧; វិវរ ១:១០ ។

៨. ថ្ងៃឈប់សំរាកត្រូវញែកជាបរិសុទ្ធថ្វាយព្រះជាម្ចាស់ ហើយ មនុស្សត្រូវញែកចេញដោយខ្សែកពីកិច្ចការចាំបាច់នានា ដោយរៀបចំចិត្តរបស់យើង និងរៀបចំកិច្ចការនានាទុកជាមុន ។ មួយវិញទៀត គ្រប់គ្នាត្រូវរក្សា១ថ្ងៃនេះពេញមួយថ្ងៃពីការងារ ការសន្ទនា និងការគិតទាំងឡាយណាដែលទាក់ទងទៅនឹងមុខរបរ និងការកំសាន្តខាងឯលោកិយ[៣០] ។ យើងគួរយកពេលវេលាមួយថ្ងៃពេញនេះ សំរាប់ការថ្វាយបង្គំជាសាធារណៈ និងដោយផ្ទាល់ខ្លួន និងសំរាប់ភារកិច្ចនៃភាពចាំបាច់នានា និងសេចក្ដីមេត្តាករុណា[៣១] ។

[៣០]អេសា ៥៨:១៣; នេ ១៣:១៥-២២ ។ [៣១]ម៉ាថ ១២:១-១៣ ។

# ជំពូក ២៣

# សម្បថ និង បំណន់ដែលត្រឹមត្រូវ

១. សម្បថដែលត្រឹមត្រូវ គឺជាផ្នែកមួយនៃការថ្វាយបង្គំ ដែលបុគ្គលម្នាក់ស្បថដោយសេចក្ដីពិត សុចរិត និងយុត្តិធម៌ ហើយគាត់ស្រែកហៅព្រះជាម្ចាស់ អោយទ្រង់ធ្វើជាសាក្សី[១] នូវពាក្យសម្បថរបស់គាត់ ហើយកាត់ក្ដីគាត់ទៅតាមពាក្យសម្បថនោះ[២] ។

[១]និក្ខ ២០:៧; ចោទិ ១០:២០; យេ ៤:២ ។ [២]២របា ៦:២២, ២៣ ។

២. យើងអាចស្បថបានតែនៅក្នុងព្រះនាមនៃព្រះជាម្ចាស់ប៉ុណ្ណោះ ហើយយើងគួរប្រើការទាំងអស់នេះ ដោយកោតខ្លាច និងគោរពដល់ព្រះ ។ ដូច្នេះ ប្រសិនបើយើងស្បថដោយអសារឥតការ ឬ ដោយខ្វះការយកចិត្តទុកដាក់ដល់ព្រះនាមទ្រង់ ដែលប្រកបដោយសិរីរុងរឿងនិងគួរកោតខ្លាច ឬក៏ ដោយប្រើឈ្មោះផ្សេង ឬ របស់វត្ថុនានា នោះមានន័យថា យើងធ្វើបាបហើយ ។ យើងគួរស្អប់នូវការទាំងនោះ[៣] ។ ប៉ុន្តែនៅក្នុងការសំខាន់សំរាប់បញ្ជាក់ពីសេចក្ដីពិត និងបញ្ចប់ជំលោះ[៤] នោះព្រះបន្ទូលរបស់ព្រះអាចអោយយើងស្បថបាន[៥] ។

[៣]ម៉ាថ ៥:៣៤, ៣៧; យ៉ា ៥:១២ ។ [៤]ហេ ៦:១៦; ២កូ ១:២៣ ។ [៥]នេ ១៣:២៥ ។

៣. អ្នកណាដែលត្រូវបានអនុញ្ញាតអោយស្បថដោយព្រះបន្ទូលរបស់ព្រះ គេគួរតែពិចារណាពីភាពសំខាន់បំផុតនៃការស្បថនោះ ហើយគេអាចស្បថនូវអ្វីដែលពិតប្រាកដប៉ុណ្ណោះ ។ ព្រះជាម្ចាស់ខ្ញាល់នឹងសម្បថណាដែលខ្វះការយកចិត្តទុកដាក់ ដោយមិនពិត ឬក៏ដោយអសារឥតការ ។ បើសិនពួកគេធ្វើដូច្នោះ នោះស្រុកគេនឹងទទួលការឈឺចាប់ជាមិនខាន[6] ។

[6]លេវី ១៩:១២; យេ ២៣:១០ ។

៤. សម្បថត្រូវធ្វើដោយពាក្យសាមញ្ញត្រង់ៗ និងឥតវៀចវេរឡើយ ហើយ ក៏មិនត្រូវនិយាយអោយតែរួចពីមាត់ដែរ[7] ។

[7]ទំនុក ២៤:៤ ។

៥. បំណន់ គឺជាការមួយ ដែលត្រូវធ្វើឡើងទៅចំពោះព្រះជាម្ចាស់ប៉ុណ្ណោះ មិនមែនទៅចំពោះមនុស្សទេ ។ ពេលដែលយើងធ្វើបំណន់មួយទៅចំពោះព្រះ យើងត្រូវធ្វើវាដោយយកចិត្តទុកដាក់ និងដោយស្មោះត្រង់[8] ។ ប៉ុន្តែបំណន់នៃបព្វជិត (ដូចជានៅក្នុងចំណោមពួកជំនុំរ៉ូម) ដែលតំរូវអោយយើងមិនយកប្តីប្រពន្ធ[9] ឬតំរូវអោយមានភាពទ័លក្រ[10] នោះវាមិនមែនជាទង្វើនៃភាពឥតខ្ចោះទេ! តែផ្ទុយទៅវិញ សកម្មភាពទាំងអស់នេះ វាគឺជាជំនឿឆ្វេងនិយម និងជាអន្ទាក់នៃអំពើបាបប៉ុណ្ណោះ ហើយគ្រីស្ទបរិស័ទម្នាក់ៗ មិនគួរនឹងបណ្តោយខ្លួនអោយវង្វេងទៅក្នុងអន្ទាក់នេះឡើយ[11] ។

[៨]ទំនុក ៧៦:១១; លោក ២៨:២០-២២ ។ [៩]១កូ ៧:២, ៩ ។ [១០]អេ ៩:២៨ ។ [១១]ម៉ាថ ១៩:១១ ។

# ជំពូក ២៤
# ច្បាប់រដ្ឋ

១. ព្រះដ៏ជាព្រះ គឺជាព្រះអម្ចាស់ដ៏មហាអស្ចារ្យ និងជាស្តេចនៃពិភពលោកទាំងមូល ។ ទ្រង់បានតាំងច្បាប់រដ្ឋឡើង ដើម្បីអោយនៅក្រោមការត្រួតត្រារបស់ទ្រង់ លើមនុស្សជាតិទាំងអស់ សំរាប់ទុកជាសិរីរុងរឿង ដល់ទ្រង់ផ្ទាល់ និងសំរាប់ជាការល្អដល់សាធារណៈជន ។ តាមរយៈគោលបំណងនេះ ទ្រង់បានប្រទានអោយពួកគេមានអំណាច ដើម្បីទុកជីវិត និងសំលាប់ អោយមានសុវត្ថិភាព និងការលើកទឹកចិត្តដល់អស់អ្នកណាដែលប្រព្រឹត្តិល្អ ហើយ ដាក់ទោសដល់អស់អ្នកណាដែលប្រព្រឹត្តអាក្រក់វិញ[១] ។

[១]រ៉ូម ១៣:១-៤ ។

២. មានច្បាប់សំរាប់គ្រីស្ទបរិស័ទ ដើម្បីទទួលនិងអនុវត្តតួនាទីជាមន្ត្រីរាជការបានដែរ នៅពេលដែលអ្នកនោះត្រូវបានត្រាស់ហៅមកបំពេញតួនាទីនេះ ។ ពួកគេត្រូវទទួលខុសត្រូវដោយរក្សាអោយបាននូវយុត្តិធម៌ និងសន្តិភាព[២] តាមរយៈការអនុវត្តន៍ច្បាប់នៃប្រទេសនោះ ។ សេចក្តី

បង្រៀននៃព្រះគម្ពីរសញ្ញាថ្មីបានបង្រៀនថា អោយពួកគេមានអំណាចដើម្បីចូលរួមធ្វើសង្គ្រាមនៅពេលដែលចាំបាច់ ដើម្បីអោយមានភាពយុត្តិធម៌[៣] ។

[២]២សាំ ២៣:៣; ទំនុក ៨២:៣, ៤ ។ [៣]លូ ៣:១៤ ។

៣. ព្រះជាម្ចាស់បានបង្កើតអោយមានអ្នកគ្រប់គ្រងច្បាប់រដ្ឋឡើង គឺជាគោលបំណងរបស់ទ្រង់ ។ ដូច្នេះគ្រីស្ទបរិស័ទគ្រប់រូប គួរតែចុះចូលហើយស្តាប់បង្គាប់គ្រប់ទាំងច្បាប់ ដែលមិននាំយើងទៅរកការមិនស្តាប់បង្គាប់ព្រះ ។ យើងគួរគោរពច្បាប់នេះ ទុកដូចជាផ្នែកមួយនៃការស្តាប់បង្គាប់ របស់យើងដល់ព្រះ ប៉ុន្តែ មិនមែនធ្វើដើម្បីអោយតែរួចពីទោសកំហុសប៉ុណ្ណោះទេ តែដោយព្រោះប្រយោជន៍ដល់បញ្ញាចិត្តរបស់ខ្លួនវិញ[៤] ។ យើងគួរតែអធិស្ឋានអោយស្តេច ហើយនិងអ្នកដែលមានសមត្ថកិច្ចគ្រប់គ្រងរបស់យើងទាំងប៉ុន្មាន “ដើម្បីអោយយើងរាល់គ្នាបាននៅជាសុខសាន្ត ហើយស្រគត់ស្រគំ ដោយកោតខ្លាច ហើយដោយនឹងធឹង គ្រប់ជំពូក”[៥] ។

[៤]រ៉ូម ១៣:៥-៧; ១ពេ ២:១៧ ។ [៥]១ធី ២:១, ២ ។

# ជំពូក ២៥
# អាពាហ៍ពិពាហ៍

១. អាពាហ៍ពិពាហ៍ គឺត្រូវធ្វើឡើងរវាងបុរសម្នាក់ និងស្ត្រីម្នាក់ ។ វាមិនត្រឹមត្រូវទេ ដែលបុរសមានប្រពន្ធលើសពីមួយ ឬ ស្ត្រីមានប្តីលើសពីមួយ ក្នុងពេលតែមួយ[១] ។

[១]លោក ២:២៤; ម៉ាឡ ២:១៥; ម៉ាថ ១៩:៥, ៦ ។

២. អាពាហ៍ពិពាហ៍ គឺជាការមួយដែលតាំងឡើងសំរាប់ការជួយគ្នាទៅវិញទៅមករបស់ប្តីប្រពន្ធ[២] ដើម្បីអោយមនុស្សបង្កបង្កើតកូនចៅដោយស្របច្បាប់[៣] និងដើម្បីការពារមិនអោយមានភាពអសីលធម៌ផងដែរ[៤] ។

[២]លោក ២:១៨ ។ [៣]លោក ១:២៨ ។ [៤]១កូ ៧:២, ៩ ។

៣. វាជាការត្រឹមត្រូវ ដែលមនុស្សទាំងអស់គួរតែរៀបអាពាហ៍ពិពាហ៍ ប្រសិនបើ ពួកគេមានការយល់ព្រមដោយមានការពិចារណាត្រឹមត្រូវ[៥] ។ ប៉ុន្តែនេះជាកាតព្វកិច្ចរបស់គ្រីស្ទបរិស័ទ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្រីស្ទបរិស័ទដូចគ្នា[៦] ។ ផ្ទុយទៅវិញ ពួកគេមិនត្រូវរៀបការជាមួយអ្នកដែលមិនជឿព្រះ ឬ អ្នកថ្វាយបង្គំរូបព្រះឡើយ ហើយអ្នកដែលកោតខ្លាចដល់ព្រះក៏មិនគួរទឹមនឹមស្រៀក ជាមួយមនុស្សដែលប្រព្រឹត្តិអាក្រក់ ឬពួកអ្នកដែលរក្សាសេចក្តីបង្រៀនខុសឆ្គង ដែលនាំអោយទទួលបណ្តាសា និងការជំនុំជំរះនោះដែរ[៧] ។

[៥]ហេ ១៣:៤; ១ធី ៤:៣ ។ [៦]១កូ ៧:៣៩ ។ [៧]នេ ១៣:២៥-២៧ ។

៤. ដូចដែលព្រះគម្ពីរបានហាមហើយ អាពាហ៍ពិពាហ៍ មិនត្រូវរៀបចំឡើងរវាងសាច់ញាតិ ឬ អ្នកដែលរួមខ្សែលោហិតជិតស្និតឡើយ[៨] ។ បើមានមនុស្សពីរនាក់រួមខ្សែលោហិតយ៉ាងជិតស្និតជាមួយគ្នា ហើយទោះបីជាពួកគេបានព្រមព្រៀងគ្នារួចស្រេចទាំងសងខាង ឬក៏មានច្បាប់អោយធ្វើយ៉ាងដូច្នោះក៏ដោយ ក៏គេទាំងពីរនាក់មិនត្រូវបានអនុញ្ញាតអោយរៀបការរស់នៅជាមួយគ្នាជាប្តីប្រពន្ធស្របច្បាប់បានដែរ[៩] ។

[៨]លេវី ១៨:១-៣០ ។ [៩]ម៉ាក ៦:១៨; ១កូ ៥:១ ។

# ជំពូក ២៦

# ពួកជំនុំ

១. ពួកជំនុំសកល ជាពួកជំនុំដែលយើងមិនអាចមើលឃើញ ពីព្រោះវាជាកិច្ចការផ្នែកខាងក្នុងរបស់ព្រះវិញ្ញាណ និងសេចក្តីពិតនៃព្រះគុណ ជាពួកអ្នកដែលព្រះបានជ្រើសរើស គឺជាពួកអ្នកដែលបានសង្គ្រោះហើយ ឬក៏ ពួកអ្នកកំពុងតែបានសង្គ្រោះ ហើយនិង អស់អ្នកដែលនឹងបានសង្គ្រោះនៅពេលអនាគត ។ ពួកគេនឹងបានរួមមកតែមួយនៅក្នុងព្រះគ្រីស្ទដែលទ្រង់ជាសិរសានៃពួកជំនុំ ។ ពួកជំនុំនេះជាប្រពន្ធ រូបកាយ

និងភាពពេញលេញនៃព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ "បំពេញគ្រប់ទាំងអស់ក្នុងទាំងអស់"[១] ។

[១]ហេ ១២:២៣; កូល ១:១៨; អេ ១:១០, ២២, ២៣; ៥:២៣, ២៧, ៣២ ។

២. មនុស្សទាំងអស់នៅលើពិភពលោក ដែលនិយាយថាខ្លួនបានជឿដំណឹងល្អ ហើយស្តាប់បង្គាប់ព្រះដោយព្រះគ្រីស្ទ យើងអាចហៅពួកគេថា ពួកបរិសុទ្ធដែលមើលឃើញ[២] ប្រសិនបើ ពួកគេមិនធ្វើអោយការនិយាយរបស់ពួកគេជាអសារឥតការ ដោយព្រោះតែកំហុសឆ្គងដែលបំផ្លាញមូលដ្ឋានគ្រឹះនៃដំណឹងល្អ ឬ ដោយឥរិយាបថមិនបរិសុទ្ធរបស់ពួកគេ ។ ក្រុមជំនុំក្នុងមូលដ្ឋានទាំងអស់ គួរមានពេញទៅដោយពួកបរិសុទ្ធ[៣] ។

[២]១កូ ១:២; កិច្ច ១១:២៦ ។ [៣]រ៉ូម ១:៧; អេ ១:២០-២២ ។

៣. មានពួកជំនុំបរិសុទ្ធជាច្រើន មាននិន្នាការជាមួយការច្របូកច្របល់លាយឡំគ្នា និងកំហុសឆ្គង[៤] ហើយក៏មានខ្លះទៀតបានទទួលឱនភាពក្នុងសេចក្តីជំនឿយ៉ាងខ្លាំង ដល់ម្ល៉េះហើយ បានជាបណ្តាលអោយពួកគេឈប់ធ្វើជារូបកាយនៃព្រះគ្រីស្ទ ហើយក៏បានក្លាយទៅជាសាលាប្រជុំរបស់អារក្សសាតាំងវិញ[៥] ។ ទោះជាយ៉ាងដូច្នេះក្តី ព្រះគ្រីស្ទជានិច្ចជាកាលបានរក្សាទុក និង តែងតែមានអាណាចក្រមួយនៅក្នុងលោកិយនេះ

របបូតដល់ថ្ងៃចុងបំផុត ។ ទ្រង់បានរៀបចំវាទុកជាស្រេចសំរាប់អស់អ្នកដែលជឿដល់ទ្រង់ ហើយប្រកាសពីព្រះនាមរបស់ទ្រង់[៦] ។

[៤]១កូ ៥; វិវរ ២:៩; ៣:៩ ។ [៥]វិវរ ១៨:២; ២ថែស ២:១១, ១២ ។ [៦]ម៉ាថ ១៦:១៨; ទំនុក ៧២:១៧; ១០២:២៨; វិវរ ១២:១៧ ។

៤. ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាសិរសានៃពួកជំនុំ ដោយការតែងតាំងរបស់ព្រះវរបិតា ហើយ ទ្រង់បានទទួលគ្រប់ទាំងអំណាចទាំងអស់សំរាប់ការត្រាស់ហៅ ការបង្កើត ការបង្គាប់ និងការគ្រប់គ្រងពួកជំនុំដែលប្រកបដោយអធិបតេយ្យភាព និងដោយឧត្តមភាពបំផុត[៧] ។ យ៉ាងណាមិញ សម្តេចសង្ឃនៃចក្រភពរ៉ូម មិនអាចធ្វើជាក្បាលនៃពួកជំនុំបានទេ តែគាត់ជាអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទ ជាមនុស្សមានបាប និងជាអ្នកលើកតាំងខ្លួនឡើងទាស់ប្រឆាំងនឹងព្រះគ្រីស្ទវិញ ។ តែព្រះជាម្ចាស់នឹងបំផ្លាញគ្រប់ការទាំងអស់នេះចោលចេញ ដោយរស្មីភ្លឺចែងចាំងនៃដំណើរយាងមករបស់ទ្រង់[៨] ។

[៧]កូល ១:១៨; ម៉ាថ ២៨:១៨-២០; អេ ៤:១១, ១២ ។ [៨] ២ថែស ២:២-៩ ។

៥. នៅក្នុងការអនុវត្តន៍អំណាចដែលព្រះជាម្ចាស់បានប្រទានដល់ទ្រង់ ព្រះយេស៊ូវបានត្រាស់ហៅអស់អ្នក ដែលព្រះវរបិតាបានប្រទានដល់ទ្រង់[៩] អោយចេញពីលោកិយនេះ តាមរយៈព័ន្ធកិច្ចនៃព្រះបន្ទូល ហើយដោយព្រះវិញ្ញាណរបស់ទ្រង់ នោះពួកគេនឹងអាចដើរនៅចំពោះទ្រង់

ដោយការស្តាប់បង្គាប់ និងការចុះចូលដែលទ្រង់បានបង្គាប់ទៅពួកគេតាមព្រះបន្ទូលរបស់ទ្រង់បាន[១០] ។ ដូច្នេះអស់អ្នកដែលទ្រង់បានត្រាស់ហៅ ទ្រង់បានបង្គាប់អោយដើរជាមួយគ្នានៅក្នុងសង្គម ឬ ក្នុងពួកជំនុំ ដើម្បីស្អាងចិត្តគ្នាទៅវិញទៅមក និងដើម្បីចូលរួមក្នុងការថ្វាយបង្គំព្រះជាសាធារណៈដែលទ្រង់បានតំរូវដល់ពួកគេ អោយអនុវត្តនៅក្នុងលោកិយនេះ[១១] ។

[៩]យ៉ូន ១០:១៦; ១២:៣២ ។ [១០]ម៉ាថ ២៨:២០ ។ [១១]ម៉ាថ ១៨:១៥-២០ ។

៦. សមាជិកនៃពួកជំនុំនេះ គឺជាពួកបរិសុទ្ធដោយព្រោះការត្រាស់ហៅរបស់ព្រះ ហើយពួកគេស្តាប់បង្គាប់ការហៅរបស់ព្រះគ្រីស្ទ តាមរបៀបមួយដែលយើងអាចមើលឃើញ គឺដោយការលន់តួចំពោះព្រះគ្រីស្ទ និងលក្ខណៈនៃជីវិតរស់នៅរបស់ពួកគេ[១២] ។ ពួកបរិសុទ្ធបែបនេះ នឹងស្មោះស្ម័គ្រដើរជាមួយគ្នា ដោយអស់ពីចិត្តទៅតាមអ្វីៗ ដែលព្រះគ្រីស្ទបានបង្រៀនពួកគេ ហើយ ពួកគេបានប្រគល់ខ្លួនគេផ្ទាល់ដល់ព្រះអម្ចាស់ ហើយជួយគ្នាទៅវិញទៅមក ទៅតាមបំណងព្រះហឫទ័យនៃព្រះជាម្ចាស់ ដើម្បីចុះចូលចំពោះការទាមទាររបស់ដំណឹងល្អ[១៣] ។

[១២]រ៉ូម ១:៧; ១កូ ១:២ ។ [១៣]កិច្ច ២:៤១, ៤២; ៥:១៣, ១៤; ២កូ ៩:១៣ ។

៧. ចំពោះពួកជំនុំនិមួយៗទាំងអស់នេះ បានជួបជុំគ្នាតាមបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ដូចដែលបានប្រកាសក្នុងព្រះបន្ទូលរបស់

ទ្រង់ស្រាប់ហើយ ។ ទ្រង់បានប្រទាន គ្រប់ទាំងអំណាចព្រះចេស្តា និងរាជអជ្ញាដែលពួកគេត្រូវការ ដើម្បីអនុវត្តនូវរបៀបនៃការគោរពថ្វាយបង្គំព្រះ និងសេចក្តីប្រៀនប្រដៅដែលទ្រង់បានរៀបចំទុកអោយពួកគេដើម្បីប្រតិបត្តិតាម ។ ទ្រង់ក៏បានប្រទាននូវបញ្ញត្តិ និងច្បាប់ផ្សេងៗសំរាប់ការអនុវត្តន៍អំណាច និងរាជអជ្ញានេះ អោយបានត្រឹមត្រូវផងដែរ[១៤] ។

[១៤]ម៉ាថ ១៨:១៧, ១៨; ១កូ ៥:៤, ៥; ៥:១៣; ២កូ ២:៦-៨ ។

៨. ពួកជំនុំនិមួយៗដែលបានជួបជុំគ្នា ដោយមានការរៀបចំត្រឹមត្រូវតាមគំនិតរបស់ព្រះគ្រីស្ទ គឺត្រូវមានពួកបាវបំរើព្រះ និង សមាជិកក្រុមជំនុំ ។ តាមរយៈការតែងតាំងរបស់ព្រះគ្រីស្ទ ពួកបាវបំរើព្រះគួរតែត្រូវបានជ្រើសរើស ហើយញែកចេញដោយពួកជំនុំ ។ ពួកបាវបំរើទាំងអស់នេះហៅថា គ្រូគង្វាល និងអ្នកជំនួយ ។ ពួកគេមានទំនួលខុសត្រូវពិសេសដើម្បីរៀបចំនូវអ្វីដែលព្រះបានតាំងឡើង ដោយប្រើអំណាចដែលទ្រង់បានប្រទានមក ដើម្បីអនុវត្តកាតព្វកិច្ចរបស់ពួកគេ ។ ហើយការនេះត្រូវបន្តធ្វើនៅក្នុងក្រុមជំនុំរហូតដល់ទីបញ្ចប់នៃផែនដី[១៥] ។

[១៥]កិច្ច ២០:១៧, ២៨ ភី ១:១ ។

៩. របៀបដែលព្រះគ្រីស្ទបានតែងតាំង សំរាប់ការត្រាស់ហៅអ្នកណាម្នាក់ដែលមានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ សំរាប់កិច្ចការជាគ្រូគង្វាលនៅក្នុងក្រុមជំនុំ នោះគួរតែត្រូវបានជ្រើសរើសឡើង ដោយការ

បោះឆ្នោតរបស់ពួកជំនុំ[១៦] ។ ហើយអ្នកនោះគួរត្រូវញែកចេញដោយការតមអាហារ និងសេចក្តីអធិស្ឋាន ។ ប្រសិនបើក្រុមជំនុំនោះមានគ្រូគង្វាល ឬចាស់ទុំហើយ នោះពួកគេគួរដាក់ដៃលើគាត់[១៧] ។ ហើយចំណែកឯអ្នកជំនួយវិញ គួរត្រូវបានជ្រើសរើសដោយពួកជំនុំ ហើយក៏ត្រូវញែកគាត់ចេញដោយសេចក្តីអធិស្ឋាន ព្រមទាំងដាក់ដៃលើផង[១៨] ។

[១៦]កិច្ច ១៤:២៣ ។ [១៧]១ធី ៤:១៤ ។ [១៨]កិច្ច ៦:៣, ៥, ៦ ។

១០. គ្រូគង្វាល ត្រូវបានតំរូវអោយមានការផ្តោតយកចិត្តទុកដាក់គ្រប់ពេលវេលាចំពោះការបំរើព្រះគ្រីស្ទនៅក្នុងពួកជំនុំរបស់ទ្រង់ ។ គាត់គួរតែមានភាពសស្រាក់សស្រាំចំពោះកិច្ចការនៃព្រះបន្ទូល និង សេចក្តីអធិស្ឋាន ។ គ្រូគង្វាលគួរឃ្លាំមើលព្រលឹងរបស់ពួកជំនុំ ពីព្រោះគាត់ជាអ្នកទទួលខុសត្រូវលើពួកគេចំពោះព្រះ[១៩] ។ ដូច្នេះ វាមានសារៈសំខាន់ណាស់សំរាប់ពួកជំនុំរបស់គ្រូគង្វាល ដូចនេះពួកគេគួរផ្តល់កិត្តិយសហើយចែករំលែកទ្រព្យសម្បត្តិខាងលោកិយនេះ ដោយបរិបូរហូរហៀរដល់គាត់តាមសមត្ថភាពរបស់ពួកគេ[២០] ។ ដូចនេះលោកគ្រូគង្វាលអាចរស់នៅដោយសុខសាន្តបាន ដោយមិនជាប់រវល់ក្នុងកិច្ចការរកស៊ីខាងលោកិយនេះទៀត[២១] ហើយគាត់ក៏អាចចែករំលែកដល់អ្នកដទៃទៀតដែរ[២២] ។ ការទាំងអស់នេះ គឺត្រូវបានតំរូវ ដោយច្បាប់នៃធម្មជាតិ និងការបង្គាប់របស់ព្រះអម្ចាស់យេស៊ូវ ដែលទ្រង់បានបង្គាប់ថា "អោយពួកអ្នកដែលផ្សាយដំណឹងល្អ បានរស់ដោយសារដំណឹងល្អដូច្នោះដែរ"[២៣] ។

[១៩]កិច្ច ៦:៤; ហេ ១៣:១៧ ។ [២០]១ធី ៥:១៧, ១៨; កា ៦:៦, ៧ ។ [២១] ២ធី ២:៤ ។ [២២]១ធី ៣:២ ។ [២៣]១កូ ៩:៦-១៤ ។

១១. គ្រូគង្វាលមានកាតព្វកិច្ចត្រូវចែកចាយព្រះបន្ទូលព្រះនៅក្នុងពួកជំនុំ ដ្បិតការនោះជាទំនួលខុសត្រូវរបស់គាត់ ប៉ុន្តែកិច្ចការនៃការចែកចាយព្រះបន្ទូលព្រះ មិនមែនសំរាប់តែគាត់ម្នាក់ឯងប៉ុណ្ណោះទេ ។ យ៉ាងណាមិញ អ្នកដទៃទៀតផ្សេងទៀតដែលមានអំណោយទាន និងព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើអោយគាត់មានសមត្ថភាពចំពោះការងារនេះ ហើយបានទទួលការអនុញ្ញាត ព្រមទាំងទទួលបានការអញ្ជើញដោយពួកជំនុំនោះគាត់ក៏គួរអាចនឹងចែកចាយព្រះបន្ទូលបានដែរ[២៤] ។

[២៤]កិច្ច ១១:១៩-២១; ១ពេ ៤:១០-១១ ។

១២. ពួកអ្នកជឿទាំងអស់ត្រូវចូលរួមជាមួយគ្នានៅក្នុងក្រុមជំនុំជាក់លាក់ណាមួយ នៅពេលណា និងនៅកន្លែងណា ដែលពួកគេអាចមានឱកាសចូលរួមបាន ។ អស់អ្នកណាដែលបានក្លាយជាសមាជិកនៃក្រុមជំនុំណាមួយហើយ អ្នកនោះត្រូវចុះចូលចំពោះវិន័យ និងច្បាប់គ្រប់គ្រងរបស់ក្រុមជំនុំដែលអនុលោមទៅតាមច្បាប់របស់ព្រះគ្រីស្ទនោះដែរ[២៥] ។

[២៥]១ថែស ៥:១៤; ២ថែស ៣:៦, ១៤, ១៥ ។

១៣. សមាជិកណាម្នាក់ដែលត្រូវបានធ្វើអោយថ្នាំងថ្នាក់ចិត្ត ដោយសមាជិកផ្សេងទៀត ហើយក្រោយមកអ្នកនោះក៏បានធ្វើការដោះស្រាយបញ្ហាទៅតាមការចង្អុលបង្ហាញរបស់ព្រះគម្ពីរដែរ ប៉ុន្តែពួកគេនៅតែមាន

បញ្ហាទៀត នោះពួកគេមិនត្រូវធ្វើអ្វីណាមួយ ដែលធ្វើអោយប៉ះពាល់ដល់សេចក្តីសុខសាន្តរបស់ពួកជំនុំឡើយ ។ ហើយពួកគេក៏មិនត្រូវយករឿងនេះទុកជាលេសដើម្បីមិនមកព្រះវិហារដែរ ប៉ុន្តែ ពួកគេត្រូវរង់ចាំព្រះគ្រីស្ទ ដើម្បីអោយទ្រង់បានដោះស្រាយចំពោះបញ្ហានេះវិញ[២៦] ។

[២៦]ម៉ាថ ១៨:១៥-១៧; អេ ៤:២, ៣ ។

១៤. សមាជិកទាំងអស់នៃពួកជំនុំ ត្រូវមានភារកិច្ចអធិស្ឋានឥតឈប់ឈរសំរាប់ការល្អ និងការរីកចំរើននៃពួកជំនុំរបស់ព្រះគ្រីស្ទ[២៧] ទាំងអស់នៅគ្រប់ទីកន្លែង ហើយ យើងត្រូវជួយដល់មនុស្សគ្រប់រូបនៅក្នុងសហគមន៍របស់យើង ដោយប្រើប្រាស់អំណោយទាន និងទេពកោសល្យរបស់យើង ទៅតាមការដែលព្រះបានប្រទានមក ។ ដូច្នេះពួកជំនុំគួរតែមានការប្រកបជាមួយគ្នាទៅវិញទៅមក នៅពេលដែលព្រះបានប្រទានឱកាសដល់គេ ដើម្បីកំឡាចិត្ត និងលើកទឹកចិត្តគ្នា[២៨] ។

[២៧]អេ ៦:១៨; ទំនុក ១២២:៦ ។ [២៨]រ៉ូម ១៦:១, ២; ៣យ៉ូន ១:៨-១០ ។

១៥. នៅពេលដែលមានការពិបាក ឬភាពខុសគ្នា បានកើតឡើងអំពីគោលលទ្ធិ ឬការគ្រប់គ្រងក្រុមជំនុំ ការនោះអាចនឹងធ្វើអោយប៉ះពាល់ដល់សេចក្តីសុខសាន្ត ការសាមគ្គីគ្នា និងការស្អាងចិត្តគ្នា ចំពោះក្រុមជំនុំមួយ ឬច្រើនបាន ។ ជួនកាល សមាជិកក្រុមជំនុំម្នាក់ ឬច្រើន ក៏អាចនឹងមានការអន់ចិត្តដែរ ដោយសារតែរបៀបមួយចំនួនដែលមិនបានអនុវត្តអោយបានត្រឹមត្រូវ តាមសេចក្តីពិត និងរបៀបរៀបរយរបស់ពួកជំនុំ ។

ក្នុងករណីទាំងនេះ ពួកជំនុំទាំងនោះគួរប្រជុំ ហើយពិភាក្សាគ្នាតាមរយៈអ្នកតំណាងរបស់ពួកគេ ដោយផ្អែកទៅលើព្រះបន្ទូលរបស់ព្រះគ្រីស្ទ ។ ចំពោះអ្នកតំណាងទាំងនោះ ពួកជំនុំគួរជ្រើសរើសអស់អ្នកដែលមានសមត្ថភាពផ្តល់យោបល់អំពីបញ្ហានៃទំនាស់នេះ[២៩] ។ ប៉ុន្តែត្រូវយល់ថាអ្នកតំណាងទាំងនោះមិនមានអំណាចលើក្រុមជំនុំណាមួយឡើយ ហើយពួកគេក៏មិនអាចដាក់វិន័យ ឬក៏បង្ខំក្រុមជំនុំនោះអោយធ្វើតាមយោបល់របស់ខ្លួនបានដែរ[៣០] ។

[២៩]កិច្ច ១៥:២, ៤, ៦, ២២, ២៣, ២៥ ។ [៣០]២កូ ១:២៤; ១យ៉ូន ៤:១ ។

# ជំពូក ២៧
# ការប្រកបគ្នារបស់ពួកបរិសុទ្ធ

១. ពួកបរិសុទ្ធទាំងអស់ បានរួមមកក្នុងព្រះគ្រីស្ទ ដែលទ្រង់ជាសិរសារបស់ពួកគេតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ និងដោយសេចក្តីជំនឿ ។ ប៉ុន្តែនោះមិនមែនមានន័យថា ពួកគេបានត្រឡប់ទៅជាបុគ្គលតែមួយជាមួយទ្រង់នោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែមានការប្រកបគ្នាជាមួយទ្រង់នៅក្នុងព្រះគុណ ការរងទុក្ខ ការសុគត ការរស់ពីស្លាប់ឡើងវិញ និងសិរីល្អរបស់ទ្រង់ដែរ[១] ។ មួយវិញទៀត ពួកបរិសុទ្ធត្រូវរួមគ្នាមកតែ មួយដោយសេចក្តីស្រឡាញ់ ហើយដោយពេញចិត្តនឹងមកប្រកបគ្នាតាមអំណោយទាន និង ទេពកោសល្យរបស់ពួកគេ[២] ។

ហើយពួកគេមានករណីយកិច្ចរៀបចំកម្មវិធីជាសាធារណៈ និងផ្ទាល់ខ្លួន ដើម្បីនឹងលើកកំពស់សេចក្តីសុខសាន្តចំពោះគ្នានឹងគ្នា ទាំងផ្នែកខាងឯព្រលឹងវិញ្ញាណ និងទាំងផ្នែកខាងរូបកាយ[៣] ។

[១]១យ៉ូន ១:៣; យ៉ូន ១:១៦; ភី ៣:១០; រ៉ូម ៦:៥, ៦ ។ [២]អេ ៤:១៥, ១៦; ១កូ ១២:៧; ៣:២១-២៣ ។ [៣]១ថែស ៥:១១, ១៤; រ៉ូម ១:១២; ១យ៉ូន ៣:១៧, ១៨; កា ៦:១០ ។

២. យោងទៅតាមការប្រកាសប្រាប់ពីសេចក្តីជំនឿរបស់ពួកគេ ពួកបរិសុទ្ធត្រូវរក្សានូវការប្រកបគ្នាជិតស្និតដោយបរិសុទ្ធ ក្នុងការថ្វាយបង្គំព្រះ និងការបង្កើតកម្មវិធីផ្សេងៗ ដើម្បីលើកទឹកចិត្តគ្នា[៤] ។ នៅពេលដែលពួកគេមានបញ្ហាផ្សេងៗ ពួកគេមានកាតព្វកិច្ចជួយគ្នាទៅវិញទៅមកទៅតាមសេចក្តីត្រូវការ និងសមត្ថភាពរបស់ខ្លួន[៥] ។ យោងតាមដំណឹងល្អការប្រកបគ្នាបែបនេះ គួរអនុវត្តដល់គ្រួសារពួកជំនុំ[៦] របស់ខ្លួនជាមុនសិន ប៉ុន្តែនៅពេលដែលព្រះបានប្រទានឱកាស យើងគួរជួយមនុស្សទាំងអស់ដែលស្រែកអំពាវនាវរកព្រះនាមព្រះអម្ចាស់យេស៊ូវផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវតែយល់អំពីការចែករំលែកជាមួយគ្នាទៅវិញទៅមកនេះ មិនមានន័យថា យើងបាត់បង់សិទ្ធិក្នុងការមានអ្វីមួយជាកម្មសិទ្ធិផ្ទាល់ខ្លួននោះទេ[៧] ។

[៤]ហេ ១០:២៤, ២៥; ៣:១២, ១៣ ។ [៥]កិច្ច ១១:២៩, ៣០ ។ [៦]អេ ៦:៤; ១កូ:១២:១៤-២៧; ។ [៧]កិច្ច ៥:៤; អេ ៤:២៨ ។

# ជំពូក ២៨
# ពិធីបុណ្យជ្រមុជទឹក
# និង ពិធីលៀងព្រះអម្ចាស់

១. ពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ គឺជាពិធីដែលព្រះយេស៊ូវបានបង្កើត និងបង្គាប់ដល់យើង ដោយផ្ទាល់។ ទ្រង់មួយអង្គប៉ុណ្ណោះដែលជាអ្នកបង្កើតពិធីទាំងពីរនេះ ហើយ ពិធីទាំងពីរនេះទៀតសោត យើងត្រូវតែបន្តធ្វើក្នុងពួកជំនុំរបស់ទ្រង់ រហូតដល់ចុងបំផុតកល្បនៃផែនដី[១] ។

[១]ម៉ាថ ២៨:១៩, ២០; ១កូ ១១:២៦ ។

២. ពិធីបរិសុទ្ធទាំងពីរនេះត្រូវតែចាត់ចែង ដោយអស់អ្នកដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ ព្រមទាំងបានត្រាស់ហៅមកធ្វើកិច្ចការនេះទៅតាមការចាត់តាំងរបស់ព្រះគ្រីស្ទប៉ុណ្ណោះ [២] ។

[២]ម៉ាថ ២៨:១៩; ១កូ ៤:១ ។

# ជំពូក ២៩
# ពិធីបុណ្យជ្រមុជទឹក

១. ពិធីបុណ្យជ្រមុជទឹកគឺជាពិធីមួយនៃសម័យសញ្ញាថ្មី ដែលព្រះគ្រីស្ទទ្រង់បានបង្កើតឡើង ។ វាគួរជានិមិត្តរូបមួយដល់ពួកអ្នកដែលទទួលពិធីនេះថា ពួកគេមានការប្រកបគ្នាជាមួយព្រះគ្រីស្ទ ក្នុងការសុគត និងរស់ពីសុគតឡើងវិញរបស់ទ្រង់ ហើយក៏ជានិមិត្តរូបមួយដែលបង្ហាញថា ពួកគេត្រូវបានផ្សាំបំបៅមែកនៅក្នុងព្រះគ្រីស្ទហើយ[៣] ព្រមទាំងបង្ហាញពីការអត់ទោសចំពោះអំពើបាបរបស់ពួកគេផង[៤] ។ ពិធីបុណ្យជ្រមុជទឹកក៏បង្ហាញថា អ្នកដែលបានទទួលពិធីនេះ បានថ្វាយខ្លួនផ្ទាល់ដល់ព្រះ តាមរយៈព្រះយេស៊ូវគ្រីស្ទហើយ យ៉ាងនោះពួកគេអាចនឹងរស់នៅ ហើយដើរក្នុងជីវិតថ្មីជាមួយទ្រង់បាន[៥] ។

[៣]រ៉ូម ៦:៣-៥; កូល ២:១២; កា ៣:២៧ ។ [៤]ម៉ាក ១:៤; កិច្ច ២២:១៦ ។ [៥]រ៉ូម ៦:៤ ។

២. មានតែអស់អ្នកដែលបានលន់តួប្រែចិត្តនៅចំពោះព្រះ ដោយសេចក្តីជំនឿ និងដោយការស្តាប់បង្គាប់ចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទប៉ុណ្ណោះ ទើបស័ក្តិសមបំផុតក្នុងការទទួលពិធីនេះ[៦] ។

[៦]ម៉ាក ១៦:១៦; កិច្ច ៨:៣៦, ៣៧; ២:៤១ ; ៨:១២; ១៨:៨ ។

៣. វត្ថុផ្នែកខាងក្រៅដែលត្រូវប្រើប្រាស់ក្នុងពិធីនេះ នោះគឺជាទឹក ដែលជាកន្លែងសំរាប់បុគ្គលរូបនោះ ត្រូវទទួលពិធីជ្រមុជទឹក ដោយនូវក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ[៧] ។

[៧]ម៉ាថ ២៨:១៩, ២០; កិច្ច ៨:៣៨ ។

៤. ការជ្រមុជចូលទៅក្នុងទឹក ក្នុងពេលទទួលពិធីនេះ នោះវាចាំបាច់ណាស់សំរាប់ការរៀបចំដ៏ត្រឹមត្រូវចំពោះពិធីនេះ[៨] ។

[៨]ម៉ាថ ៣:១៦; យ៉ូន ៣:២៣ ។

# ជំពូក ៣០
# ពិធីលៀងព្រះអម្ចាស់

១. ពិធីលៀងនៃព្រះអម្ចាស់យេស៊ូវ ទ្រង់បានរៀបចំឡើងក្នុងពេលយប់តែមួយ ដែលសិស្សទ្រង់ម្នាក់បានក្បត់ របបូតមកដល់ថ្ងៃចុងបំផុតនៃផែនដី ដើម្បីរក្សាទុកអនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបាន នៅក្នុងចំណោមពួកជំនុំរបស់ទ្រង់ ហើយវាក៏បានបង្ហាញអោយឃើញថាទ្រង់បានប្រគល់អង្គទ្រង់ទៅក្នុងការសុគតរបស់ទ្រង់ដែរ[១] ។ ព្រះគ្រីស្ទក៏បានបញ្ជាក់ពីពិធីលៀងព្រះអម្ចាស់នេះផងដែរថា អត្ថប្រយោជន៍របស់ទ្រង់ គឺជាកម្មសិទ្ធរបស់ពួកបរិសុទ្ធទាំងអស់គ្នា ។ ហើយពិធីលៀងព្រះអម្ចាស់នោះ បានជួយអោយពួកគេធំចំរើនឡើងខាងឯព្រលឹងវិញ្ញាណ

ហើយអោយរីកចំរើននៅក្នុងទ្រង់ ព្រមទាំងចំរើនកំលាំងដល់ពួកគេសំរាប់ការរួមចំណែក និងការអនុវត្តន៍ភារកិច្ចទាំងអស់របស់ពួកគេនៅចំពោះទ្រង់ដែរ ។ មិនតែប៉ុណ្ណោះ វាជាចំណង និងកិច្ចសន្យានៃការប្រកបគ្នារបស់អ្នកជឿជាមួយនឹងទ្រង់ និងជាមួយពួកអ្នកជឿផ្សេងៗទៀត[២] ។

[១]១កូ ១១:២៣-២៦ ។ [២]១កូ ១០:១៦-១៧, ២១ ។

២. នៅក្នុងពិធីនេះ មិនមានន័យថាយើងយកព្រះគ្រីស្ទមកធ្វើជាដង្វាយថ្វាយដល់ព្រះវរបិតានោះទេ ហើយក៏មិនមែនជាយញ្ញបូជាពិតប្រាកដមួយ សំរាប់ការអត់ទោសបាបរបស់មនុស្សរស់ ឬមនុស្សស្លាប់ដែរ ។ ពិធីលៀងនេះគ្រាន់តែជាសេចក្ដីរំលឹកអំពីព្រះគ្រីស្ទថា ទ្រង់បានសុគតនៅលើឈើឆ្កាងមួយដងជាសំរេច[៣] ។ ពិធីនេះ ក៏ជាដង្វាយនៃការសរសើរខាងវិញ្ញាណដល់ព្រះ សំរាប់កិច្ចការមួយដងជាសំរេចនៅកាល់វ៉ារីដែរ[៤] ។ ផ្ទុយទៅវិញ ដង្វាយនៃពិធីលៀងព្រះអម្ចាស់របស់ពួកកាតូលិក ដែលពួកគេធ្លាប់ធ្វើនោះ គឺជាទង្វើដែលគួរអោយស្អប់ខ្ពើមបំផុត ហើយវាក៏ធ្វើអោយខូចដង្វាយរបស់ព្រះគ្រីស្ទ ដែលជាដង្វាយតែមួយគត់ ដើម្បីយកឈ្នះលើអំពើបាបរបស់ពួករើសតាំងទៀតផង ។

[៣]ហេ ៩:២៥, ២៦, ២៨ ។ [៤]១កូ ១១:២៤; ម៉ាថ ២៦:២៦, ២៧ ។

៣. នៅក្នុងពិធីនេះ ព្រះអម្ចាស់យេស៊ូវបានចាត់តាំងពួកអ្នកបំរើទ្រង់អោយអធិស្ឋាន ហើយអោយពរចំពោះនំប៉័ង និងស្រាទំពាំងបាយជូរ ដើម្បី ញែករបស់ទាំងនោះពីការប្រើប្រាស់បែបធម្មតា មកជាការប្រើ

ប្រាស់បែបបរិសុទ្ធវិញ ។ ពួកគេត្រូវកាច់នំបុ័ង និងយកពែងសំរាប់ខ្លួនឯង ព្រមទាំងចែកដល់ពួកអ្នកដែលត្រូវទទួលពិធីនោះ នៅពេលជាមួយគ្នាផង[៥] ។

[៥]១កូ ១១:២៣-២៦ ។

៤. ប្រសិនបើយើងបដិសេធ មិនព្រមទទួលយកពែងនៃព្រះអម្ចាស់ ឬប្រសិនបើយើងថ្វាយបង្គំ និងលើកដំកើងនំបុ័ង និងស្រាទំពាំងបាយជូរ ដោយការកោតសរសើរ ឬក៏បំរុងទុករបស់ទាំងនោះ សំរាប់ការប្រើប្រាស់ដែលមិនត្រឹមត្រូវ នោះមានន័យថា វាផ្ទុយទៅនឹងច្បាប់ និងបំណងព្រះហឫទ័យរបស់ព្រះគ្រីស្ទហើយ[៦] ។

[៦]ម៉ាថ ២៦:២៦-២៨; ១៥:៩; និក្ខ ២០:៤, ៥ ។

៥. នំបុ័ង និងស្រាទំពាំងបាយជូរនៃពិធីនេះ ត្រូវបានញែកចេញយ៉ាងត្រឹមត្រូវ សំរាប់ការប្រើប្រាស់ដែលព្រះគ្រីស្ទបានតាំងឡើង ដែលវាទាក់ទងទៅនឹងការជាប់ឆ្កាងរបស់ទ្រង់ អញ្ចឹងហើយ ជួនកាលគេហៅវាថា ជាតំណាងរូបកាយ និងព្រះលោហិតរបស់ទ្រង់[៧] ។ ប៉ុន្តែវានៅតែជានំបុ័ង និងស្រាទំពាំងបាយជូរធម្មតាដដែល ដូចមុនពេលដែលរបស់ទាំងនេះត្រូវបានញែកចេញដែរ[៨] ។

[៧]១កូ ១១:២៧ ។ [៨]១កូ ១១:២៦-២៨ ។

៦. ជាការដែលគួរអោយស្អប់ខ្ពើមណាស់ ចំពោះគោលលទ្ធិដែលបង្រៀនថា នំបុ័ង ហើយនិងស្រាទំពាំងបាយជូរ បានត្រឡប់ទៅជា

រូបកាយ និងព្រះលោហិតពិតៗរបស់ព្រះគ្រីស្ទ ដោយព្រោះពួកសង្ឃបានឧទ្ទិស ឬធ្វើតាមរបៀបណាផ្សេងទៀត[៩] ។ មិនតែប៉ុណ្ណោះ វាផ្ទុយទៅនឹងការសំដែងនៅក្នុងព្រះគម្ពីរ ហើយវាក៏ធ្វើអោយមានការភាន់ច្រឡំយ៉ាងខ្លាំងដែរ ។ ការនេះវាខុសពីពិធីរបស់ព្រះ ហើយបានក្លាយទៅជាជំនឿបែបឆ្វេងនិយម និងបែបជាការថ្វាយបង្គំរូបព្រះដោយងងឹតងងុលវិញ[១០] ។

[៩]កិច្ច ៣:២១; លូ ២៤:៦, ៣៩ ។ [១០]១កូ ១១:២៤, ២៥ ។

៧. ពួកអ្នកជឿពិតប្រាកដ ពួកគេមិនគ្រាន់តែទទួលតែផ្នែកខាងក្រៅរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែដោយផ្នែកខាងក្នុងដោយជំនឿផងដែរ ។ ពួកគេទទួលព្រះគ្រីស្ទជាអាហារខាងព្រលឹងវិញ្ញាណ ហើយ ពួកគេក៏បានទទួលគ្រប់ទាំងអត្ថប្រយោជន៍ ពីការសុគតរបស់ទ្រង់ផង ។ ពួកគេទទួលការនេះដោយពិតប្រាកដនៅផ្នែកខាងក្នុង ដោយសេចក្តីជំនឿ មិនមែនដោយការទទួលអាហារ ដោយបរិភោគសាច់មនុស្សនោះទេ ។ នៅក្នុងពិធីលៀងព្រះអម្ចាស់ រូបកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ទមានវត្តមានចំពោះសេចក្តីជំនឿរបស់ពួកអ្នកជឿ តាមរបៀបខាងវិញ្ញាណមួយ ដូចជានំប៉័ង និងស្រាទំពាំងបាយជូរមានវត្តមានចំពោះផ្នែករូបកាយខាងក្រៅដែរ[១១] ។

[១១]១កូ ១០:១៦; ១១:២៣-២៦ ។

៨. បានជាអ្នកណាដែលបរិភោគនំប៉័ងនេះ ឬផឹកពីពែងនៃព្រះអម្ចាស់ បែបមិនគួរសម នោះនឹងមានទោសចំពោះរូបអង្គ និងព្រះលោហិតនៃ ព្រះអម្ចាស់ ។ ត្រូវអោយមនុស្សនោះល្បងខ្លួនឯងមើល រួចសឹម បរិភោគនំប៉័ង ហើយផឹកពីពែងនេះចុះ ដ្បិតអ្នកណាដែលបរិភោគបែប មិនគួរសម អ្នកនោះឈ្មោះថា បរិភោគជាសេចក្តីជំនុំជំរះដល់ខ្លួនវិញ ដោយព្រោះមិនពិចារណាឃើញរូបអង្គនៃព្រះអម្ចាស់[១២] ។ អ្នកដែលមិន យល់ និងពួក អ្នកដែលមិនកោតខ្លាចព្រះ ពួកគេមិនមានទំនាក់ទំនង ជាមួយព្រះគ្រីស្ទទេ ដូច្នេះ ពួកគេមិនស័ក្តិសមនឹងបរិភោគក្នុងពិធីលៀង ព្រះអម្ចាស់ឡើយ ។ ហើយប្រសិនបើពួកគេបរិភោគ នោះពួកគេបាន ប្រព្រឹត្តិអំពើបាបដ៏ធំមួយប្រឆាំងនឹងព្រះយេស៊ូវហើយ ។ ដូច្នេះយើង ត្រូវតែហាមពួកគេមិនអោយចូលរួមជាដាច់ខាត រហូតដល់ពួកគេមាន ទំនាក់ទំនងផ្ទាល់ជាមួយព្រះគ្រីស្ទសិនទើបបាន[១៣]

[១២]១កូ ១១:២៧-២៩; ម៉ាថ ៧:៦ ។ [១៣]២កូ ៦:១៤, ១៥ ។

# ជំពូក ៣១
# សណ្ឋានរបស់មនុស្សក្រោយពីស្លាប់ទៅ និង ការរស់ឡើងវិញ

១. រូបកាយរបស់មនុស្សក្រោយពីស្លាប់ទៅនឹងត្រឡប់ទៅជាធូលី និងភាពពុករលួយ[១] ប៉ុន្តែព្រលឹងវិញ្ញាណរបស់ពួកគេវិញ មិនដែលស្លាប់ ឬដេកលក់សោះ ព្រោះថា វាមិនចេះស្លាប់ ហើយភ្លាមៗនោះវាក៏ត្រឡប់ទៅឯព្រះវិញ ដែលទ្រង់ជាអ្នកបានប្រទានវាមក[២] ។ គ្រប់ទាំងព្រលឹងនៃមនុស្សសុចរិតនឹងត្រូវធ្វើអោយបានគ្រប់លក្ខណ៍ឡើង ក្នុងភាពបរិសុទ្ធ គឺបានទទួលទៅនៅឯស្ថានសួគ៌ ជាកន្លែងដែលពួកគេរស់នៅជាមួយព្រះគ្រីស្ទ ហើយក៏ឃើញព្រះភ័ក្ត្រនៃព្រះ ដែលពេញដោយពន្លឺ និងសិរីរុងរឿង ដែលពួកគេកំពុងតែរង់ចាំសំរាប់ការប្រោសលោះដ៏ពេញលេញដល់រូបកាយរបស់ពួកគេ[៣] ។ តែផ្ទុយទៅវិញ ព្រលឹងវិញ្ញាណនៃពួកមនុស្សអាក្រក់នឹងត្រូវបោះទៅក្នុងស្ថាននរក ជាកន្លែងដែលពួកគេត្រូវរងទារុណកម្ម និងពេញដោយភាពងងឹត ហើយពួកគេនឹងត្រូវបានឃុំឃាំងនៅទីនោះ ដើម្បីទទួលការជំនុំជំរះនៅថ្ងៃដ៏អស្ចារ្យមួយ[៤] ។ ព្រលឹងមនុស្សដែលចេញពីរូបកាយ ហើយនឹងត្រូវទៅស្ថានសួគ៌ ឬស្ថាននរក ពីព្រោះព្រះគម្ពីរមិនបានសំដែងអំពីកន្លែងណាផ្សេងទៀតទេ ។

[១]លោក ៣:១៩; កិច្ច ១៣:៣៦ ។ [២]សាស ១២:៧ ។ [៣]លូ ២៣:៤៣; ២កូ ៥:១, ៦, ៨; ភី ១:២៣; ហេ ១២:២៣ ។ [៤]យូ ១:៦, ៧; ១ពេ ៣:១៩; លូ ១៦:២៣, ២៤ ។

២. នៅថ្ងៃចុងក្រោយ ពួកបរិសុទ្ធទាំងឡាយណាដែលនៅមានជីវិតរស់នៅនៅឡើយ នោះនឹងមិនត្រូវស្លាប់ទេ ប៉ុន្តែនឹងត្រូវបានផ្លាស់ប្រែរូបកាយរបស់ខ្លួនវិញ[៥] ។ ហើយ ពួកអ្នកដែលបានស្លាប់នោះនឹងបានរស់ឡើងវិញជាមួយរូបកាយដើមរបស់ពួកគេ[៦] ប៉ុន្តែ វានឹងមានលក្ខណៈផ្សេងគ្នា ហើយ រូបកាយនោះនឹងមករួមជាមួយព្រលឹងរបស់ខ្លួនវិញរហូតដល់អស់កល្បជានិច្ច[៧] ។

[៥]១កូ ១៥:៥១, ៥២; ១ថែស ៤:១៧ ។ [៦]យ៉ូប ១៩:២៦, ២៧ ។ [៧]១កូ ១៥:៤២, ៤៣ ។

៣. ដោយអំណាចនៃព្រះគ្រីស្ទ រូបកាយរបស់មនុស្សដែលមិនសុចរិតនោះនឹងត្រូវបានធ្វើអោយរស់ឡើងវិញសំរាប់សេចក្តីអាប់ឱន ។ ប៉ុន្តែ ដោយព្រះវិញ្ញាណរបស់ទ្រង់ ព្រះគ្រីស្ទនឹងប្រោសរូបកាយរបស់មនុស្សសុចរិត អោយរស់ឡើងវិញសំរាប់ជាកិត្តិយស ហើយទ្រង់នឹងបានធ្វើរូបកាយនោះអោយដូចជារូបកាយដ៏រុងរឿងផ្ទាល់របស់ទ្រង់ដែរ[៨] ។

[៨]កិច្ច ២៤:១៥; យ៉ូន ៥:២៨, ២៩; ភី ៣:២១ ។

# ជំពូក ៣២
# ការជំនុំជំរះចុងក្រោយ

១. ព្រះជាម្ចាស់បានជ្រើសរើសថ្ងៃមួយ ដើម្បីនឹងជំនុំជំរះលោកិយក្នុងសេចក្តីសុចរិតដោយព្រះយេស៊ូវគ្រីស្ទ[១] ។ ព្រះវរបិតាបានប្រគល់គ្រប់ទាំងអំណាច និងការជំនុំជំរះនោះដល់ទ្រង់ហើយ ។ នៅថ្ងៃនោះ ទ្រង់នឹងជំនុំជំរះអស់ទាំងពួកទេវតាដែលមិនស្តាប់បង្គាប់[២] និង មនុស្សទាំងអស់ដែលបានរស់នៅលើផែនដីនេះ ។ ពួកគេនឹងឈរនៅក្នុងទីសវនាការរបស់ព្រះគ្រីស្ទ ដើម្បីរៀបរាប់ពីគំនិត ពាក្យសំដី និងទង្វើរបស់ពួកគេ ដើម្បី នឹងទទួលនូវអ្វីដែលពួកគេបានធ្វើនៅក្នុងជីវិតរស់នៅរបស់ខ្លួន ទោះបើជាការល្អ ឬការអាក្រក់ក្តី[៣] ។

[១]កិច្ច ១៧:៣១; យ៉ូន ៥:២២, ២៧ ។ [២]១កូ ៦:៣; យូ ៦ ។ [៣] ២កូ ៥:១០; សាស ១២:១៤; ម៉ាថ ១២:៣៦; រ៉ូម ១៤:១០, ១២; ម៉ាថ ២៥:៣២-៤៦ ។

២. គោលបំណងនៃការតែងតាំងរបស់ព្រះជាម្ចាស់សំរាប់ថ្ងៃនោះ គឺដើម្បីបង្ហាញពីសិរីរុងរឿង នៃសេចក្តីមេត្តាករុណាចំពោះសេចក្តីសង្គ្រោះដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ សំរាប់ពួកអ្នកដែលទ្រង់បានជ្រើសរើស ហើយក៏បង្ហាញផងដែរ ពីភាពយុត្តិធម៌របស់ទ្រង់ ចំពោះការដាក់ទោសដ៏អស់កល្បជានិច្ចដល់ពួកមនុស្សអាក្រក់ និងពួកអ្នកដែលមិនស្តាប់បង្គាប់ព្រះ[៤] ។ មនុស្សសុចរិតនឹងទទួលបានជីវិតដ៏នៅអស់កល្ប

ជានិច្ចជាមរតក ហើយនឹងទទួលភាពពេញលេញនៃសេចក្តីអំណរ និង សិរីរុងរឿងនៅក្នុងវត្តមានរបស់ព្រះ ទុកជារង្វាន់ដ៏នៅអស់កល្ប ។ ប៉ុន្តែ ពួកមនុស្សអាក្រក់ដែលមិនស្គាល់ព្រះ និងមិនស្តាប់បង្គាប់តាមដំណឹងល្អ របស់ព្រះយេស៊ូវគ្រីស្ទ នោះនឹងត្រូវញែកចេញដោយឡែក អោយទៅ នៅក្នុងការរងទុក្ខអស់កល្បជានិច្ចវិញ[៥] ដោយត្រូវទទួលទារុណកម្មជា មួយនឹងសេចក្តីវិនាសដ៏អស់កល្ប ហើយពេលនោះ ពួកគេនឹងបានដាច់ ចេញឆ្ងាយពីវត្តមាន និងសិរីល្អនៃអំណាចព្រះចេស្តារបស់ទ្រង់[៦] ។

[៤]រ៉ូម ៩:២២, ២៣ ។ [៥]ម៉ាថ ២៥:២១, ៣៤; ២ធី ៤:៨ ។ [៦]ម៉ាថ ២៥:៤៦; ម៉ាក ៩:៤៨; ២ថែស ១:៧-១០ ។

៣. ព្រះគ្រីស្ទសព្វព្រះហឫទ័យចង់អោយយើងដឹងច្បាស់ថា មានការ ជំនុំជំរះនៅថ្ងៃខាងមុខ គឺដើម្បីការពារមនុស្សកុំអោយធ្វើបាប[៧] និងដើម្បី ផ្តល់ការកំសាន្តចិត្តកាន់តែច្រើនថែមទៀត ដល់ពួលបរិសុទ្ធ នៅក្នុង ការលំបាករបស់ពួកគេ[៨] ។ ទ្រង់បានកំណត់ថ្ងៃរបស់ទ្រង់ សំរាប់ថ្ងៃ នោះហើយ តែគ្មានមនុស្សណាម្នាក់បានដឹងទេ យ៉ាងនេះពួកគេអាចនឹង បោះបង់ចោលការជឿជាក់លើខ្លួនឯងចោលចេញ ដោយព្រោះតែមិន ដឹងថា ទ្រង់នឹងយាងមកនៅវេលាណា[៩] ដូច្នេះ ពួកគេត្រូវតែចាំយាម ហើយត្រៀមខ្លួនជាស្រេចដើម្បីនឹងនិយាយថា “ព្រះអម្ចាស់យេស៊ូវ អើយ! ឆាប់យាងមក! សូមទ្រង់យាងមកជាឆាប់...!” [១០] អាម៉ែន ។

[៧]២កូ ៥:១០, ១១ ។ [៨]២ថែស ១:៥-៧ ។ [៩]ម៉ាក ១៣:៣៥-៣៧; លូ ១២:៣៥-៤០ ។ [១០] វិវរ ២២:២០ ។